ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-May-2016, 15:01
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣៩៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| លោក ជុំ ម៉ី (2-TCCP-243) | ខ្មែរ |

# ខ្លឹមសារ (ឧបសម្ព័ន្ធ)

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ជុំ ម៉ី** (2-TCCP-243)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ............ ទំព័រ ៧
សួរដោយលោក ហុង គឹមសួន ផ្តើមពី ............ ទំព័រ ១១
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី ............ ទំព័រ ៣៤
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី ............ ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-243 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខ ស-២១ ហើយក៏ជាការចាប់ផ្តើម នៃការពិភាក្សាដេញដោលពិនិត្យភ័ស្តុតាងលើអង្គហេតុមន្ទីរសន្តិសុខ ស-២១ នេះដែរ។

ហើយមុននឹងបន្តកិច្ចដំណើរការសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីសំណុំរឿង០០២/០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ដោយលោកស្រីចៅក្រម ក្លូឌា ហ្វែនស៍ គាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន បន្ទាប់ពីយើងខ្ញុំបានពិគ្រោះពិភាក្សាយោបល់ជាមួយនឹងចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ដែលជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែងចៅក្រម ក្លូឌា ហ្វែនស៍ ដែលអវត្តមាននៅថ្ងៃនេះ។ ហើយការអនុវត្តនេះ ដោយផ្អែកលើខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៤:២០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-243។ ដើមបណ្តឹង

រូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ ហើយនៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-865។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនឹងធ្វើសម្បថជាមុន មុននឹងផ្ដល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមាន ដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦។

[០៩:០៥:៥៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះជាប្រចាំ ពិបាកអង្គុយ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ ដោយសារមុននឹងផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីតាមកាលវិភាគបានកំណត់ ដោយអង្គជំនុំជម្រះបានទទួលព័ត៌មានថ្មីៗមុនពេលចូលឆ្នាំខ្មែរពាក់ព័ន្ធទៅនឹងបញ្ហានៃដំណើរការសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243 អង្គជំនុំជម្រះសូមសួរទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា តើមានសំណើ ឬក៏មានការកត់សម្គាល់អ្វីដែរទេ មុននឹង -- ដើម្បីដោះស្រាយជាមុន ៗនឹងផ្ដើមចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243?

[០៩:០៧:៥១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម និងភាគីទាំងអស់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

បាទ អញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ក្នុងពេលឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ យើងបានផ្ញើជូនភាគីទាំងអស់និងអង្គជំនុំជម្រះនូវអ៊ីម៉ែលមួយពាក់ព័ន្ធទៅនឹងសំណើសុំដោយផ្អែកតាមវិធាន៨៧(៤) ដើម្បីសុំឱ្យអង្គជំនុំជម្រះទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ខ្ញុំឃើញលោកប្រធានដាក់កាសវិញហើយអ៊ីចឹងខ្ញុំសូមបន្តទៅទៀត។ ដើម្បីសូមការទទួលយកសៀវភៅដែលបោះពុម្ពដោយដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវស្ដាប់សក្ខីកម្មនៅថ្ងៃនេះ។ សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០១២ ដែលមានចំណងជើងថា "អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម"។ យើងបានផ្ញើជូនភាគី និងអង្គជំនុំជម្រះរួចមកហើយកាលពីថ្ងៃទី១១ ខែមេសា ហើយឧបសម្ព័ន្ធនៃសំណើនេះបង្ហាញអំពីសម្រង់ពាក់ព័ន្ធជាភាសាខ្មែរអង់គ្លេស និងបារាំង។ យើងខ្ញុំគិតថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ការស្ដាប់សក្ខីកម្មសាក្សីរូបនេះគឺត្រូវធ្វើឡើងដោយផ្អែកទៅលើសៀវភៅរបស់គាត់<ដែលបោះពុម្ពនៅឆ្នាំ២០១២>ផងដែរ។ នេះជាសំណើដែលយើងបានផ្ញើជូនអង្គជំនុំជម្រះនិងភាគីនៅថ្ងៃទី១១ ខែមេសា។ យើងមិនទាន់បានដាក់សំណើជាផ្លូវការនៅឡើយទេកាលពីពេលនោះ ដោយសារតែមានការរង់ចាំការបកប្រែជាភាសាខ្មែរក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរនោះ។ សូមអរគុណលោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:១០:១៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួនទៅលោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍។ ទី១ គឺពាក់ព័ន្ធទៅនឹងភាពយឺតយ៉ាវនៃសំណើនេះ។ ហេតុអ្វីបានជាលោកស្រីមិនដាក់សំណើនេះឱ្យបានមុនបន្តិចទៅ ពាក់ព័ន្ធនឹងការសុំឱ្យទទួលយកឯកសារនេះ? ហើយសំណួរមួយទៀត ថាតើសៀវភៅហ្នឹងមានជាភាសាខ្មែរ ឬក៏យ៉ាងម៉េច ហើយចុះភាសាផ្សេងទៀត? ហើយលោកស្រី<>ស្នើសុំទទួលយកសៀវភៅនេះទាំងមូលតែម្តង ឬក៏លោកស្រីគ្រាន់តែស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកសម្រង់មួយចំនួនដែលលោកស្រីបានដាក់នៅក្នុងឧបសម្ព័ន្ធតែប៉ុណ្ណោះ<ដែលមានទាំងបីភាសារួចហើយ>?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកចៅក្រម។ ពាក់ព័ន្ធទៅនឹងភាពយឺតយ៉ាវនៃការដាក់សំណើនេះ គឺយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ទទួលយក ឬក៏មិនទទួលយក។ សៀវភៅនេះត្រូវបានបោះពុម្ពនៅឆ្នាំ២០១២។ អង្គជំនុំជម្រះបានបញ្ជាក់អំពីការកោះហៅ<ដើមបណ្តឹងរដ្ឋប្បវេណីនេះ> គឺនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦។ ហើយយើងបានផ្ញើអ៊ីម៉ែលពាក់ព័ន្ធនឹងសំណើនេះ នៅថ្ងៃទី១១ ខែមេសា <ឆ្នាំ២០១៦>។ ហើយនៅក្នុងសំណើនេះ យើងបានបញ្ជាក់រួចមកហើយថា កាលពីអតីតកាល អង្គជំនុំជម្រះបានទទួលយកសៀវភៅមួយចំនួនក្នុងលក្ខខណ្ឌនៃពេលវេលាឆាប់រហ័សដូចគ្នានេះ ខ្ញុំយោងទៅលើកថាខណ្ឌ៩ នៃសំណើរបស់យើងខ្ញុំ។ ពាក់ព័ន្ធទៅនឹងសម្រង់<ដែលយើងខ្ញុំចង់>ស្នើសុំឱ្យទទួលយកនេះ គឺ<ជាសម្រង់ដែលបានបញ្ជាក់>នៅក្នុងឧបសម្ព័ន្ធ "ក" នៃសំណើរបស់យើង។ ហើយយើងខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះ និងភាគីថា សៀវភៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មានជាភាសាទាំងបី គឺខ្មែរ បារាំង អង់គ្លេស។ ដូច្នេះទាំងសម្រង់ ទាំងសៀវភៅ គឺមានជាភាសាទាំងបីតែម្តង អង់គ្លេស ខ្មែរ និងបារាំង។

[០៩:១២:៣៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ក៏ប៉ុន្តែលោកស្រីស្នើសុំឱ្យទទួលយកតែសម្រង់ដែលមាននៅក្នុងឧបសម្ព័ន្ធ ឬក៏លោកស្រីសុំឱ្យ

អង្គជំនុំជម្រះទទួលយកសៀវភៅនេះទាំងមូលតែម្តង?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមតែឲ្យទទួលយកតែសម្រង់នៅក្នុងឧបសម្ព័ន្ធតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសធ្វើសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងសំណើសុំរបស់ក្រុមសហមេធាវីនាំមុខតំណាងរដ្ឋប្បវេណី សុំទទួលយកឯកសារធ្វើជាឯកសារភ័ស្តុតាង ពិភាក្សាដេញដោលចំពោះសាក្សី -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២នេះ។ សូមអញ្ជើញ បាទ!

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ យើងខ្ញុំគាំទ្រចំពោះសំណើនេះ។ ខ្ញុំគិតថា ដើម្បីជាផលប្រយោជន៍យុត្តិធម៌ ចម្លើយពីមុនរបស់សាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលយក មុនពេលដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្ម ដើម្បីឲ្យយើងអាចសួរបានទាំងស្រុង ទៅលើចម្លើយពីមុនៗរបស់ពួកគាត់។ <ដូច្នេះហើយយើងអាចស្នើសុំដាក់ចូលទាំងអស់តែម្តង មិនមែនសុំដាក់តែសម្រង់ខ្លះនោះទេ។>

[០៩:១៥:២១]

ការបញ្ជាក់ពាក់ព័ន្ធនឹងសៀវភៅនេះ សម្រង់ដែលបានដាក់នៅក្នុងឧបសម្ព័ន្ធនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាចម្លើយរបស់គាត់ទាំងអស់ពីមុន<អមដោយឧបសម្ព័ន្ធ>។ ជាពិសេស គឺចម្លើយសារភាព<របស់គាត់>នៅ ស-២១។ ហើយយើងក៏មាននៅក្នុងសំណុំរឿងរួចមកហើយ ពាក់ព័ន្ធនឹងចម្លើយសារភាពនៅ ស-២១នេះ។ ដូច្នេះ<អ្វីដែលសំខាន់នោះគឺអ្វីដែលជាឧបសម្ព័ន្ធស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយ>សម្រង់<>ហ្នឹង គឺវាមានជាបីភាសា។ ហើយខ្ញុំមានការកត់សម្គាល់មួយពាក់ព័ន្ធទៅនឹងគុណភាពនៃសៀវភៅជាភាសាបារាំង។ ប្រសិនបើសៀវភៅនេះ<>ត្រូវបានទទួលយកនោះ ខ្ញុំនឹងប្រើជាភាសាអង់គ្លេសវិញ ពីព្រោះថាមើលទៅបកជាភាសាបារាំងគឺអន់មែនទែន ប្រហែលជាការបកប្រែគឺបកដាក់ចូល *ហ្គូហ្គលអូតូម៉ាទិក* ស្វ័យប្រវត្តិឲ្យបកមក អ៊ីចឹងបាត់កថាខណ្ឌ បាត់អីផ្សេងៗ។ អ៊ីចឹងបើអង្គជំនុំជម្រះទទួលយកឯកសារហ្នឹង គឺខ្ញុំសូមអនុញ្ញាតយកភាសាអង់គ្លេសមកប្រើវិញ ពីព្រោះថាភាសាបារាំង គឺយកជាការអីមិនកើតទេ។ យើងអានគឺយើងអានសម្រង់ជាភាសាអង់គ្លេស។

យើងដឹងថាសំណើនេះត្រូវបានដាក់យឺតពេល ក៏ប៉ុន្តែយើងគិតទៅតាមអ្វីដែលអង្គជំនុំជម្រះសម្រេចពីមុនពាក់ព័ន្ធទៅនឹងការមកផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីកាលពីមុន។ <វាមានប្រយោជន៍សម្រាប់>ភាគីក៏ដូចជាអង្គជំនុំជម្រះ<ដែលត្រូវ>មានសៀវភៅនេះ <>។ ហើយប្រសិនបើអង្គជំនុំជម្រះទទួលយកឯកសារនេះ យើងគួរតែដាក់លេខជាទំព័រវិញ កុំដាក់លេខជា ERN <ទាំងបីភាសា> ពីព្រោះថាយើងអាចងាយស្រួលក្នុងការស្វែងរកជាភាសាបារាំង, អង់គ្លេស និងខ្មែរ ដែលយើងគ្រាន់តែប្រាប់លេខទំព័រទៅយើងវាស្រួល។ សូមអរគុណលោកប្រធាន។

[០៩:១៦:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសធ្វើសារណាផ្ទាល់មាត់តបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងមិនមានបញ្ហាអ្វីនោះទេ ពាក់ព័ន្ធទៅនឹងឯកសារដែលត្រូវទទួលយកនេះ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសង្ឃឹមថានៅពេលក្រោយមេធាវីការពារក្តី នួន ជា គួរទទួលបានការអនុគ្រោះ ឬក៏ការយោគយល់បែបដូចគ្នានេះដែរ។ យើងដឹងថាពេលខ្លះ ទោះបីថាឯកសារហ្នឹងគឺអាចរកបាន<>តាំងពីយូរមកហើយក៏ដោយ ប៉ុន្តែទើបតែនៅពេលក្រោយភ្លាមនេះដែលយើងជួបប្រទះ។ ហេតុដូច្នេះហើយយើងយល់អំពីបញ្ហាទាំងអស់នេះ ហើយខ្ញុំយល់ថា ឯកសារនេះគឺអាចទទួលបាន។ ខ្ញុំមិនមានបញ្ហាអ្វីជាមួយនឹងការទទួលយកឯកសារនេះពីលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខាងមេធាវីការពារក្តីក៏យើងមិនមានការជំទាស់អ្វីដែរ ពីព្រោះថានេះជាចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[០៩:១៨:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៩:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមឱ្យអង្គជំនុំជម្រះទទួលយកឯកសារជាភស្តុតាង ហើយភាគីដទៃទៀតមិនមានការជំទាស់នោះ ដើម្បីឱ្យដំណើរការនីតិវិធីប្រព្រឹត្តទៅបានរលូននោះ គឺអង្គជំនុំជម្រះសម្រេចទទួលយកឯកសារនេះ ធ្វើជាឯកសារភស្តុ-តាងនៅក្នុងរឿងក្តីនេះ។ ឯសំអាងហេតុអង្គជំនុំជម្រះនឹងដាក់នៅពេលក្រោយ។

ជាបន្តទៅនេះ អង្គជំនុំជម្រះសូមបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

កុំអាលទាន់! ចាំៗក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឱ្យភ្លើងសញ្ញាភ្លើងក្រហមសិនណ៎ា លោក!

ឆ្លើយ!

**លោក ជុំ ម៉ី៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ ជុំ ម៉ាញ ហៅ ម៉ី ឯកឧត្តម។

[០៩:២៣:១២]

**ស៖** ឥឡូវនេះយើងសួរបញ្ជាក់ឈ្មោះ ឥឡូវដូចជាមានបញ្ហាឈ្មោះនេះ។ ហើយឈ្មោះដែលលោកប្រើប្រាស់ជាផ្លូវការសព្វថ្ងៃហ្នឹង ក្នុងការប្រកាស ប្រើប្រាស់ជាផ្លូវការ ដូចជាធ្វើអត្តសញ្ញាណពលរដ្ឋខ្មែរ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋខ្មែរជាដើមហ្នឹង តើលោកប្រើប្រាស់ឈ្មោះអីគេ ពិតប្រាកដ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកបង្អង់បន្តិចចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដៀងភ្នែកបន្តិចទៅ លោកមើលប្រតិបត្តិការសិន សឹមលោកឆ្លើយ។

**ឆ៖** ជម្រាបឯកឧត្តម ឥឡូវនេះ គេហៅតែ ជុំ ម៉ី ៗរាល់ថ្ងៃហ្នឹង ឯកឧត្តម។

**ស៖** យើងចង់បញ្ជាក់ឈ្មោះនេះឱ្យច្បាស់លាស់ ពីព្រោះបញ្ហាវាទាក់ទិនជាមួយនឹងអត្តសញ្ញាណបុគ្គល ពីព្រោះលោកប្រើអំមិញថា ឈ្មោះ ជុំ ម៉ាញ ហៅ ម៉ី។ បើតាមលោកនិយាយនេះ បានន័យថា វា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឈ្មោះ ជុំ ម៉ី ហៅ ម៉ាញ អាហ្នឹងបានវាត្រឹមត្រូវ។ បានន័យថា ឈ្មោះដែលប្រើផ្លូវការឈ្មោះ ម៉ី មិនមែនឈ្មោះ ម៉ាញ ទេ។ ឥឡូវឈ្មោះផ្លូវការ យើងចង់ដឹងឈ្មោះផ្លូវការដែលលោកប្រើឯកសារសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬក៏សំបុត្រកំណើតដែលលោកបានធ្វើនោះ តើលោកប្រើឈ្មោះអ្វីពិតប្រាកដ? ឈ្មោះ ម៉ី ឬក៏ឈ្មោះ ម៉ាញ?

**ឆ៖** ជម្រាបឯកឧត្តមរាល់ ថ្ងៃហ្នឹងឈ្មោះ ម៉ី ហៅ ជុំ ម៉ី ៗហ្នឹងបាទ។

**ស៖** បាទ អរគុណលោក ជុំ ម៉ី។ ហើយលោក កើតនៅថ្ងៃខែឆ្នាំណាលោកចាំទេ?

**ឆ៖** ខ្ញុំបាទកើតនៅឆ្នាំ១៩៣៣ ឯកឧត្តម។

[០៩:២៥:១៧]

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទកើតនៅខេត្តព្រៃវែង នៅឃុំល្វា ស្រុកកំពង់ត្របែក។

**ស៖** ចុះលំនៅឋានបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** រាល់ថ្ងៃហ្នឹង ខ្ញុំបានមកនៅត្រង់ គេហៅថា ផ្សារឈូកមាស ជិតវត្តសំរោងអណ្ដែត ឯកឧត្តម។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបរអ្វីដែរ សព្វថ្ងៃ?

**ឆ៖** រាល់ថ្ងៃហ្នឹង ខ្ញុំបាទលក់សៀវភៅប្រវត្តិខ្ញុំបាទជារៀងរាល់ថ្ងៃនៅសារមន្ទីរទួលស្លែង ឯកឧត្តម។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ជុំ ហើយម្ដាយឈ្មោះ តែត ឯកឧត្តម។

**ស៖** ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** គ្រួសារខ្ញុំបាទ គ្រួសារមុន ឈ្មោះ សំ សាវន។ មានកូនបួននាក់ តែស្លាប់ជំនាន់ប៉ុល ពត អស់ហើយ។

[០៩:២៦:៥៦]

**ស៖** ចុះសព្វថ្ងៃនេះ លោកមានភរិយាទេ? មានប្រពន្ធទេ?

**ឆ៖** ខ្ញុំបាទមានគ្រួសារថ្មីទៀត បានកូនស្រីបី កូនប្រុសបី រាល់ថ្ងៃ ឯកឧត្តម។

**ស៖** ហើយប្រពន្ធរបស់លោកក្រោយនេះ ឈ្មោះអី?

**ឆ៖** ប្រពន្ធរាល់ថ្ងៃឈ្មោះ ធឿន ឯកឧត្តម – សំ ធឿន។

**ស៖** បាទ អរគុណលោក ជុំ ម៉ី។ អង្គជំនុំជម្រះសូមជម្រាបលោកថា ជាចុងក្រោយនៃការស្តាប់សក្ខីកម្មរបស់លោក។ ក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ គឺលោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មទាំងឡាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ នេះគឺជាឱកាសដែលអង្គជំនុំជម្រះនឹងផ្តល់ទុកជូនលោកនៅពេលចុងក្រោយបំផុតនៃការផ្តល់សក្ខីកម្មរបស់លោកនាដំណើរការសវនាការនេះ។

ហើយលោក ជុំ ម៉ី តើលោកធ្លាប់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ពីពេលពេលកន្លងមក នៅក្នុងសំណុំរឿង០០២? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? នៅទីកន្លែងណាដែរ លោកចាំដែរទេ?

**ឆ៖** បាទ០០២ ខ្ញុំអត់ដែលបានធ្វើទេ ធ្លាប់ធ្វើតែ០០១ ឯកឧត្តម សក្ខីកម្ម។

**ស៖** ហើយលោកបានពិនិត្យមើលនូវសក្ខីកម្មរបស់លោកដែលលោកផ្តល់ពីសំណុំរឿងកន្លងមកទេ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ខ្ញុំបាទបានពិនិត្យខ្លះៗដែរ តែវាមិនបានល្អិតល្អន់ទេ ដោយសារខ្ញុំបាទភ្នែកហ្នឹង វាអត់ស្រួលកើតភ្នែកក្រហម។

[០៩:២៩:៤០]

**ស៖** ហើយតាមការពិនិត្យការអានរបស់លោកដែលលោកបានមើល គិតថាត្រួសៗហ្នឹង បើតាមលោកដឹង ឬក៏លោកចងចាំ តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលលោកបានអានដើម្បីរំឭកការចងចាំនោះ តើវាសមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍កាលពីពេលមុនន៎ុង នៅក្នុងសំណុំរឿងមុននោះដែរឬទេ?

**ឆ៖** ខ្ញុំបាទចង់បញ្ជាក់ជម្រាបឯកឧត្តមអ៊ីចេះថា ខ្ញុំបានចង់បញ្ជាក់ថា ពេលដែលគេចាប់ខ្ញុំមកហ្នឹង គឺតែថ្ងៃ១៨ ខែ៩ ឆ្នាំ៧៨។ គេកុហកអំឱ្យទៅជួយធ្វើឡាននៅវៀតណាម គេមិនយកទៅវៀតណាមយកចូលទួលស្លែង។

**ស៖** អង្គជំនុំជម្រះអត់ទាន់ចង់ដឹងអ៊ីចឹងទេ ចង់ដឹងខ្លឹមសារដែលលោកបានផ្តល់សក្ខីកម្មលើក

មុនជាលាយលក្ខណ៍អក្សរ ហើយបានលោកបានអាន បានន័យថាអង្គជំនុំជម្រះផ្តល់ឱកាសឲ្យបានអានមុន មុននឹងផ្តល់សក្ខីកម្ម ដើម្បីរំឭកការចងចាំឡើងវិញ អំពីអ្វីដែលលោកបានផ្តល់សក្ខីកម្មនៅពេលមុន។ ហើយសំណួរសួរថា អ្វីដែលលោកបានផ្តល់សក្ខីកម្មពីមុន ហើយបានអានដើម្បីរំឭកការចងចាំហ្នឹងវាស៊ីសង្វាក់គ្នា វាស្របគ្នាទេ ឬក៏វាមានខ្លឹមសារផ្ទុយគ្នា តាមដែលលោកបានពិនិត្យត្រួសៗហ្នឹង? ប៉ុណ្ណឹងទេ ហើយចំពោះសក្ខីកម្មលម្អិត បន្តិចទៀត យើងនឹងផ្តល់វេទិកាទៅភាគី គេនឹងសួរលម្អិតលើបញ្ហាទាំងអស់ហ្នឹងហើយ។ លោកអាចបញ្ជាក់បានដែរទេ ថាសមស្រប វាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មពីពេលមុនដែរឬទេ ព្រោះវារឿងវាយូរ ៗឆ្នាំណា?

[០៩:៣១:២៧]

**ឆ៖** បើតាមខ្ញុំស្តាប់បាន វាសមស្របតាមហ្នឹងដែរ ឯកឧត្តមបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋ-ប្បវេណី ជុំ ម៉ី មុនភាគីដទៃទៀត។ ភាគីទាំងពីរសហមេធាវីមុខ រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានអនុញ្ញាតឲ្យលោកមេធាវី ហុង គឹមសួន ចាប់ផ្តើមសំណួរសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញមេធាវី ហុង គឹមសួន!

[០៩:៣២:២០]

**លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមអរគុណ។ បាទសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព និង

អង្គសវនាការ ព្រមទាំងភាគីទាំងអស់។ ខ្ញុំបាទឈ្មោះ ហុង គឹមសួន ជាមេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងមានសំណួរទាក់ទងជាមួយនឹងប្រវត្តិរឿងរ៉ាវលោក ជុំ ម៉ី ដែលគាត់ជួបប្រទះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយដែលទាក់ទងជាមួយនឹងលោកប្រធានអនុញ្ញាតឲ្យគាត់មានឱកាសថ្លែងទុក្ខសោកផងដែរនោះ ខ្ញុំបាទនឹងសួរទាក់ទងពីមុនថ្ងៃ១៧ មេសា ១៩៧៥បន្តិច ហើយនិងចូលដល់ក្នុងចន្លោះពីថ្ងៃ១៧ មេសា ១៩៧៥ មកដល់ថ្ងៃចុងក្រោយបំផុតនៃថ្ងៃរបបកម្ពុជាប្រជាប្រធិបតេយ្យដួលរលំនៅថ្ងៃ០៦ មករា ១៩៧៩។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរលោក ជុំ ម៉ី។ ខ្ញុំសូមឲ្យលោកឆ្លើយសំណួរខ្លីៗ បើលោកមិនយល់ ចាំសួរត្រឡប់មកខ្ញុំវិញសិន ហើយនិងព្យាយាមមើលសញ្ញានៅពីមុនផង ដើម្បីឲ្យខាងលោកប្រធានបានស្តាប់ឮតាមរយៈការបកប្រែផងបាទ។ ខ្ញុំសូមសួរលោកបន្តិចថា មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានន័យថាបួនប្រាំថ្ងៃក៏ដោយ ឬក៏មួយអាទិត្យក៏ដោយ ខ្ញុំមិននិយាយវែងពេកទេ តើលោករស់នៅទីណា?

**លោក ជុំ ម៉ី៖**

**ឆ៖** បាទ ជម្រាបលោកមេធាវី។ មុនថ្ងៃ១៧ ហ្នឹងគឺថាខ្ញុំរស់នៅ តាមការពិតខ្ញុំនៅខាងច្បារមនកំពង់ស្ពឺ នៅជាមួយឯកឧត្តម ចន្ទរង្សី។ ក្រោយមក បានខ្ញុំមកទីក្រុងភ្នំពេញ មកនៅម្តុំផ្សារដេប៉ូជាមួយគ្រូពេទ្យម្នាក់ហៅ គ្រូពេទ្យ ឡុក លាន។

[០៩:៣៤:៣២]

**ស៖** បាទ សូមលោកពូស្តាប់សំណួរខ្ញុំ ខ្ញុំសូមសួរឲ្យលោកពូឆ្លើយឲ្យខ្លីៗទាក់ទងសំណួររបស់ខ្ញុំប៉ុណ្ណឹងសិនទៅណា។ អ៊ីចេះសំណួរខ្ញុំសួរថា មុនថ្ងៃ១៧ មេសា ១៩៧៥ មានន័យថាថ្ងៃដែលរបប លោក លន់ នល់ ដួលរលំ គឺរបបកម្ពុជាប្រជាធិបតេយ្យ មានគេហៅថាកងទ័ពខ្មែរក្រហមចូលភ្នំពេញនោះណាតើលោកពូចងចាំបានទេ?

**ឆ៖** មុនថ្ងៃ១៧ មេសា ដោយសារខ្ញុំ ដូចខ្ញុំជម្រាបប្រាប់អ៊ីចឹងថា ខ្ញុំមុននឹងគឺថា យើងនៅខាងកំពង់ស្ពឺ គេហៅច្បារមន នៅជាមួយ ចន្ទរង្សី។ ក្រោយមកគឺថា យើងមកនៅម្តុំផ្សារដេប៉ូ ជាមួយលោកតាឡុក លាន។

**ស៖** បាទ សូមអរគុណ។ តើការងាររបស់លោកពូ មុនថ្ងៃ១៧ មេសា ១៩៧៥ លោកធ្វើជាអ្វី

ដែរ?

**ឆ៖** មុនថ្ងៃ១៧ មេសា ខ្ញុំធ្វើជាជាង គេហៅថា *មេកានិចស្បាង* យន្តការី ជួសជុលត្រាក់ទ័រ ជួសជុលឡាន។

**ស៖** បាទ សូមអរគុណ។ មុនថ្ងៃ១៧ មេសា ១៩៧៥ ពីរបីថ្ងៃ ចង់និយាយថា មុនពីរបីថ្ងៃ ដែលកងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញហ្នឹង លោកនៅធ្វើជាជាងរាល់ថ្ងៃ ឬក៏ឈប់ហើយ?

**ឆ៖** នៅពេលនោះ មុនបីបួនថ្ងៃហ្នឹង គឺថាយើងឈប់ធ្វើជាជាងហើយ។ ពេលហ្នឹងគឺថា ទីក្រុងភ្នំពេញហ្នឹងកំពុងតែជ្រួលច្រាលអត់មានធ្វើអីបានទេ។

[០៩:៣៦:៣៦]

**ស៖** បាទ សូមអរគុណ។ សូមលោកពូបញ្ជាក់បន្តិចថា ទីក្រុងភ្នំពេញជ្រួលច្រាលហ្នឹង មានន័យយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបលោកមេធាវី គឺថាទីក្រុងភ្នំពេញ មុននេះហ្នឹង គឺថាជ្រួលច្រាលហ្នឹង ដោយសារគ្រាប់ផ្លោង ផ្លោងពីវិហារសួគ៍ ផ្លោងពីប្រសិទ្ធិ៍ ផ្លោងពីត្រាំខ្នារអី ចូលទីក្រុងភ្នំពេញទាំងអស់ ម៉្លោះហើយទីក្រុងភ្នំពេញចេះតែជ្រួលច្របល់ហើយបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកពូបានដឹងទេថា ការផ្លោងគ្រាប់ផ្លោងជុំវិញទីក្រុងភ្នំពេញចូលទីក្រុងភ្នំពេញហ្នឹង ជាគ្រាប់ផ្លោងខាងណាដែរ?

**ឆ៖** បើតាមខ្ញុំដឹងថា គ្រាប់ផ្លោងចូលទីក្រុងភ្នំពេញហ្នឹង គឺថាជាគ្រាប់ប្លោងរបស់ខ្មែរក្រហម។

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃទី១៧ ខែមេសា ១៩៧៥ តើទីក្រុងភ្នំពេញពេលហ្នឹងទៅជាយ៉ាងម៉េចដែរ?

**ឆ៖** នៅក្នុងទីក្រុងភ្នំពេញ គឺថា វាខ្ទេចខ្ទាំដោយសារគ្រាប់ផ្លោង ផ្លោងមកដូចជាឃ្លាំង ដូចជាសាលារៀន ដូចជាមន្ទីរពេទ្យអីៗហ្នឹងគឺថា វាឆេះខ្ទេចខ្ទីរអស់ខ្លះ បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកពូម្តងទៀតថា ថ្ងៃ១៧ មេសា ១៩៧៥ ថ្ងៃហ្នឹងតើមានឃើញកងទ័ពខ្មែរក្រហម ចូលមកដល់ទីក្រុងភ្នំពេញដែរទេ?

**ឆ៖** ពេលនោះខ្ញុំបានឃើញកងទ័ពខ្មែរក្រហម ស្លៀកខ្មៅ ពាក់ខ្មៅ គឺថា

[០៩:៣៨:៥៤]

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កុំអាលទាន់! កុំអាលទាន់លោក ជុំ ម៉ី!

សូមអញ្ជើញលោកមេធាវី អង់តា ហ្គីសសេ មេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអភ័យទោសដែលកាត់ផ្ដាច់លោកមេធាវី។ ខ្ញុំស្ដាប់ឮសំណួរដែលសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងទៅ ខ្ញុំមើលទៅ ដូចយើងកំពុងតែយល់ច្រឡំការកាត់ជំនុំជម្រះក្ដីហើយ <>យើងមិនមែននិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ វគ្គសវនាការយើងនេះ។ អ៊ីចឹងខ្ញុំមិនដឹងថា តើលោកមេធាវីសួរយ៉ាងម៉េចទេ អ៊ីចឹងសួរហ្នឹងដូចជាសួរក្រៅប្រធានបទ ចាកប្រធានហើយ យើងអត់មាននិយាយអំពីការជម្លៀសប្រជាជនទេនៅពេលនេះនោះ។

**លោក ហុង គីមសួន៖**

បាទ សូមអនុញ្ញាតលោកប្រធាន ដោយសារអម្បាញ់មិញ ខ្ញុំបាទឮលោកប្រធានអនុញ្ញាតឱ្យលោក ជុំ ម៉ី មានឱកាសថ្លែងទុក្ខសោកទាក់ទងជាមួយនឹងព្យសនកម្មទាំងឡាយ។ អ៊ីចឹងសំណួររបស់ខ្ញុំបាទនេះ ខ្ញុំដឹងថាថ្ងៃនេះ យើងនិយាយអំពីវិសាលភាពមន្ទីរសន្តិសុខស-២១ នៃរបបកម្ពុជាប្រជាធិបតេយ្យហើយ។ ក៏ប៉ុន្តែទាក់ទងទៅនឹងផលវិបាក ឬក៏ព្យសនកម្មរបស់គាត់គឺមានតាំងពីថ្ងៃដែលគាត់ មុននឹងចាកចេញពីទីក្រុងភ្នំពេញដោយការជម្លៀសនេះឯង ហើយគាត់នឹងមានរឿងរ៉ាវបន្តិចទៀតប្រាប់លោកប្រធាន និងអង្គជំនុំជម្រះឱ្យបានដឹងថា គាត់មានរងទុក្ខ ឬក៏វិនាសកម្មអ្វីខ្លះដែលទាក់ទងនៅក្នុងសម័យនោះ។ អ៊ីចឹងបានខ្ញុំបាទត្រូវសួរទាក់ទងនេះតិចសិន បានចូលទៅដល់ក្នុងសាច់រឿងដែលគាត់ត្រូវបានជាប់មន្ទីរឃុំឃាំងនោះបាទ។

[០៩:៤០:២២]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចសួរបាន គ្រាន់តែវាជាសំណួរបន្ទាប់បន្សំទេ មិនមែនជាសំណួរចម្បងនៃគោលដៅដែលអង្គជំនុំជម្រះធ្វើសក្ខីកម្មទេ ហើយពេលវេលាមានតែពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ភាគី រួមទាំងភាគីសហព្រះរាជអាជ្ញាផង។ សូមមេធាវីជ្រាបរវាងការជ្រើសរើសសំណួរសារវន្ត សំណួរចម្បង ហើយនិងសំណួរមធ្យម ហើយនិងសំណួរបន្ទាប់បន្សំក្នុងការតាំងសំណួរ។ បើសួរសំណួរបន្ទាប់បន្សំច្រើនពេក ពេលវេលាអស់ នោះគឺសុំមិនឱ្យទេ អនុញ្ញាតមិន -- អង្គជំនុំជម្រះមិនពន្យារពេល មិនផ្ដល់ពេលវេលាឱ្យទេ។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទនឹងសង្ខេបសំណួរសារវន្តខ្លីៗ ដើម្បីឱ្យមានទំនាក់ទំនងបន្តិចទៀត។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកពូ ជុំ ម៉ី ខ្ញុំសូមសួរលោកអំពីការចាកចេញពីទីក្រុងភ្នំពេញ។ តើការចាកចេញរបស់លោកពូហ្នឹងមានការពន្យល់ ឬការប្រាប់ ឬការប្រកាសយ៉ាងម៉េចពីខាងកងទ័ពខ្មែរក្រហមដោយឱ្យក្រុមគ្រួសារលោកចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ នោះបាទ?

[០៩:៤១:៤៧]

**លោក ជុំ ម៉ី៖**

**ឆ៖** ខ្ញុំបាទចង់ជម្រាបមេធាវីអីចេះ ព្រោះជម្លៀស ខ្ញុំបាទហ្នឹងវាមានពីរលើក។ លើកទី១ យើងនិយាយពីគឺថា ឆ្នាំ៧៩ អ៊ំា៧៥! ហើយលើកទី២ នេះថ្ងៃ០៧ មករា។ លោកមេធាវីចង់ឱ្យខ្ញុំនិយាយពីថ្ងៃ០៧ មករា ឬក៏ថ្ងៃ៩៥បាទ?

**ស៖** ឥឡូវអីចេះខ្ញុំសូមប្តូរសំណួរដើម្បីឱ្យលោកពូងាយយល់។ ថ្ងៃជម្លៀសចេញពីទីក្រុងភ្នំពេញថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ តើមានរឿងរ៉ាវអ្វីខ្លះកើតទៅលើសមាជិកក្រុមគ្រួសាររបស់លោកពូដែរទេ?

**ឆ៖** អាហ្នឹងលើកទី១ លើកដំបូងហើយលោកមេធាវី។

**ស៖** បាទ សូមលោកពូឆ្លើយនឹងសំណួរខ្ញុំសិនចុះ។

**ឆ៖** បាទ ហ្នឹង។ ពេលនុ៎ងគឺថាទីក្រុងភ្នំពេញហ្នឹងគឺថា គេដេញប្រជាជនចេញពីទីក្រុងភ្នំពេញគឺថាជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយសារកងទ័ពខ្មែរក្រហមហ្នឹងគឺស្លៀកខ្មៅ ពាក់ខ្មៅហ្នឹងមួរដៃអាវម្ខាងដេញប្រជាជនចេញ ឱ្យចេញទៅចំនួន៣ថ្ងៃ ខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក។ ពេលនុ៎ងគឺថាខ្ញុំនៅអែអង់ៗ ស្រាប់តែឃើញប្រជាជនអត់ចេញ ពួកខ្មែរក្រហមហ្នឹងបាញ់ប្រជាជនដួលបីនាក់នៅមុខខ្ញុំ ៗភ័យពេកចេញទៅប្រមូលគ្រួសារខ្ញុំចេញទៅខាងផ្លូវទៅផ្លូវជាតិលេខ៥។

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំសួរដដែលឡើងវិញ ថាតើសមាជិកគ្រួសារ មានន័យថា ជាប្រពន្ធ ជាកូន ជាបងប្អូនលោក តើមានរឿងរ៉ាវអីកើតឡើងទេ ពេលដែលត្រូវបានជម្លៀសចេញពីភ្នំពេញហើយនោះ?

[០៩:៤៤:០២]

**ឆ៖** ពេលដែលជម្លៀសចេញពីទីក្រុងភ្នំពេញហ្នឹង គឺថា យើងខ្ញុំចេញពីទីក្រុងភ្នំពេញចំនួនប្រហែលជា៣៣គីឡូ រហូតទៅដល់ព្រែកក្តាមហ្នឹង គឺថាពេលនុំង គឺថាមានភ្លៀងយប់។ ភ្លៀងយប់ហ្នឹងកូនខ្ញុំវាក្តៅ អាកូនអាយុពីរឆ្នាំហ្នឹងក្តៅរាក ហើយយើងទៅរកសុំថ្នាំគេឲ្យគាត់លេប។ ដល់ហើយគេថាឲ្យទៅសុំអង្គការ ទៅណោះ ឲ្យសុំអង្គការ។ ហើយយើងអស់ស្គាល់អង្គការ រហូតដល់កូនហ្នឹងស្លាប់ទៅ។ ស្លាប់ទៅ ខ្ញុំក៏បានទៅខ្ចីចបអ្នកស្រុកកាយរណ្តៅចិញ្ចើមថ្នល់ហ្នឹងកប់កូននៅហ្នឹង ហើយបានវាដេញឲ្យយើងធ្វើដំណើរតទៅទៀត។

**ស៖** ឥឡូវនេះ ខ្ញុំចង់បង្វែរសំណួរលោកពូមក អំពីការចូលមកទីក្រុងភ្នំពេញវិញតែម្តង។ ថាតើលោកពូចេញបានរយៈពេលប៉ុន្មានដែលត្រូវបានត្រឡប់មកទីក្រុងភ្នំពេញវិញ?

**ប្រធានអង្គជំនុំ៖**

បាទ កុំអាលទាន់! កុំអាលទាន់ ជុំ ម៉ី!

**លោក ជុំ ម៉ី៖**

**ឆ៖** យើងចូលទីក្រុងភ្នំពេញវិញ យើងទៅក្រៅហ្នឹង គេជម្លៀសទៅក្រៅបានប្រហែលជាកន្លះខែ គេហៅឲ្យចូលទីក្រុងភ្នំពេញវិញ ដោយសារយើងចេះជួសជុលត្រាក់ទ័រ ជួសជុលឡាន។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ លោកពូចូលមកទីក្រុងភ្នំពេញ តើគេឲ្យលោកពូមកធ្វើអីដែរ?

[០៩:៤៥:៥១]

**ឆ៖** ចូលមកទីក្រុងភ្នំពេញ គេឲ្យយើងជួសជុលកាណូត កប៉ាល់ ឲ្យពួកវា។ យើងជួសជុលប្រហែលជាបានប្រាំបីគ្រឿង ទៅពីរដណ្តប់គ្រឿង បាទ។

**ស៖** តើលោកពូនៅធ្វើការនៅក្នុងឫស្សីកែវហ្នឹង រហូតដល់ពេលណាទៀត ហើយផ្លាស់ទៅណាទៀតដែរទេ?

**ឆ៖** យើងនៅក្នុងឫស្សីកែវហ្នឹង បានប្រហែលជាខ្ទង់បីបួនខែ បានគេឲ្យយើងទៅអូរឫស្សី ទៅជួយប្រមែប្រមូលគ្រឿងបន្លាស់ដាក់ឃ្លាំង។

**ស៖** បាទ សូមអរគុណ។ ទៅអូរឫស្សី តើលោកពូទៅរស់នៅក្នុងជាកង ជាក្រុម ឬជាអង្គភាពឈ្មោះអីដែរ?

**ឆ៖** នៅក្នុងអូរឫស្សីហ្នឹង យើងអត់ដឹងថា ជាកងអីៗទេ យើងអត់ដឹង គឺយើងដឹងថាតែយើង

នៅក្នុងអូរឬស្សីហ្នឹង គឺថាគេឲ្យយើងជួយប្រមែប្រមូលម៉ាស៊ីនដេរឲ្យពួកវាជួសជុលម៉ាស៊ីនដេរឲ្យពួកវា។ ហើយបង្រៀនពួកវាប្រហែលជា២០នាក់ ហើយនារីៗ ប្រហែលជា១.០០០នាក់ ប្រុសៗ២០០នាក់ ដែរខោអាវខ្មៅៗ ពួកវាហ្នឹង បាទ។

**ស៖** តើលោកឮដឹងអង្គភាពនោះ គេហៅអង្គភាពអីដែរទេ?

**ឆ៖** គេហៅអង្គភាពកាត់ដេរ។ គេមិនមែនហៅអង្គភាពកងពលធំ កងពលតូចអី ខ្ញុំអត់ស្គាល់ទេ ស្គាល់តែអង្គភាពកាត់ដេរ។

[០៩:៤៧:៥២]

**ស៖** បាទ សូមអរគុណ។ លោកស្គាល់មេដឹកនាំនៅក្នុងអង្គភាពកាត់ដេរហ្នឹងឈ្មោះអីដែរទេ?

**ឆ៖** ប្រធាននៅអូរឬស្សីហ្នឹង គឺថាឈ្មោះ គុណ បាទ ឈ្មោះ គុណ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងអង្គភាពកាត់ដេរនោះ តើលោកបានធ្វើអ្វីខ្លះ ក្នុងនាមខ្លួនលោកផ្ទាល់?

**ឆ៖** ខ្ញុំបានជួសជុលម៉ាស៊ីនដេរ ហើយយើងបានបង្រៀនពួកវាបាន២០នាក់ ជួសជុលម៉ាស៊ីនដេរហ្នឹង វាបាន៦៧.០០០ក្បាល។

**ស៖** តើនៅក្នុងអង្គភាពកាត់ដេរអូរឬស្សីហ្នឹង ដែលមានមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមទៅពិនិត្យ ឬក៏ទៅធ្វើទស្សនកិច្ចដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** នៅក្នុងអូរឬស្សីហ្នឹង គឺថាខ្ញុំបានស្គាល់លោក ខៀវ សំផន ដោយសារមាននារីអ្នកដាំបាយហ្នឹង ខ្ញុំសួរគាត់ថា សួរថា ពីណាហ្នឹង? ហើយគាត់ថា ហ្នឹងហើយ ខៀវ សំផន។ អ៊ីចឹងគាត់មានអង្គរក្សពីរនាក់ ដើរការពារគាត់ហ្នឹង ហើយគាត់បង់កក្រមា មួយៗខាងស្មានេះ បង់កក្រមា។ ពេលនុ៎ង ខ្ញុំស្គាល់លោក ខៀវ សំផន ពេលនុ៎ង។

[០៩:៤៩:៤៧]

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកនៅចងចាំបានទេ នៅឆ្នាំណាដែរ លោក ខៀវ សំផន ទៅទស្សនកិច្ច ឬក៏ទៅពិនិត្យ

កន្លែងលោកពូនុំង?

**ឆ៖** ខ្ញុំមិនបានចាំអស់ទេ គ្រាន់តែថា ដឹងថាគាត់ទៅមើលខ្ញុំធ្វើចង្ក្រានដាំបាយ ដុតតែម្ខាងគឺថា ឆ្អិនបាយបាន៥ខ្ទះ ៦ខ្ទះ ដុតម្ខាងហ្នឹងបាទ។

**ស៖** សូមលោកពូបញ្ជាក់បន្តិច អំមិញលោកពូថា ផ្នែកខាងជួសជុលម៉ាស៊ីន ឬក៏បង្រៀនពួកកម្មករធ្វើម៉ាស៊ីនដេរ។ ឥឡូវលោកនិយាយអំពីការដែលធ្វើចង្ក្រានបាយ ហើយលោក ខៀវ សំផន មកពិនិត្យចង្ក្រានបាយហ្នឹង តើចង្ក្រានបាយហ្នឹងសម្រាប់ដាំយ៉ាងម៉េច ដាំក្នុងអង្គភាព ឬក៏ដាំយកទៅណា?

**ប្រធានអង្គជំនុំ៖**

អត់ៗ!

**លោក ជុំ ម៉ឺ៖**

**ឆ៖** ដាំហ្នឹង ដាំសម្រាប់អង្គភាពកាត់ដេរ នៅផ្សារអូរឬស្សីហ្នឹង។ ក្រោយមកទៅបាន ឃើញគេដាំច្រើន អ៊ីចឹងទៅគេខ្ចប់មួយកញ្ចប់ៗ គឺថាដាក់កញ្ចេរហ្នឹង ដើម្បីយកមកចែកជូនប្រជាជនគេជម្លៀសពីស្វាយរៀង ពីព្រៃវែងមកហ្នឹង មកនឹងវ៉ារទេះភ្លើងហ្នឹង។ ហើយពេលនោះខ្ញុំយកបាយ ជួយសែងបាយយកទៅវ៉ារទេះភ្លើងហ្នឹង ខ្ញុំបានឃើញលោក ខៀវ សំផន នៅហ្នឹងដែរ។

[០៩:៥១:៣១]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ តើពេលដែលលោក ខៀវ សំផន ទៅមើលកន្លែងដាំបាយ ឬក៏ទៅចែកបាយហ្នឹង លោកបាននិយាយជាមួយនឹងលោក ខៀវ សំផន ដែរទេពេលនោះ?

**ឆ៖** ខ្ញុំបាទអត់ប៉ាននិយាយរកគាត់ទេពេលនោះ គឺយើងអត់ប៉ានដើរជិតគាត់ផងហ្នឹង។

**ស៖** ចុះគាត់បាននិយាយអ្វីមកលោកពូ ឬនិយាយទៅរកពួកកម្មករកន្លែងរោងបាយហ្នឹងដែរទេ?

**ឆ៖** ក្រោយមក គឺថាខ្ញុំអត់បានដឹង បានឮសួរគាត់និយាយទេ គ្រាន់តែថាខ្ញុំបានសួរមិត្តនារីដាំបាយហ្នឹង ខ្ញុំសួរថាពីណាហ្នឹង? ហើយគាត់ប្រាប់ខ្ញុំថា ហ្នឹងហើយលោក ខៀវ សំផន នោះបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងអង្គភាពកាត់ដេរ លោកធ្វើការនៅកន្លែងហ្នឹងរហូតដល់ពេលណាដែលត្រូវបានផ្លាស់ចេញពីកន្លែងហ្នឹង?

**ឆ៖** នៅពេលហ្នឹងគឺថាខ្ញុំនៅកន្លែងនឹងគឺថា ដល់ថ្ងៃ២៨ -- ២៩ ខែ១០ហ្នឹង គឺថា គេកុហកខ្ញុំឲ្យទៅជួយធ្វើឡាននៅវៀតណាម គេមិនយកទៅវៀតណាម យកទៅទួលស្លែងហ្នឹង មានគ្នាបីនាក់ គឺថា

មិត្តទ្រី មួយ, មិត្តទឹម មួយ។

**ស៖** សូមថយក្រោយបន្តិច ពីព្រោះសំណួរខ្ញុំសួរមិនទាន់ដល់ហ្នឹង លោកពូបានឆ្លើយមុនហើយ ចង់និយាយថា នៅកន្លែងកាត់ដេរមុននឹងលោកផ្លាស់ចេញទៅនោះ លោកបានចូលរួមពិធីអីដែរទេ នៅក្នុងអង្គភាពកាត់ដេរហ្នឹង?

**ឆ៖** នៅក្នុងអង្គភាពកាត់ដេរហ្នឹង ខ្ញុំបានចូលរួមគ្រាន់តែប្រជុំជាក្រុមតូច គឺថាប្រជុំជីវភាពស្អីៗហ្នឹង ក្រោយមកគេបានឲ្យខ្ញុំចូលរួមជាមួយគេរៀបការ បាទរៀបការ២០គូ នៅផ្សារអូរឫស្សីហ្នឹងបាទ។

[០៩:៥៣:៥៦]

**ស៖** តើនៅក្នុងពេលរៀបការ២០គូហ្នឹង លោកពូចូលរួមក្នុងនាមជាអ្វី ជាមេកង ឬក៏ជាចាស់ទុំ ឬក៏ជាអ្វីដែរ?

**ឆ៖** គេឲ្យយើងចូលរួមហ្នឹង គេឃើញយើងជាចាស់ទុំ ម៉្លោះហើយគេឲ្យចូលរួមនៅហ្នឹងបាទ។

**ស៖** បាទ សូអរគុណ។ អម្បាញ់មិញលោកបាននិយាយអំពីការគេកុហកយកលោកទៅ។ តើមុននឹងលោកចាកចេញទៅដែលគេកុហកថា យកលោកទៅធ្វើ ជួសជុលគ្រឿងម៉ាស៊ីនទឹកន្លែងដទៃហ្នឹង មុនហ្នឹងមានបាត់មនុស្សពីកន្លែងធ្វើការរបស់លោកដែរទេ?

**ឆ៖** គឺថាពេលហ្នឹង គឺថា ប្រធាននៅហ្នឹងគេយកប្រធានហ្នឹងទៅបាត់ហើយ គឺថាឈ្មោះមិត្តគុណ ហ្នឹង។ យកមិត្តគុណ ទៅបាត់ឡើងមិត្តឈុំ ឡើងមិត្តឈុំ នៅធ្វើប្រធាននៅហ្នឹង។ ក្រោយមកគេយកមិត្តឈុំ ហ្នឹងទៅបាត់ទៀត ឡើងមិត្តយ៉ុង។ បន្តមកទៀត យកមិត្តយ៉ុង ទៅបាត់ទៅ ឡើងមិត្តវ៉ាន់ មកពីខាងតាកែវ ស្រីនោះ មកពីខាងតាកែវ។ អាពេលហ្នឹងហើយដែលគេ ជាមួយមិត្តលីន ហ្នឹងគេយកខ្ញុំទៅទួលស្លែង គេកុហកខ្ញុំ ឲ្យទៅជួយធ្វើឡាននៅទួលស្លែង អ៎! គេនៅប្រទេសយៀកណាម។

**ស៖** ដល់ពេលដែលគេប្រាប់លោកថា ឲ្យជុសជុលរថយន្តនៅវៀតណាមហ្នឹង តើគេឲ្យលោករៀបចំជាអីវ៉ាន់ ឬក៏គេឲ្យលោកទៅដោយវិធីណា? ទៅដោយគ្មានការចាប់ចង ឬក៏ទៅដោយដើរមានសេរីភាព?

**ឆ៖** គេអត់មានចាប់ចងយើងទេ គេឲ្យយើងឡើងអាឡាំប្រឹតា គ្នាបីនាក់ហ្នឹង ហើយយើងឡើងឡាំប្រឹតាព្រលឹមឡើងហ្នឹង ហើយដល់ហើយ យើងទៅយើងត្រូវតែមានអាកូនសោមួយគេស ហើយខ្ញុំលើកអាកូនសោដាក់លើឡាំប្រឹតាហ្នឹង អាមិត្តលីម នុំងវាថា មិនបាច់យកទៅទេ ទុកហ្នឹង ចាំគេផ្ញើទៅតាមក្រោយ។ អ៊ីចឹងយើងឡើងតែខ្លួនទៅ យើងជិះឡាំប្រឹតាទៅ។

[០៩:៥៦:៤៣]

**ស៖** លោកពូអាចបញ្ជាក់បានទេ លោកចាកចេញពីកន្លែងអង្គភាពកាត់ដេរហ្នឹងទៅតាមណា ហើយទៅដល់កន្លែងណាទើបបានគេចាប់លោក?

**ឆ៖** ពេលដែលយើងចេញពីអូរឫស្សីចេញទៅហ្នឹង គឺថាជិះឡាំប្រឺតា គឺថាទៅតាមអាផ្លូវវត្ត សំពៅមាស ចេញមកលើវត្តអី ជិតនេះហ្នឹង វត្តអីទេ វត្តភ្លេចហើយវត្តនុំង នៅនេះជិតស្ដាតនេះ ខាងត្បូង ស្ដាតនេះ។ វត្តនេះ បាទភ្លេចវត្តហ្នឹងហើយ។ ហើយយើងមកមកដល់វត្តហ្នឹង យើងព័ទ្ធមកខាងកើត បត់មកខាងកើតមកស្ដុបពេទ្យចិនហ្នឹង គឺថាមួយផ្លូវហ្នឹង គេបាំងស័ង្កសីលិចក្បាលរហូត បានយើងព័ទ្ធទៅខាងត្បូងវិញ ចុះពីពេទ្យចិនទៅដល់បូកគោ អត់ដល់បូកគោទេ។ ទៅដល់មេភ្លើងហ្នឹង គឺថាមានផ្លូវមួយចូលមកអីចឹង ចូលមកទួលស្លែងបាទ។

**ស៖** កាលដែលគេយកលោកទៅដល់ទីតាំងដំបូងហ្នឹង លោកពូដឹងថា គេយកទៅដាក់កន្លែងហ្នឹងឈ្មោះកន្លែងអីដែរទេ?

**ឆ៖** យើងអត់បានដឹងថាកន្លែងហ្នឹងជាកន្លែងអីទេ។ យើងគ្រាន់តែពេលដែលយើងចុះពីឡាំប្រឺតាហ្នឹង វាឲ្យយើងអង្គុយបីនាក់ អង្គុយកៅអីហ្នឹង ហើយយើងអត់ដឹងថា ពួកវានៅពួននៅខាងក្រោយខ្នងហ្នឹងទេ។ ពេលហ្នឹង គឺថាវាចាប់ដៃយើងទាញទៅក្រោយ វាដាក់ខ្នោះ ហើយក្រមាដែលខ្ញុំបង់កហ្នឹងវាយកមកចងមុខ គ្រប់គ្នាទាំងបីនាក់ហ្នឹង។

[០៩:៥៨:៣៨]

**ស៖** បាទ សូមអរគុណ។ ពេលដែលគេចាប់ មុននឹងចាប់ចងលោកហ្នឹង លោកមានមើលឃើញពួកអ្នកដែលមកចាប់ចងលោកហ្នឹងទេ ដែលគេមិនទាន់ចងភ្នែកហ្នឹង? តើពួកគេហ្នឹងជាប្រុសជាស្រីស្លៀកពាក់យ៉ាងម៉េច មានអាវុធយ៉ាងម៉េចដែរទេ?

**ឆ៖** ពេលហ្នឹងសុទ្ធតែប្រុសៗទេ មកចាប់ខ្ញុំហ្នឹង មានមិត្តលីម អីដែលវានៅហ្នឹងដែរ ហើយសុទ្ធតែប្រុសៗ គឺថាវាមានកាំភ្លើងសៀតនៅចង្កេះគ្រប់គ្នា។

**ស៖** ពេលដែលពួកហ្នឹងចាប់លោក ឬក៏ចងលោកហ្នឹង តើគេមាននិយាយយ៉ាងម៉េចដាក់មកលោកទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** ពេលនុំង វាទាញស្លឹកត្រចៀកខ្ញុំ ឲ្យឆ្លងថ្នល់។ ឲ្យឆ្លងថ្នល់ខ្ញុំបានប្រាប់ពួកវាថា “បងៗសុំជួយមើលគ្រួសារខ្ញុំផង”។ គ្រាន់តែខ្ញុំនិយាយប្រាប់ប៉ុណ្ណឹង វាធាក់ខ្ញុំមួយចុងត្រគៀកហ្នឹង ដួលផ្កាប់មុខទៅនឹងថ្នល់ហ្នឹង ហើយចាប់ទាញសក់ក្បាលឡើង។ “អាចុយម៉ាយ អ្អែងផ្ដាំផ្ញើអីទៀត អង្គការកម្ទេចតែទាំងអស់ហ្នឹងអ្អែង”។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ បន្ទាប់ពីគេធាក់លោកដួល ដេរលោករួចហើយ តើគេយកលោកទៅណាទៀត?

[១០:០០:១៨]

**ឆ៖** គេយកខ្ញុំទៅអាបន្ទប់មួយ គឺថាក្នុងបន្ទប់ហ្នឹង វាមានអាប្រដាប់គេវាស់កម្ពស់ គេវាស់កម្ពស់យើងហើយ គេថតរូប។ ថតរូបហើយ បានគេដោះអាវយើងចេញ ដោះខោវែងចេញ នៅតែខោខ្លី គេដាក់ខ្នោះដៃទៅក្រោយ គេយកក្រមាមកចងមុខខ្ញុំ បានគេបញ្ជូនទៅអាបន្ទប់០២២ហ្នឹង។ បន្ទប់គេដាក់អ៊ំហ្នឹង។

**ស៖** បាទ សូមអរគុណ។ សូមសួរថយបន្តិចទេ លោកពូ ថាតើអាពេលដែលគេយកទៅដល់បន្ទប់ហ្នឹង លោកពូមើលឃើញជុំវិញខាងក្រៅបន្ទប់ហ្នឹងទេ ថាកន្លែងហ្នឹង ជាកន្លែងអី មានជាអគារ ជាសាលា ឬក៏ជាផ្ទះថ្មអីអ៊ីចឹង ពូមើលឃើញដែរទេ?

**ឆ៖** ពេលនោះយើងមិនបានមើលឃើញទេ យើងមើលឃើញតែក្នុងអំឡុងប្រហែលជាមួយម៉ែត្រកន្លះបួនជ្រុងហ្នឹងទេ យើងមើលក្នុងហ្នឹង គឹងងឹតឈឹង អត់មានពន្លឺថ្ងៃទេ។

**ស៖** បាទ សូមអរគុណ។ សូមលោកពូបញ្ជាក់កន្លែងហ្នឹងបន្តិច ថាតើពេលដែលគេស្រាយមុខលោកពូ លោកពូអំមិញថា គេវាស់កម្ពស់ហើយ គេយកលោកពូទៅកន្លែងត្រង់ណាទៀត នៅក្នុងបន្ទប់មួយកន្លែងហ្នឹង?

**ឆ៖** អាបន្ទប់០២២ហ្នឹង វាយកទៅ វាបញ្ចូលខ្ញុំនៅហ្នឹង ដល់ហើយ វាថាឲ្យអង្គុយចុះ ឲ្យយើងអង្គុយចុះ។ ខ្ញុំអង្គុយចុះហើយ វាដាក់អាខ្នោះជើងយើង យកអាខ្នោះហ្នឹង មកដាក់ខ្នោះជើងយើង។ ដាក់ខ្នោះជើងរួច បានវាដោះអាខ្នោះដៃចេញ។ ដោះខ្នោះដៃចេញ បានស្រាយមុខ។ ស្រាយមុខហើយ វាចេញក្រៅ វាដាក់អាក្រណាត់បាំងត្រង់មាត់ទ្វារហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០២:២៣]

**ស៖** បាទ សូមអរគុណ។ លោកពូសូមបញ្ជាក់បន្តិច ថាតើពាក្យថា "បន្ទប់០២២" ហ្នឹង បន្ទប់យ៉ាងម៉េច? អគារយ៉ាងម៉េចដែរ?

**ឆ៖** អាបន្ទប់០២២ហ្នឹង គឺថាវាប្រហែលជាតែ១,៥០ម៉ែត្រ១ បាទហើយបណ្ដោយប្រហែលជា២ម៉ែត្រប៉ុណ្ណឹងទេ។ ពេលនុំងលោកចៅក្រមស៊ើបអង្កេតបានទៅមើលអាកន្លែងហ្នឹងដែរ ទៅមើលអាកន្លែងហ្នឹង ហើយបានសួរ ឌុច នៅកន្លែងហ្នឹង ថាកន្លែងហ្នឹង កន្លែងលោកតា ជុំ ម៉ី មែនអ្អី យ៉ាងម៉េច អីយ៉ាងម៉េច។ ពេលនុំង ឌុច ថាកន្លែងហ្នឹង កន្លែងលោកតា ជុំ ម៉ី ហើយបាទ។

**លោក ហុង គឹមសួន៖**

លោកប្រធាន សូមអនុញ្ញាតពីលោកប្រធាន សុំឱ្យគាត់ចង្អុលបង្ហាញនៅក្នុងសៀវភៅរបស់គាត់ ថាតើរូបនៅក្នុងនេះ មែនឬទេ បាទ?

**ប្រធានអង្គជំនុំ៖**

ចុះមានការបង្ហាញដោយទូរទស្សន៍ដែរទេ ដែរៗ ក្នុងទូរទស្សន៍ដែរទេ? ឬក៏បង្ហាញ គ្រាន់តែឃើញតែម្នាក់ឯង ជាមួយនឹងសាក្សី អ៊ំ ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក ហុង គឹមសួន៖**

បាទ សូមជម្រាបលោកប្រធាន សូមឱ្យគាត់បង្ហាញ -- អ៊ំ ពិនិត្យតែខ្លួនគាត់ហ្នឹង។

[១០:០៣:៤៩]

**ប្រធានអង្គជំនុំ៖**

ចុះពិនិត្យតែគាត់ទៅ ដល់ពេលគាត់ឆ្លើយទៅ គាត់គិតថាម៉េច ឥឡូវនេះ វាបញ្ហាបច្ចេកទេស និងការឱ្យសាធារណជន និងភាគីដទៃទៀតដឹង។ ធ្វើយ៉ាងម៉េចឥឡូវ?

**លោក ហុង គឹមសួន៖**

សូមអនុញ្ញាតលោកប្រធាន។ អ៊ីចឹងខ្ញុំបាទសូមអានជាលេខនៅក្នុងសៀវភៅ ដើម្បីសម្គាល់អំពីរូបភាពស្ថិតនៅក្នុងទំព័រទីប៉ុន្មានបានទេ បាទ?

**ប្រធានអង្គជំនុំ៖**

ចុះលើកតាមបច្ចេកទេស ប៉ុន្តែលោកធ្វើអ្វីដើម្បីឱ្យភាគីពាក់ព័ន្ធដទៃទៀតហ្នឹងគេយល់ដឹងអំពីបញ្ហានេះ។

សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារយើងអត់ទាន់បានទទួលឯកសារដែលលោកមេធាវីបម្រុងនឹងបង្ហាញនេះ។ អ៊ីចឹងសូមឲ្យលោកមេធាវីចែកអាកូពីនេះ ជាមុនសិនទៅ ដើម្បីឲ្យយើងអាចយល់ពីរូបនេះផង បាទ។ សូមអរគុណ។

[១០:០៤:៥១]

**លោក ហុង គីមសួន៖**

បាទ ខ្ញុំបាទ និងខាងសហការីជួយកូពីជូនទៅខាងភាគីទៀត បាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** អ៊ីចឹងខ្ញុំបាទសូមអនុញ្ញាតបន្តសំណួរទៀត។ ដោយសារយើងមិនទាន់បានរៀបចំក្នុងការផ្សាយតាមរូបភាពនៅលើអេក្រង់ អ៊ីចឹងខ្ញុំបាទសូមបន្តសំណួរទៅទៀតបាទ។ លោកពូ ខ្ញុំសូមសួរលោកពូបន្តទៀត ទាក់ទងជាមួយនឹងបន្ទប់០២២ ដែលលោកពូបានជម្រាបអង្គសវនាការអម្បាញ់មិញ តើលោកពូអាចជម្រាបបានទេថា នៅក្នុងបន្ទប់ឃុំឃាំងលោកពូហ្នឹងមានគ្នាប៉ុន្មាននាក់?

**លោក ជុំ ម៉ី៖**

**ឆ៖** នៅក្នុងបន្ទប់ គេដាក់អ៊ំហ្នឹង ដាក់បានតែម្នាក់ទេ គេមិនអាចដាក់បានពីរនាក់ទេ។

**ស៖** តើលោកពូនៅចងចាំបានទេថា បន្ទប់ដែលគេដាក់ឃុំឃាំងលោកពូដំបូងហ្នឹងជាទទឹងប៉ុនណា បណ្ដោយប៉ុនណា ហើយជញ្ជាំងធ្វើអំពីអ្វីខ្លះ?

**ឆ៖** បន្ទប់គេដាក់អ៊ំហ្នឹង បើអ៊ំស្មាន ប៉ាន់ស្មានថាប្រហែលជាទទឹងហ្នឹង ប្រហែលជា១,៥០ម៉ែត្រទេ បណ្ដោយប្រហែលជា២ម៉ែត្រ។

**ស៖** តើនៅក្នុងបន្ទប់ហ្នឹងគេមានដាក់ជារបស់របរ ឬឧបករណ៍អ្វីខ្លះឲ្យលោកពូប្រើប្រាស់ទេ?

**ឆ៖** នៅក្នុងបន្ទប់ហ្នឹងគឺថាយើងមើលឃើញនៅនុ៎ង គេបើកភ្នែកឲ្យយើងមើល យើងមើលឃើញមានអាកេសគ្រាប់មួយ គេសម្រាប់ឲ្យយើងជុះអាចម៍ ហើយអាប៊ីដុងជ័រមួយសម្រាប់ឲ្យយើងឈឺនោម។ ហើយប៊ីដុង អាកេសគ្រាប់ហ្នឹង ជុះអាចម៍ហ្នឹង តែវាបានប្រាប់យើង ប្រាប់យើង អ្លែងតែជុះខ្លាយ វាឲ្យយើងលិឍហើយ។

[១០:០៧:០៣]

01246988



**ស៖** បាទ សូមអរគុណលោកពូ។ នៅថ្ងៃដំបូងដែលលោកពូទៅដល់បន្ទប់០២២នោះ តើគេមានប្រាប់លក្ខខណ្ឌ ឬជាបទប្បញ្ញត្តិអីទេ ដែលពួកគេនាំពូទៅដាក់នៅក្នុងបន្ទប់ហ្នឹង?

**ឆ៖** នៅក្នុងបន្ទប់ហ្នឹង គេគ្រាន់តែប្រាប់យើងថា កុំឲ្យនិយាយទៅ និយាយគ្នានៅអាបន្ទប់ជិតៗហ្នឹង យើងនៅឲ្យស្ងៀម។

**ស៖** ថ្ងៃដំបូងដែលលោកពូអញ្ជើញទៅដល់កន្លែងហ្នឹង ដែលគេយកទៅដាក់បន្ទប់០២២ហ្នឹង តើគេមានឲ្យទឹក ឲ្យបាយ ឲ្យម្ហូបអាហារលោកពូពិសាទេ?

**ឆ៖** ពេលដែលថ្ងៃវាវ៉ៃសួរចម្លើយហ្នឹង ពេលព្រឹកវាឲ្យទឹកបបរមួយវែក ពេលល្ងាចវាឲ្យទឹកបបរមួយវែក។ ហើយបើយើងស្រេកទឹក យើងសុំវា វាឲ្យផឹកបន្តិចៗទេ អត់ឲ្យផឹកច្រើនទេ។

**ស៖** សូមអរគុណ។ ចុះថ្ងៃដដែល ថ្ងៃដំបូងហ្នឹង តើលោកពូនៅក្នុងបន្ទប់ហ្នឹងរហូតទៅដល់ថ្ងៃស្អែក ឬមានគេយកពូកទៅណាទៀតដែរទេ?

**ឆ៖** យើងនៅក្នុងអាបន្ទប់តូចហ្នឹង គឺថាវាវ៉ៃ វាសួរចម្លើយ វាវ៉ៃ១២ថ្ងៃ១២យប់។ វាវ៉ៃពេលព្រឹកហ្នឹងពីម៉ោងប្រាំពីរព្រឹករហូតដល់ម៉ោងម៉ាដណ្តប់ ម៉ោងមួយរហូតដល់ម៉ោងប្រាំ ពីម៉ោងប្រាំមួយ រហូតដល់ម៉ោងដប់យប់។ ១២ថ្ងៃ១២យប់នៅក្នុងបន្ទប់ហ្នឹង។ ដល់សួរចប់ហើយៗ បានវាយកទៅដាក់ឯលើណោះ៤ខែ។

[១០:០៩:០៨]

**ស៖** សូមៗលោកពូស្តាប់សំណួរខ្ញុំម្តងទៀត។ សំណួរខ្ញុំសួរថានៅក្នុងបន្ទប់០២២ហ្នឹង គេមានយកលោកពូចាកចេញពីបន្ទប់០២២ ទៅណាទៀតដែរឬទេ?

**ឆ៖** នៅអាបន្ទប់០២២ហ្នឹង គេយកទៅវ៉ៃសួរចម្លើយនៅអគារឯត្បូងណោះ នៅលើ នៅបន្ទប់លើនោះ តាមខ្ញុំដឹងថាក្រោយមកទេ ដែលខ្ញុំមើលឃើញ ហើយអាបន្ទប់ហ្នឹងលេខ៤ ដោយសារថ្ងៃក្រោយទេណា ខ្ញុំមើលឃើញបន្ទប់ហ្នឹងលេខ៤ បន្ទប់គេវ៉ៃខ្ញុំហ្នឹង។

**លោក ហុង គឹមសួន៖**

លោកប្រធានសូមអនុញ្ញាតលោក ពេជ អង្គ លោកចង់សុំបង្ហាញពីការបញ្ជូនឯកសារទៅភាគីបន្តិចបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ពេជ អង្គរ៖**

បាទ សូមគោរពលោកប្រធាន។ ដោយសារថាលោកមេធាវី គង់ សំអុន បានសួរបញ្ជាក់អំពីឯកសារ ដើម្បីឲ្យមានការចែកចាយអំពីឯកសារនោះជូនទៅដល់ភាគី។ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ថា នៅក្នុងអ៊ីម៉ែលពីការិយាល័យមេធាវីនាំមុខ គឺអ៊ីម៉ែលដែលផ្ញើ -- មួយត្រូវបានផ្ញើចេញជូនទៅដល់មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះដោយលោកស្រី អេឡេណ័រ ហ្វេរណាន់ដេស នៅថ្ងៃចន្ទ ទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងបួន ម្ភៃបីនាទីល្ងាច។ ហើយនៅក្នុងអ៊ីម៉ែលនោះបានបញ្ជាក់ថា ឯកសាររបស់មេធាវីនាំមុខដែលស្នើសុំឲ្យមានការទទួលអំពីអង្គជំនុំជម្រះគឺត្រូវបានដាក់នៅក្នុង*ជីដ្រាយ ជី-ស៊ីវិលផាតធីលីដខូឡូយ៉េរ រូល* វិធាន៨៧(៤) គឺបានដាក់នៅក្នុងឯកសារ *ជីដ្រាយ* របស់មេធាវីនាំមុខសម្រាប់ចែកចាយជូនទៅភាគីរួចហើយ។ ហើយភាគីអាចចូលទៅក្នុងកន្លែងនោះដើម្បីរកឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបាន។ សូមអរគុណលោកប្រធាន។

[១០:១១:១៦]

**ប្រធានអង្គជំនុំ៖**

សំខាន់លោកចង់បង្ហាញនេះទំព័រប៉ុន្មាន? ឥឡូវហ្នឹងបើភាគី គ្រប់ភាគី ហើយចង់បានឲ្យមើលឯកសារទៅរក *ដ្រាយជី* រៀង១ខ្លួនហ្នឹង ហើយទៅរករបៀបយ៉ាងម៉េចទៅ ហើយបើឯកសារទាំងអស់ចង្អុលបង្ហាញតែរបៀបនេះ។ យើងចង់ដឹងថា លោកកត់សម្គាល់ទេ ឥឡូវ*វេក* ទំព័រប៉ុន្មាន ឥឡូវហ្នឹងព្រោះមិនទាន់មានលេខERNទេ។ តើទំព័រប៉ុន្មានដែលជាភាសាខ្មែរទំព័រខ្មែរ ទំព័រប៉ុន្មានជាភាសាអង់គ្លេស ទំព័រប៉ុន្មានជាភាសាបារាំង ដើម្បីដាក់កត់ត្រានៅក្នុងប្រតិចារឹក ដើម្បីឲ្យភាគីពាក់ព័ន្ធហ្នឹងមើលនាពេលខាងមុខបាន។ ហើយនិងព្រីនចែក បែងចែក ហ្វូតូកូពីបែងចែកភាគី និងអង្គជំនុំជម្រះបានពិនិត្យមើលមុននឹងសួរដេញដោលនោះ។

**លោក ពេជ អង្គរ៖**

បាទ សូមអរគុណលោកប្រធាន។ សូមអធ្យាស្រ័យដែលពិបាកនៅក្នុងការនិយាយបន្តិច។ ខ្ញុំគ្រាន់ចង់បញ្ជាក់ថា ឯកសារគឺបានដាក់នៅក្នុងកន្លែងមួយដែលភាគីអាចចូលទៅមើលនៅក្នុងឯកសារនោះបានហើយ។ ហើយអ្វីដែលលោក គឹមស្ងួន បានលើកអម្បាញ់មិញអំពីរូបថតនៃបន្ទប់ឃុំឃាំងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី នេះ គឺនៅសៀវភៅរបស់គាត់ ភាសាខ្មែរគឺអាចមើលឃើញនៅក្នុងទំព័រ ៥០ ហើយភាសាបារាំង និងភាសាអង់គ្លេសអាចមើលឃើញបានដូចគ្នានៅក្នុងទំព័រលេខ៣៨។ សូម

អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៥នាទី)*

[១០:៣៥:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណ លោកប្រធានម្ដងទៀត។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោកពូ ជុំ ម៉ី អំមិញយើង ខ្ញុំបាទបានសួរលោកពូមកដល់កន្លែងសួរចម្លើយហើយ។ នៅថ្ងៃដែលគេយកលោកពូទៅដាក់នៅបន្ទប់តូច ហើយគេយកលោកពូមកសួរចម្លើយ លោកពូបានជម្រាបអង្គសវនាការអម្បាញ់មិញថា មានរយៈពេល១២ថ្ងៃ។ តើក្នុងអំឡុងរយៈពេល១២ថ្ងៃ ដែលការសាកសួរនោះ តើគេសួរលោកពូ ឬក៏គេចោទប្រកាន់លោកពូពីទោសកំហុសអ្វីដែរទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** ពេលនោះ គឺថាគេវាយអឺសួរថា “គ្នាអ្នែងមានប៉ុន្មាននាក់ចូល សេ.អ៊ី.អា ចូល កា.ហ្សេ.បេ?” ហើយយើងប្រាប់គេថា “ខ្ញុំអត់ស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ទេ ពេលនោះ។ អាសេង ហ្នឹង ទាញរំពាត់វ៉ាវមក វាយខ្ញុំផ្ទួងៗទៅ។

**ស៖** បាទ សូមអរគុណ។ ការធ្វើទារុណកម្មមកលើលោកពូនោះ តើធ្វើក្រៅអំពីវាយ តើមានធ្វើអ្វីទៀតទេ?

**ឆ៖** ពេលវាយ ខ្ញុំយកដៃរងអ៊ីចឹង បាក់អាកូនដៃហ្នឹងមួយ។ ហើយបន្ទាប់មក វាយកអាដង្កាប់មួលអាក្រចកជើង មេជើងហ្នឹង ទាញផ្តាច់ បាទ ទាញផ្តាច់បាទ។

[១០:៣៧:៤៣]

**ស៖** តើលោកពូឆ្លើយយ៉ាងម៉េច បានគេវាយបាក់ម្រាមដៃ ហើយគេដកក្រចកជើងលោក?

**ឆ៖** យើងឆ្លើយថា យើងអត់ស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងទេ។ ពេលនុ៎ង គឺថាវាវាយថែមទៀត គឺថាវាយហើយ វាយកអាខ្សែភ្លើងមកញាត់ស្លឹកត្រចៀកយើងហ្នឹង ញាត់ឆាច់អ៊ីចឹងទៅ ប៊ឹង! ដូចរយះ ដូចបែកអំពិលអំពែកអ៊ីចឹង យើងសន្លប់មួយសន្ទុះធំ។

**ស៖** តើការឆក់ខ្សែភ្លើងទៅលើលោកពូហ្នឹង មានប៉ុន្មានដងដែរ?

**ឆ៖** ឆក់ខ្សែភ្លើងហ្នឹង មានពីរដង ជម្រាបលោកមេធាវី ឆក់ពីរដង បាទ។ ហើយអា--

**ស៖** តើមុន--

**ឆ៖** ត្រចៀកម្ខាងហ្នឹង ភ្នែកម្ខាងហ្នឹង ឥឡូវប្រើការអត់កើតទេ។ អាត្រចៀក ស្តាប់ទៅអត់ឮទេ ភ្នែកមើលឃើញព្រិលៗទេ បានតែមួយខាងនេះទេ។

**ស៖** តើហេតុផលនៃការស្តាប់មិនសូវឮ ឬក៏ភ្នែកមើលមិនសូវឃើញម្ខាងហ្នឹង ចាប់តាំងពីពេលណាមក?

**ឆ៖** ពេលដែលវាដាក់ខ្សែភ្លើងឲ្យឆក់អ៊ំហ្នឹង គឺថាចាប់ពេលនុ៎ងមក ឆក់ខ្សែភ្លើងហ្នឹង។

**ស៖** សូមអរគុណ។ លោកពូថា មានការធ្វើទារុណកម្មលោកពូរយៈពេល១២យប់ ១២ថ្ងៃ ទើបលោកពូឆ្លើយសារភាព។ តើលោកពូយល់អត្ថន័យដែលគេចង់ឲ្យលោកពូឆ្លើយយ៉ាងម៉េច ទើបលោកពូឆ្លើយសារភាពកើត?

[១០:៤០:០២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ធ៖** ក្នុងរយៈពេល១២ថ្ងៃ ១២យប់ហ្នឹង ខ្ញុំដេកគិតផង អង្គុយគិតផង ប្រហែលជាមាននរណាឆ្លើយដាក់ខ្ញុំបានគេយកខ្ញុំមកវាយហ្នឹង គឺខ្ញុំអត់ដឹងទេបាទ។

**ស៖** លោកពូយល់ពាក្យសំណួរ សួរសេ.អ៊ី.អាហ្នឹងមានន័យយ៉ាងម៉េចដែរទេពេលនោះ?

**ធ៖** ពេលនោះខ្ញុំអត់ស្គាល់អារឿង សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងយើងអត់ស្គាល់ ហើយវាឲ្យនិយាយតែរឿង សេ.អ៊ី.អា, កា.ហ្សេ.បេ, សេ.អ៊ី.អា, កា.ហ្សេ.បេ និយាយអីក្រៅពីហ្នឹងអត់បានទេ វាវាយយើង។

**ស៖** ក្រោយពេលលោកពូដេកគិត ថាក្រែងមាននរណាឆ្លើយដាក់លោកពូ ចុះចម្លើយដែលលោកពូសារភាពហ្នឹង តើលោកពូបានឆ្លើយដាក់ទៅលើនរណាផ្សេងខ្លះដែរឬទេ?

**ធ៖** ពេលនោះគឺថាយើងឆ្លើយដាក់ហ្នឹង គឺថាឆ្លើយដាក់ពាសទឹកពាសដីទេ យើងអត់បានថាអ្នូសំដៅអ្នកនេះអ្នកនោះទេ ខ្ញុំនឹកស្មានប្រហែលគេឆ្លើយដាក់ខ្ញុំហើយ។ អ៊ីចឹងខ្ញុំសន្មតថា ខ្ញុំធ្វើត្រូវនិយាយឆ្លើយពាសទឹកពាសដី ដូចគេដូចឯងអ៊ីចឹងដែរបាទ។

**ស៖** ចុះនៅពេលដែលលោកពូឆ្លើយដាក់ឈ្មោះគេឯងនោះ តើអ្នកនោះហ្នឹងជាមនុស្សមែនទែនឈ្មោះរបស់មនុស្សមែនទែន ឬយ៉ាងម៉េចដែរ?

**ធ៖** ពេលនោះ គឺថាយើងអត់ដឹងថាជាមនុស្សមែនទែន ឬមនុស្សមិនមែនទេ គឺថាយើងមិនបានសំដៅថាមនុស្សមែនទែនទេ។ យើងសំដៅថាប្រហែលជាគេឆ្លើយដាក់ខ្ញុំអ៊ីចឹង ខ្ញុំឆ្លើយដាក់ពាសទឹកពាសដីទៅ តែយើងបានសុំទោសគេដែរ។ បើសិនណាខ្ញុំឆ្លើយដាក់ទៅហើយ មានការគេចាប់ពួកអស់ហ្នឹងមកអី យើងសូមអភ័យទោសដល់គេ យើងលើកដៃអំពាវនាវឡើងលើបាទ។

[១០:៤២:២៧]

**ស៖** ចុះនៅពេលដែលលោកពូបានឆ្លើយចម្លើយហ្នឹងហើយ តើគេនៅធ្វើទារុណកម្មលោកលោកពូទៀតទេ?

**ធ៖** ពេលនោះ អាសេង វាមកវាយយើង វាយសួរហើយសួរទៀត សួរហើយសួរទៀត។ ដល់ហើយវាថា អាចុយម៉ាយ អ្អែងបើឆ្លើយអ៊ីចឹងយូរណាស់ អញមិនវាយអ្អែងដល់ប៉ុណ្ណឹងអ្ហេ! ប៉ុន្តែអ្អែងអត់ព្រមឆ្លើយ បាទ។

**ស៖** ក្រោយពេលដែលលោកពូឆ្លើយហើយគេនៅតែបន្តវាយ ឬក៏ធ្វើទារុណកម្មលោកពូទៀតដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាប់ពីថ្ងៃនុ៎ងមក គឺថាអត់មានវាយបន្តទៀតទេក្មួយ។

**ស៖** អ៊ីចឹងឈ្មោះដែលលោកពូឆ្លើយដាក់ហ្នឹង តើលោកពូមានសង្កេតឃើញថាមានគេចាប់មកតាមក្រោយទៀតដែរឬទេ?

**ឆ៖** ខ្ញុំសង្កេតមើលដូចជាអត់មានគេចាប់បន្តមកទៀតទេ ខ្ញុំសង្កេតមើលបាទ។

**ស៖** ចុះក្រៅពីឈ្មោះដែលលោកពូបានឆ្លើយដាក់ហ្នឹង មានអ្នកដែលមិនស្គាល់ឃើញមានគេបញ្ជូនមនុស្សចូលមកតាមក្រោយទៀតដែរទេ?

**ឆ៖** ពេលនោះយើងអត់ដឹងទេ ជម្រាបលោកមេធាវី យើងអត់ដឹងទេ។

[១០:៤៤:០៦]

**ស៖** មុនពេលសម្រាកវគ្គទី១ លោកពូបាននិយាយថាក្រោយពេលគេសាកសួរ ឬក៏គេសួរចម្លើយហើយ គេបានបញ្ជូនលោកពូទៅដាក់នៅបន្ទប់ធំ។ អ៊ីចឹងសំណួរខ្ញុំសួរថានៅក្នុងចម្លើយដែលលោកពូបានឆ្លើយរួចហើយ មុននឹងបញ្ជូនទៅបន្ទប់ធំនោះ តើចម្លើយដែលលោកពូឆ្លើយហ្នឹង គេអានឲ្យលោកស្ដាប់ដែរទេ?

**ឆ៖** គេអត់មានអានឲ្យយើងស្ដាប់អីទេក្មួយ គ្រាន់តែគេឲ្យផ្តិតមេដៃហើយ ហើយៗ។

**ស៖** សូមអរគុណ។ ឥឡូវចូលដល់ក្នុងការឃុំឃាំងលោកពូ ដែលលោកពូថា នៅក្នុងបន្ទប់ធំ តើនៅក្នុងបន្ទប់ធំ នៅក្នុងអគារផ្ទាល់ដី ឬក៏អគារយ៉ាងម៉េច ផ្ទះថ្ម ផ្ទះល្វែង ជាន់ទី១, ទី២ លោកពូអាចជម្រាបបានទេ?

**ឆ៖** អាបន្ទប់ធំហ្នឹង នៅអគារ“សេ” ហ្នឹងដែរក្មួយ ប៉ុន្តែនៅលើនុះ នៅលើអាជាន់លើផុតនោះ។ ពេលនុ៎ង គេដាក់ខ្នោះជើងយើងនៅហ្នឹង គ្នាប្រាំបួននាក់។

**ស៖** សូមសួរលោកពូបញ្ជាក់បន្តិចអគារ“សេ” ហ្នឹងវាស្ថិតនៅទីតាំងកន្លែងឈ្មោះអីកន្លែងហ្នឹងលោកពូ?

**ឆ៖** អគារហ្នឹង គេនិយាយរាប់ពីអគារទី១មក អគារ“អា”, អគារ“បេ”, អគារ“សេ”។

**ស៖** សំណួរខ្ញុំសួរអ៊ីចេះទេ សួរថាតើអគារហ្នឹងស្ថិតនៅក្នុងទីតាំងនៃមន្ទីរមណ្ឌលអី ឬក៏ជាបរិវេណកន្លែងហ្នឹង គេហៅអី ឈ្មោះអី?

**ឆ៖** គេអត់មានបញ្ជូនយើងទៅណាទៀតទេ គេដាក់យើងនៅក្នុងសារមន្ទីរទួលស្លែងហ្នឹង គេហៅ “អគារ-សេ” ហ្នឹង អត់មានបញ្ជូនទៅអគារណាទេ។

[១០:៤៦:១៩]

**ស៖** បាទ សូមអរគុណ។ ឥឡូវអំពីទិដ្ឋភាពនៃការឃុំឃាំងនៅអគារធំ តើនៅកន្លែងហ្នឹង បន្ទប់ហ្នឹង តើមានមនុស្សច្រើនទេដែលដាក់ឃុំជាមួយលោកពូនៅពេលនោះ?

**ឆ៖** នៅពេលនុ៎ង យើងឃើញថា វានៅក្នុងបន្ទប់ហ្នឹងយើងមើលឃើញប្រហែលជា៤០នាក់ បាទ ៤០នាក់ ប៉ុន្តែសុទ្ធតែដាក់ខ្នោះជើង អាខ្នោះវែងៗ នោះក្អួយ ខ្នោះវែងៗនោះ។

**ស៖** តើរបបអាហារ ម្ហូបអាហារ តើគេឲ្យយ៉ាងម៉េចដែរ និងការស្លៀកពាក់ជាដើម តើគេឲ្យផ្ដល់ឲ្យអ្នកទោសយ៉ាងម៉េចដែរ មួយថ្ងៃទៅមួយថ្ងៃ?

**ឆ៖** ពេលនុ៎ងគេលែងឲ្យយើងហូបទឹកបបរទៀតហើយ គេហៅញ៉ាំបបរប៊ុៗ បាទ ញ៉ាំបបរប៊ុៗ ហើយស្លៀកពាក់ធម្មតា ស្លៀកពាក់ខោវែង អាវដៃវែងអីចឹងបាទ។

**ស៖** តើមានឲ្យងូតទឹក ឬមានទឹកផឹកអីគ្រប់គ្រាន់ទេ?

**ឆ៖** ការហូបទឹកហ្នឹង គេឲ្យហូបធម្មតា ប៉ុន្តែបបរនៅតែប៊ុៗអីចឹង បាទហូបធម្មតា។

**ស៖** លោកពូអាចជម្រាបបានទេថា របបដែលគេចែកហ្នឹង បានប៉ុន្មានដែរ បើវាល់ជាវែក ឬជាចាន?

**ឆ៖** បបរទឹកហ្នឹង គេដួសតែមួយវែកទេ ក្អួយ ហើយអាបបរប៊ុៗហ្នឹង ក៏គេដួសតែមួយវែកដែរ ព្រឹកបានមួយវែក ល្ងាចបានមួយវែក តែប៉ុណ្ណឹងទេ។

[១០:៤៨:៣៥]

**ស៖** តើពេលយប់ កន្លែងដែលបន្ទប់ឃុំឃាំងលោកពូ ដែលថាបន្ទប់ធំហ្នឹង គេមានជាមុង ជាភួយ កន្ទេលអីឲ្យលោកពូសម្រាន្តដែរទេ?

**ឆ៖** គេឲ្យយើងដេកនៅនឹងឥដ្ឋហ្នឹង អត់មានមុង អត់មានស្អីទេ ក្អួយ ដេកនៅនឹងឥដ្ឋហ្នឹង។

**ស៖** ចុះមានមូស មានសង្កើច ឬមានកើតចៃអីទេ នៅពេលដែលលោកពូជាប់ឃុំនៅទីនោះ?

**ឆ៖** ពេលនោះយើងកុំនិយាយពីរឿងសង្កើច រឿងពីស្រមោច គិតតែខ្លួនហ្នឹងហើមពេញហ្នឹងតែទាំងអស់ទៅហើយ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត។ ចុះនៅពេលដែលលោកពូបត់ជើងតូច ឬក៏បត់ធំ តើគេអនុញ្ញាតឲ្យលោកពូចាកចេញទៅរកបន្ទប់បត់ជើងតូចធំដែរទេ?

**ឆ៖** គេឲ្យយើងបត់ជើងតូចនៅអាប៊ីដុងហ្នឹង ហើយបត់ជើងធំនៅអាកេសគ្រាប់ហ្នឹង។

**ស៖** តើមានលក្ខខណ្ឌ ឬវិន័យអ្វីទេ នៅចំពោះអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងនោះ?

**ឆ៖** គ្រាន់តែប្រាប់ថា កុំឲ្យនិយាយរកគ្នាតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចូលមកសួរដល់រឿងដែលលោកពូបានទៅធ្វើជាជាង។ តើលោកពូធ្វើយ៉ាងម៉េច បានគេដោះលែងលោកពូឲ្យទៅធ្វើជាជាងនៅក្នុងមន្ទីរឃុំឃាំងទួលស្លែងនោះ?

**ឆ៖** ពេលនុ៎ងមានពួកវាហ្នឹង គឺថាឈ្មោះ សួស ធី ហ្នឹង វាសួរ អាណាចេះជួសជុលម៉ាស៊ីនដេរ នៅពីអូរឫស្សីហ្នឹង អ្អែងចេះជួសជុលម៉ាស៊ីនដេរ អញ ស្អែកយកខោអាវឲ្យអ្អែងស្លៀកពាក់ តែអ្អែងកុំវត់ តែវត់ បាញ់អ្អែងចោលហើយ។

[១០:៥១:១៣]

**ស៖** កន្លែងដែលលោកពូធ្វើការងារជាជាងហ្នឹង តើស្ថិតនៅខាងណានៃបរិវេណដែលលោកពូជាប់ឃុំនោះ?

**ឆ៖** អាកន្លែងជួសជុលម៉ាស៊ីនដេរហ្នឹង នៅខាងក្រោយហ្នឹង គឺថានៅខាងលិចនេះហ្នឹង ខាងលិចអគារដែលយើងជាប់ហ្នឹង នៅខាងក្រោយហ្នឹង គេហៅ អាកន្លែងហ្នឹង មុនដំបូងមានសាលារៀនមួយ សាលាបឋមសិក្សាពញាយ៉ាតហ្នឹងបាទ។

**ស៖** ក្នុងអំឡុងលោកពូដែលចេញទៅធ្វើការខាងក្រៅ លោកពូដែលមានឃើញ ឬក៏បានឮអំពីការធ្វើទារុណកម្មមនុស្សនៅខាងក្នុងដែរទេ?

**ឆ៖** ពេលនោះយើងអត់បានឃើញថា គេធ្វើទារុណកម្មនៅខាងក្នុង អត់បានឃើញ យើងអត់ហ៊ានមើលទេ។ តែគេបញ្ជូនទៅ យើងដើរឈ្ងោកទៅតែម្តង មកវិញ ដើរឈ្ងោកមកតែម្តង។

**ស៖** តើចំពោះអ្នកទោសស្រីៗ និងកុមារ គេដាក់ជាមួយគ្នា ជាមួយនឹងបន្ទប់លោកពូដែរឬទេ?

**ឆ៖** ក្នុងបន្ទប់ហ្នឹង គេដាក់បានតែម្នាក់ទេ ជម្រាបលោកមេធាវី ដាក់បានតែម្នាក់ទេ អត់មានដាក់បានពីរនាក់ទេ បីនាក់ទេ អត់ទេ។

**ស៖** សូមអរគុណ។ សំណួរសូមថយក្រោយបន្តិច នៅពេលដែលលោកពូបញ្ជាក់ថា ពេលបត់ជើងតូច បត់ជើងធំ តើមានការធ្វើទុក្ខបុកម្នេញអ្វីទេ បើមានអ្នកជុះកំពប់ ឬក៏នោមកំពប់អីជាដើម?

**ឆ៖** ពេលនោះកាលណាយើងបត់ជើងធំ កាលណាកំពប់វាឲ្យយើងលិឍ។ បត់ជើងតូចក៏អ៊ីចឹងដែរ កាលណាកំពប់ សើមអី ទទឹកអី វាឲ្យយើងលិឍឲ្យស្អាត។

[១០:៥៣:៣៣]

**ស៖** ចុះចំពោះលោកពូផ្ទាល់ ដែលជួបរឿងបែបហ្នឹងដែរទេ?

**ឆ៖** ខ្ញុំលិឍ បាទ។ ពេលយើងបត់ជើងអត់ចំហ្នឹង វាខ្លាយ យើងលិឍឲ្យស្អាតទៅ។ បើមិនលិឍម៉េច យើងខ្លាចវាវ៉ៃ។

**ស៖** ពាក្យថា "លិឍ" ហ្នឹង លិឍនឹងអណ្តាតលោកពូតែម្តង ឬយ៉ាងម៉េច?

**ឆ៖** លិឍ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! កុំអាល។ទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ជុំ ម៉ី៖**

**ឆ៖** លាមកហ្នឹងដែលខ្លាយពីអាកេសហ្នឹង វាឲ្យយើងលិឍឲ្យស្អាតបាទ។ តែកាលណាលិឍមិនស្អាត វាវ៉ៃយើងទៀត។ ទឹកនោមអ៊ីចឹងដែរ កាលណាយើងលិឍមិនស្អាត វាវ៉ៃយើងទៀត។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ដោយសារពេលវេលាខ្លី ខ្ញុំបាទសូមសំណួរខ្លី១ពីរបីសំណួរទៀតអំពី តើលោកពូធ្វើយ៉ាងម៉េចទើបបានរួចផុតអំពីក្នុងការទុក្ខ ធ្វើទារុណកម្មលោកពូនៅមន្ទីរស-២១នេះ?

[១០:៥៤:៤៧]

**ឆ៖** ខ្ញុំជម្រាបថា ពេលនុំងវាឲ្យយើងទៅជួសជុលម៉ាស៊ីនដេរខាងក្រោយហ្នឹង គឺថាជាងជួសជុលបាន១០គ្រឿង ជួសជុលម៉ាស៊ីនដេរហ្នឹង។ បន្ទាប់មកវាឲ្យយើងជួសជុលអង្គុលីលេខ។ អាអង្គុលីលេខហ្នឹង កាលណាវាវ៉ៃអ្នកទោស វាប្រើអាអង្គុលីលេខហ្នឹង ដល់អាហ្នឹងខូច អត់មានពីណាចេះជួលជុលអាហ្នឹងទេ មានតែខ្ញុំចេះជួលជុលអាហ្នឹង។ អ៊ីចឹងវាឲ្យយើងជួលជុលអាហ្នឹង បានបីគ្រឿងបន្តមកវាឲ្យយើងជួលជុលអាម៉ាស៊ីនបូមទឹកទៀត។

**ស៖** តើលោកបានរួចផុត មានសេរីភាពរស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១នេះដោយរបៀបណាដែរ?

**ឆ៖** ជីវិតខ្ញុំ វាមានពីរចំណុច ជីវិតខ្ញុំ។ អាចំណុចទី១ ដោយសារយើងចេះជួលជុលអាម៉ាស៊ីនអង្គុលីលេខហ្នឹង។ អាម៉ាស៊ីនអង្គុលីលេខហ្នឹងវាសម្រាប់តែវៃអ្នកទោសសួរចម្លើយទេ ដល់អាហ្នឹងខូចទៅ មានតែខ្ញុំទេចេះជួលជុលអាហ្នឹង អ៊ីចឹងវាទុកយើងប្រើសិន។ ទទួលទុកប្រើទៅកងទ័ពរណសិរ្ស និងកងទ័ពវៀតណាមគេមកពីខាងច្បារអំពៅឮសូរកាំភ្លើងគ្រាំៗមក។ ពេលនុ៎ងវាប្រមូលអ្នកទោសចូលមកក្នុងអត់ហើយបាទ។

**ស៖** តើនៅពេលដែលកងទ័ពរណសិរ្ស ឬកងទ័ពវៀតណាមកដល់ហ្នឹង តើលោកពូទៅទីណាទៀត?

[១០:៥៦:៣៥]

**ឆ៖** ពេលនុ៎ងកងទ័ពរណសិរ្សចូលមកដល់ហ្នឹង កងទ័ពរណសិរ្សមិនចូលមកក្នុងទួលស្លែងភ្លាមទេ កងទ័ពរណសិរ្ស គាត់សំដៅទៅផ្សារថ្មីនោះ។ ពួកហ្នឹងដឹងថាកងទ័ពរណសិរ្សទៅផ្សារថ្មី វាប្រមូលពួកខ្ញុំ១៨នាក់ចូលក្នុងអាបន្ទប់ វ៉ាន់ ណាត គូរគំនូរហ្នឹង។ ដល់ហើយអ៊ីចឹងទុកប្រហែលម៉ោងដប់មួយបានវាឲ្យពួកខ្ញុំចេញ អត់មានដាក់ខ្នោះដៃទេ ចេញតែវាភ្ជង់កាំភ្លើងគ្រប់ៗគ្នាតែម្តង ភ្ជង់កាំភ្លើងឲ្យដើរឲ្យត្រង់។

**ស៖** លោកពូចាំបានថ្ងៃណាដែរទេ ថ្ងៃខែណាទេ នៅពេលដែលគេឲ្យពូ ភ្ជង់ឲ្យពូចាកចេញពីមន្ទីរសន្តិសុខស-២១នេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** ថ្ងៃ០៧ មករា ហ្នឹង គឺថាថ្ងៃជីវិតខ្ញុំរស់ៗបានជំនាន់ពេលនុ៎ង កុំមានថ្ងៃ០៧មករា ខ្ញុំអត់បានជួបមុខក្មួយៗទាំងអស់គ្នាទេ គេសម្លាប់ខ្ញុំបាត់ហើយ។ ខ្ញុំវេទនាណាស់។ ស្លាប់គ្រួសារអស់ បងប្អូនប្រាំបីនាក់ សល់តែពីរនាក់ វាសម្លាប់អស់រលីង។

[១០:៥៨:២៣]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងសូមលោកពូជម្រាបជូនលោកប្រធាន និងអង្គជំនុំជម្រះអំពីទុក្ខសោកវេទនាដែលលោកពូជួបប្រទះនៅក្នុងពេលវេលាដែលលោកពូទទួលរងទណ្ឌកម្មនៅក្នុងស-២១ និងការបាត់បង់

សមាជិកគ្រួសារ ឬក៏ប្រពន្ធកូនដែលលោកពូបានមានប្រសាសន៍ជម្រាបជូនអង្គសវនាការនៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

ទំនងជាលោកមេធាវីស្តាប់ការណែនាំរបស់ប្រធានអង្គជំនុំជម្រះមិនបានទេ។ អង្គជំនុំជម្រះជម្រាបហើយថា អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យគាត់ធ្វើដូច្នេះនៅចុងពេលបង្អស់នៃការផ្តល់សក្ខីកម្ម ហើយធ្វើការហ្នឹងដូចយូរហើយ។

[១០:៥៩:១១]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងអ្វីដែលលោកពូបានជួបប្រទះ បន្សល់ទុកពីក្នុងការធ្វើទារុណកម្មនៅមន្ទីរស-២១ មកទល់នឹងពេលនេះ តើនៅក្នុងបេះដូង ឬនៅក្នុងអារម្មណ៍របស់លោកពូ តើលោកពូមានការរំសាយក្នុងចិត្តដែរឬទេ ឬក៏មាននូវការឈឺចាប់យ៉ាងម៉េចដែរទេ មកដល់ថ្ងៃនេះ?

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ប្រើប្រាស់នូវសំណួរនេះ។ យើងដូចប្រាប់ហើយណ៎ា ការថ្លែងទុក្ខសោកវេទនា និងការឈឺចាប់អីៗហ្នឹង គឺរួមគ្នានៅពេលក្រោយបង្អស់ នោះជាយើងជាអ្នកប្រាប់គាត់។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹងលោកពូ នៅក្នុងពេលនេះ ដោយសារពេលវេលាយើងបានមកដល់ពេល ហើយនៅមានភាគីដទៃសួរទៀត តើលោកពូមានសំណួរអ្វី ដែលចង់សួរទៅខាងជនជាប់ចោទតាមរយៈលោកប្រធានដែរទេ?

**ប្រធានអង្គជំនុំ៖**

មិនទាន់ដល់ពេលទេ លោកមេធាវី។ ដូចជា អត់ -- នីតិវិធីយូរហើយ ដូចអត់ទាន់ដឹងរឿងអីសោះ។ យើងឆ្ងល់ណាស់នេះ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអធ្យាស្រ័យ លោកប្រធាន។ ក្រោយពេលដែលលោកបានរួចជីវិតពីមន្ទីរស-២១ តើលោកពូនៅចងចាំបានថា តើមានប៉ុន្មាននាក់ដែលលោកពូស្គាល់ដែលនៅរស់រានមានជីវិតដូចលោកពូដែរទេ?

[១១:០០:៥១]

**លោក ជុំ ម៉ី៖**

**ឆ៖** នៅរស់រានមានជីវិត គឺថាវានៅសល់ប្រាំពីរនាក់ តែក្រោយគាត់ស្លាប់អស់ប្រាំនាក់ហើយ តែឥឡូវនៅសល់តែពីរនាក់ទេ ដូចជា វ៉ាន់ ណាត, ដូចជា អ៊ឹង ប៊ិច ស្អី១ហ្នឹង គាត់ស្លាប់អស់ហើយ។ រាល់ថ្ងៃនៅសល់តែ ប៊ូ ម៉េង ហើយខ្ញុំ សល់តែពីរនាក់ទេ លោកប្រធាន។

**ស៖** ចុះលោកពូ មានចាំឈ្មោះអ្នកដឹកនាំនៅក្នុងមន្ទីរស-២១ហ្នឹង ឈ្មោះអីដែរទេ?

**ឆ៖** មួយជំនាន់នោះយើងស្គាល់តែ អាសេង, អាទិត, អាហ៊ា ហើយនិង អ៊ឹង ប៊ិច តែប៉ុណ្ណឹងទេ មួយជំនាន់នុំង។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកពូដែលបានឆ្លើយជាមួយនឹងសំណួររបស់ខ្ញុំ។ ហើយខ្ញុំបានសូមអរគុណលោកប្រធាន ដែលបានផ្ដល់ឱកាសឲ្យខ្ញុំបាទ។ ខ្ញុំសូមចប់ប៉ុណ្ណេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ ហើយសហព្រះរាជអាជ្ញាគឺមានពេលវេលានៅប៉ុណ្ណេះ ហើយនិងរសៀលនេះ យើងនិងបំពេញបន្ថែមនៃការបាត់បង់ពេលវេលាពីព្រឹកមិញ ៣០នាទីទៀតនៅរសៀលនេះ។

[១១:០២:៣៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក ជុំ ម៉ី។ ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរលោកតាងនាមឲ្យស្ថាប័នសហព្រះរាជអាជ្ញា។ ខ្ញុំឈ្មោះ វ៉ាំងសង់ ឌីវីលដ៍។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំនឹងចាប់ផ្ដើមសួរអំពីទស្សនកិច្ចរបស់លោក ខៀវ សំផន នៅក្នុងរោងកាត់ដេររបស់លោក ដែលលោកបាននិយាយមុននេះបន្តិច។ តើលោកដឹងទេថា លោក ខៀវ សំផន មកធ្វើទស្សនកិច្ចនៅរោងកាត់ដេរហ្នឹង ក្នុងឋានៈជាអ្វី? លោកស្គាល់មុខតំណែងគាត់ទេ នៅពេលនោះ?

**លោក ជុំ ម៉ឺះ**

**ឆ៖** បាទ ជម្រាបលោក ខ្ញុំអត់បានស្គាល់ អត់បានដឹងទេ។ តែខ្ញុំបានសួរអ្នកដាំបាយ គាត់ថា ហ្នឹងហើយលោក ខៀវ សំផន។

**ស៖** តើរោងកាត់ដេរនេះ មានទំនាក់ទំនងអ្វីជាមួយក្រសួងពាណិជ្ជកម្មទេ? ឬក៏មានទំនាក់ទំនងអ្វីជាមួយនឹងគណៈកម្មាធិការសេដ្ឋកិច្ចអ្វីទេ? លោកមានដឹងអំពីចំណុចនេះទេ?

**ឆ៖** ខ្ញុំបាទអត់បានដឹងទេ ដោយសារខ្ញុំជាជាងជួសជុលម៉ាស៊ីនដេរនៅហ្នឹង។ យើងអត់បានដឹងរឿងរ៉ាវអីចឹងៗទេ។

[១១:០៤:២៣]

**ស៖** នៅពេលលោក ខៀវ សំផន មកទស្សនកិច្ច តើលោកមានបានសង្កេតអំពីឥរិយាបថរបស់ប្រធានកង<ដូចជា> គួន និង ជុំ ពួកគេហ្នឹងដូចសម្តែងនូវការគោរពចំពោះលោក ខៀវ សំផន ទេ? យ៉ាងម៉េចដែរនៅពេលនោះ ឥរិយាបថពួកគេចំពោះលោក ខៀវ សំផន នោះ?

**ឆ៖** ខ្ញុំគ្រាន់តែបានសួរអ្នកដាំបាយនុ៎ង អ្នកដាំបាយគាត់ប្រាប់ខ្ញុំថា "ហ្នឹងហើយលោក ខៀវ សំផន មិត្តឯងស្គាល់ទេ? ខ្ញុំថា ខ្ញុំអត់ស្គាល់ទេ"។ ពេលនុ៎ងគាត់មានអង្គរក្សពីរនាក់ដើរតាមក្រោយគាត់។

**ស៖** ពាក់ព័ន្ធនឹងកម្មាភិបាលដែលដឹកនាំអង្គភាពកាត់ដេរ លោកនិយាយអំពីឈ្មោះ គួន, ឈ្មោះ ជុំ និងឈ្មោះ យ៉ុង តើលោកដឹងថា អ្នកទាំងអស់ហ្នឹងត្រូវបានគេចាត់ទុកជាជនក្បត់ ឬក៏បានប្រព្រឹត្តកំហុសអ្វីនៅក្នុងការងាររបស់ខ្លួនទេ?

**ឆ៖** ខ្ញុំបាទមិនបានដឹងថានេះទេ គ្រាន់ថាតែថាយើងបានដឹងថា យ៉ុង ហ្នឹងគាត់ប្រធាននៅហ្នឹង ហើយ គុណ ហ្នឹងគាត់ប្រធាននៅហ្នឹង តែប៉ុណ្ណឹងទេ។

**ស៖** លោកបាននិយាយអំពីការចាប់ខ្លួនរបស់លោក គឺនៅថ្ងៃទី២៨ <ចុងខែ>តុលា ឆ្នាំ១៩៧៨។ តើអ្នកណាជាអ្នកនាំលោកទៅទួលស្លែង? ជាអ្នកមកពីខាងកងកាត់ដេរមកចាប់លោក ហើយនាំលោកទៅ ឬក៏អ្នកមកពីស-២១ តែម្តង ជាអ្នកមកនាំលោកទៅនោះ?

**ឆ៖** គេនាំខ្ញុំទៅហ្នឹងគឺថា មានមិត្តនារីម្នាក់ឈ្មោះ ៗស្អីទេនារីហ្នឹង ខ្ញុំភ្លេចទៅហើយ។ ហើយមួយទៀតគឺថាឈ្មោះ លីន១ មកនាំទៅទួលស្លែងហ្នឹង។

**ស៖** លីន ហ្នឹងជាមេដឹកនាំមួយរូបនៅក្នុងកងកាត់ដេរមែនទេ?

[១១:០៧:២៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** យើងអត់បានដឹងថា គាត់ដឹកនាំ មិនដឹងនាំ យើងអត់បានដឹងទេ គ្រាន់តែឃើញគាត់មកនាំខ្ញុំពីកន្លែងកាត់ដេរហ្នឹងទៅទួលស្លែង ជិះអាឡាំប្រីតាគ្នាបីនាក់ ខ្ញុំ មួយ, មិត្តទឹម មួយ, មិត្ត គុណ មួយ គ្នាបីនាក់ហ្នឹង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ដើម្បីឲ្យច្បាស់នោះ តើ លីន ហ្នឹងគាត់ធ្វើការនៅក្នុងកងកាត់ដេរ ឬក៏លោក នៅពេលដែលគាត់មកចាប់លោកហ្នឹង គឺទើបតែលើកដំបូងហើយដែលលោកឃើញគាត់ហ្នឹង?

**ឆ៖** បាទ ទើបលើកដំបូងទេ ខ្ញុំឃើញគាត់មកបានប្រហែលជាពីរថ្ងៃប៉ុណ្ណឹងទេ។ ហើយគាត់នាំខ្ញុំទៅសារមន្ទីរទួលស្លែងហ្នឹង។

**ស៖** លោកបាននិយាយថា នៅពេលដែលទៅដល់ទួលស្លែងគេចាប់លោកចងដៃ ហើយគេបិទមុខ។ តើលោកមានបានប្រាប់ប្រពន្ធនិងកូនរបស់លោកអំពីការចាប់ខ្លួនទេ ឬក៏លោកប៉ុនប៉ងព្យាយាមធ្វើម៉េចជូនដំណឹងទៅដល់ប្រពន្ធនិងកូនរបស់លោកទេ?

**ឆ៖** ខ្ញុំអត់បានផ្ដែផ្ដាំ -- ខ្ញុំបានផ្ដែផ្ដាំថា ឲ្យសុំជួយមើលកូនប្រពន្ធខ្ញុំផង ហើយយើងដើរមកដល់ពាក់កណ្ដាលថ្នល់ខ្ញុំផ្ដែផ្ដាំអ៊ីចឹង វាធាក់ខ្ញុំមួយជើងដួលផ្កាប់មុខទៅ វាចាប់ទាញសក់ក្បាលឡើង វាជេរខ្ញុំទៀត “អាចុយម៉ាយ អ្អែងនៅផ្ដាំផ្ញើដល់ណាទៀត” វារុញខ្ញុំចូលសារមន្ទីរទួលស្លែងទៅ។

[១១:០៩:៥៧]

**ស៖** ហើយអ្នកដែលជេរឲ្យលោក “អាចុយម្រាយ” ហ្នឹង <តើបុគ្គលហ្នឹងមានប្រាប់លោកទេ? ដូចលោកបាននិយាយនៅក្នុងសវនាការ> កាលពីថ្ងៃទី៣០ មិថុនា ឆ្នាំ២០០៩ គឺឯកសារ <E3/7451> ហ្នឹង <ហើយនៅម៉ោងប្រហែល ៩:២៥នាទី ព្រឹក នៅក្នុងសំណុំរឿង០០១> គឺលោកបានឆ្លើយពាក់ព័ន្ធនឹងចំណុចនេះ។ លោកបានថា៖ “អង្គការនឹងកម្ទេចឯង” សូមបញ្ចប់ការស្រង់នូវចម្លើយរបស់លោក។ ដូច្នេះម្នាក់ដែលជេរលោកហ្នឹង មានបាននិយាយថា “អង្គការនឹងកម្ទេចអ្នកឯងចោលទេ” ពេលនុ៎ង?

**ឆ៖** ពេលនោះគឺថាវានិយាយថា វានឹងកម្ទេចពួកឯងទាំងអស់ហ្នឹង ពួកអាក្បត់ជាតិទាំងប៉ុន្មានវាកម្ទេចចោលទាំងអស់ហ្នឹង។

**ស៖** ការដែលលោកមិនអាចប្រាប់គ្រួសាររបស់លោកឲ្យបានដឹងជាមុនហ្នឹង ធ្វើឲ្យលោកមានការឈឺចាប់ខ្លាំងទេ នៅក្នុងពេលដែលគេឃុំខ្លួនលោកនោះ?

**ឆ៖** ខ្ញុំពេលនោះខ្ញុំមានការឈឺចាប់ខ្លាំងណាស់។ យើងអត់ដឹងថា វាសនារបស់ខ្ញុំទៅជាយ៉ាងម៉េច អីយ៉ាងម៉េច យើងអត់ដឹង បាទ។

**ស៖** នៅពេលដែលគេចាប់ខ្លួនលោកហ្នឹង តើប្រពន្ធរបស់លោកមានផ្ទៃពោះទេ?

**ឆ៖** បាទ ពេលនោះ គឺគ្រួសាររបស់ខ្ញុំមានផ្ទៃពោះ បាទ។

**ស៖** ក្រោយពីគេចាប់ខ្លួនលោក តើលោកព្រួយបារម្ភចំពោះប្រពន្ធ ហើយនិងកូននៅក្នុងផ្ទៃទេ?

**ឆ៖** ពេលនោះខ្ញុំបារម្ភមែនទែន បារម្ភខ្លាំង ដោយសារយើងមិនដឹងស្លាប់ ឬរស់ យើងអត់ដឹង។

[១១:១២:៤៩]

**ស៖** ខ្ញុំដឹងថា គេបិទភ្នែកលោក ក៏ប៉ុន្តែពេលដែលលោកទៅដល់នោះ តើលោកដឹងថា លីនដែលនាំលោកមកនុ៎ង មានបានប្រគល់ឯកសារអ្វី ឧទាហរណ៍ដូចជាប្រវត្តិរូបរបស់លោកមកពីកងរបស់លោកនោះ គាត់មានបានប្រគល់ឯកសារហ្នឹង ទៅដល់អ្នកយាមនៅស-២១ទេ គឺជាឯកសារពាក់ព័ន្ធនឹងលោក ហើយនិងអ្នកពីរនាក់ទៀតដែលគេចាប់ដែរនុ៎ង? <តើលោកដឹងទេថា គេបាន>ប្រគល់ឯកសារអ្វីទៅឲ្យអ្នកយាមទេ<ពេលលោកទៅដល់ ស-២១នោះ>?

**ឆ៖** ពេលនោះ ខ្ញុំអត់បានដឹងទេក្មួយ បាទ។

**ស៖** មុននេះលោកនិយាយថា ពេលលោកទៅដល់ គេថតរូបលោក ក៏ប៉ុន្តែមុន<ពេលថតរូបនោះ>គេ<បាន>សួរសំណួរមួយចំនួន ពាក់ព័ន្ធនឹងប្រវត្តិរូបលោក ដើម្បីចុះឈ្មោះលោកក្នុងបញ្ជី។ តើគេសួរចម្លើយលោកហ្នឹង គេសួរតែឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ដើមកំណើត ជនជាតិអីអីចឹង ឬក៏គេសួរថា លោកមានវណ្ណភាពយ៉ាងម៉េច លោកមានមុខងារ ឬក៏មានមុខរបរអ្វីខ្លះ នៅក្នុងចន្លោះពីឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៨នោះ?

**ឆ៖** ពេលនោះគេអត់មានបានសួរខ្ញុំទេ។ តែរឿងរ៉ាវហ្នឹង គេដឹងរឿងខ្ញុំ ខ្ញុំធ្វើអីៗ គេដឹងអស់ហើយ។

**ស៖** ពេលដែលគេសួរអំពីប្រវត្តិរូបរបស់លោកហ្នឹង លោកនិយាយការពិត ឬក៏លោកកុហក?

**ឆ៖** យើងអត់មានកុហកទេ យើងនិយាយតែការពិតទេ តែយើងកុហកពេលដែលគេវាយសួរចម្លើយខ្លាំងពេកហ្នឹង អាហ្នឹងយើងកុហកគេ ដូចជាឈ្មោះណាៗហ្នឹង អាហ្នឹងយើងកុហកគេ ពីព្រោះវា

ពេលហ្នឹង គឺថាខ្ញុំដូចជាបាត់បង់ស្មារតីអស់ហើយ។

[១១:១៥:៣២]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលក្រោយ។ ឥឡូវនេះខ្ញុំសុំការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញរូបថតពីរ ជូនដើមបណ្ដឹងរដ្ឋប្បវេណី។ រូបថតនេះត្រូវបានថតនៅពេលផ្គុំអង្គហេតុឡើងវិញនៅមន្ទីរស-២១ គឺឯកសារ E3/9431 គឺរូបថតលេខ៤៥ <និងលេខ>៤៦ នៅក្នុងឧបសម្ព័ន្ធទី១ នៃកំណត់ហេតុ។ ខ្ញុំសូមបញ្ជាក់ថារូបថតនេះ ដែលមាននៅក្នុង*ហ្សាយឡេហ*នេះ ជារូបថតសខ្មៅ ក៏ប៉ុន្តែរូបថត<ដើម>នៅក្នុងឯកសារ D86/16ហ្នឹង <> ERN<ភាសាអង់គ្លេស>ហ្នឹងគឺ 00198074 និង75។ ដូច្នេះលោកប្រធានខ្ញុំសុំការអនុញ្ញាតប្រគល់រូបថតនេះជូនដើមបណ្ដឹងរដ្ឋប្បវេណីនិងសូមបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកខាង អេ.វី ចូរបញ្ចាំងនូវឯកសារពាក់ព័ន្ធនឹងសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹង នៅក្នុងអេក្រង់ទូរទស្សន៍។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីនេះគឺរូបថតពីបន្ទប់លេខ២២ តើលោកស្គាល់បន្ទប់ឃុំឃាំងហ្នឹងទេ? <តើនេះជា>កន្លែងហ្នឹងហើយដែលគេឃុំលោកនៅស-២១ នៅពេលដែលគេសួរចម្លើយលោកនោះមែនទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** បន្ទប់គេដាក់អ៊ំហ្នឹង គឺបន្ទប់០២២។

[១១:១៧:៤៣]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីចំណុចមួយ នៅក្នុងរូបថតយើងឃើញមានពន្លឺចាំងមកពីខាងក្រៅ។ អ៊ីចឹងនៅពេលដែលគេឃុំលោកនៅសម័យនោះ តើមានបង្អួចបើក ហើយមានខ្យល់ មានពន្លឺចូលមកទេ ឬក៏បន្ទប់នោះគឺងងឹតស្លុងតែម្ដង?

**ឆ៖** បន្ទប់នេះ ពេលដែលនេះហ្នឹង គឺថាគេបិទជិតឈឹងតែម្ដង អត់មានពន្លឺថ្ងៃចូលទេ អត់មានពន្លឺថ្ងៃចូលទេ។

**ស៖** មុននេះលោកថាលោកសម្រាកផ្ទាល់នឹងដី ហើយគេដាក់ខ្នោះជើងលោក ហើយលោកហូបមិនបានគ្រប់គ្រាន់ ហើយផឹកទឹកបានបន្តិចបន្តួច។ អ៊ីចឹងក្នុងរយៈពេលដែលគេសួរចម្លើយលោក

១២ថ្ងៃនោះ តើលោកអាចសម្រាន្តលក់ដែរ<ទេ? តើលោកមានពេលដើម្បីសម្រាកយកកម្លាំងទេ ចន្លោះពីការសួរចម្លើយមួយទៅការសួរចម្លើយមួយ>នោះ?

**ឆ៖** យើងអត់មានកម្លាំងទេ ពេលនោះយើងហត់ហេវ ណាមួយហូបអត់គ្រប់គ្រាន់ ណាមួយយើងដេកនៅនឹងឥដ្ឋ ព្រោះអាដេកនៅនឹងឥដ្ឋហ្នឹងហើយដែលវាខ្សោះយើង វាអត់នេះ អត់មាននេះ វាខ្សោះយើង ម្ល៉ោះហើយយើងអត់កម្លាំងទេ។

**ស៖** ពាក់ព័ន្ធនឹងបញ្ហាអនាម័យ <លោកនិយាយថា លោកស្លៀកតែខោទ្រនាប់រហូតក្នុងអំឡុងពេលនោះ> ខ្ញុំចង់សួរលោកថា តើគេចងលោករហូតអ៊ីចឹង តើលោកអាចងូតទឹកអី លាងខ្លួនអីបានទេ?

**ឆ៖** ការងូតទឹកខ្ញុំជាប់រយៈ៤ខែ ១២ថ្ងៃហ្នឹង យើងបានគេបាញ់ទឹកឱ្យតែមួយម្តងទេ។

[១១:២០:០៥]

**ស៖** គេជះទឹកហ្នឹង គឺគេយកធុងមកដងទឹក ហើយគេជះទៅលើលោក ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលគេយកធុងទឹកមកដល់ហ្នឹង គេឱ្យយើងស្រាតខោខ្លីហ្នឹងចេញ ហើយយើងស្រាត យើងស្រាតចេញអត់រួច ខោខ្លីហ្នឹង យើងស្រាតចេញអត់រួច ព្រោះយើងវាជាប់ខ្នោះ។ អ៊ីចឹងវាឱ្យយើងបន្តិចចេញតាមអានេះខ្នោះហ្នឹង បន្តិចចេញបន្តិចៗទៅ កុំឱ្យវាទទឹកខោហ្នឹង ដាក់ខោឡើងលើទៅ។ អាហ្នឹង ខ្ញុំត្រូវប៉ុន្មានរំពាត់ដែរ ប៉ុន្តែខ្ញុំអត់រាយការណ៍ជូនឯកឧត្តមទេ គឺថាដោយសារយើងស្រាតខោអត់ចេញ ដល់វាបង្ហាញ វារ៉ៃ។

**ស៖** ដូច្នេះជារួម<ស្ថានភាពឃុំឃាំង>ក្នុងរយៈពេល១២ថ្ងៃហ្នឹង គឺលោក<និយាយថា លោកស្លៀកតែខោទ្រនាប់មួយ ហើយលោក>ដេកនៅលើកម្រាលឥដ្ឋ គេ<>ដាក់ខ្នោះ<ជើង> ហើយគ្មានពន្លឺ គ្មានអី <គ្មានអនាម័យ> ហើយហូបចុកមិនគ្រប់គ្រាន់។ អ៊ីចឹងការឃុំខ្លួនបែបហ្នឹង គឺថាវាជាការបន្ទាប បន្ថោកតម្លៃមនុស្សទេ? ហើយធ្វើឱ្យលោកមានអារម្មណ៍ភ័យខ្លាចជាប់ជាប្រចាំទេ?

**ឆ៖** យើងភ័យណាស់ យើងបារម្ភចេះតែនឹកភ័យ ខ្ញុំមិនដឹងថ្ងៃណានឹងស្លាប់ ទោះបីគេមិនសម្លាប់ឱ្យតែជាប់នៅហ្នឹងយូរក៏ត្រូវតែស្លាប់ដែរ។

**ស៖** ចាប់ពីពេលដែលលោកចូលទៅស-២១ រហូតដល់ពេលលោករត់ចេញនៅពេលដែលវៀតណាមវ៉ៃចូល តើគេធ្លាប់ប្រព្រឹត្តចំពោះលោក ក្នុងនាមលោកជាមនុស្សទេ? មានការគោរពសេចក្តីថ្លៃថ្នូរជាមនុស្សរបស់លោកទេ?

**ឆ៖** ពេលនោះគេទុកយើងជាជនក្បត់ជាតិ គឺថាគេទុកយើងប្រៀបដូចជាសត្វអ៊ីចឹង ប្រៀបដូច

ជាសត្វអ៊ីចឹង។ ទាំងការហូបចុក ទាំងការនិយាយស្តីស្អី។ គឺថាគេ គឺថាយើងអត់មានសិទ្ធិសេរីភាពអីនិយាយរកគ្នាទេ។

[១១:២៣:២៦]

**ស៖** ឥឡូវនេះខ្ញុំចូលទៅសួរអំពីការសួរចម្លើយ និងការធ្វើទារុណកម្មលោក។ លោកថា គេសួរលោករហូត ថាខ្មែរអ្នកណាខ្លះ មានជាប់ពាក់ព័ន្ធនឹងពួក សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ យ៉ាងម៉េចខ្លះ? អ៊ីចឹងខ្ញុំចង់ដឹង ថាតើអ្នកសួរចម្លើយហ្នឹងធ្លាប់បានប្រាប់លោក ពន្យល់លោក ថាតើពាក្យ "សេ.អ៊ី.អា" ពាក្យ "កា.ហ្សេ.បេ" ហ្នឹងមានន័យយ៉ាងម៉េចទេ? គេមានបានបង្ហើបប្រាប់លោកអំពីនិយមន័យនៃពាក្យហ្នឹង ដើម្បីឱ្យលោកអាចឆ្លើយទៅនឹងសំណួររបស់គេបានទេ?

**ឆ៖** គេអត់មានប្រាប់យើងថា យើងដឹងរឿង សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងយ៉ាងម៉េច អីយ៉ាងម៉េច គេអត់មានប្រាប់យើងទេ។ ក្រោយមកបានយើងដឹងថា គេចង់ដឹងអារឿង សេ.អ៊ី.អា, កា.ហ្សេ.បេហ្នឹង សេ.អ៊ី.អា ហ្នឹងថាយកព័ត៌មានឱ្យអាមេរិកកាំង កា.ហ្សេ.បេហ្នឹង ថាយកព័ត៌មានឱ្យសូវៀត។ យើងដឹងមកពេលអាយើងរួចហើយ យើងចេះតែសួរគេ សួរឯងទៅ អាហ្នឹង។

**ស៖** ក្នុងពេលសួរចម្លើយ គេមានសង្ស័យថា លោកមានជាប់ខ្សែ ឬក៏ជាប់ពាក់ព័ន្ធអីជាមួយនឹងយួនទេ?

**ឆ៖** ពេលនោះយើងអត់មានដឹងថា ជាប់ខ្សែចង្វាក់អីជាមួយយៀកណាមស្អី។ យើងអត់ដឹងទេបាទ។

**ស៖** អ្នកណាជា<អ្នក>សួរចម្លើយលោកក្នុងរយៈពេល១២ថ្ងៃ ហើយនិងធ្វើទារុណកម្មលោកនោះ?

**ឆ៖** ពេលនោះគឺខ្ញុំមិនដឹងពីណាមេ ពីណាកោយអី យើងអត់ដឹងទេ។ ដឹងថា កាំង ហ្កេកអ៊ាវ ហៅ ឌុច ហ្នឹងគឺថានៅទួលស្លែង មេនៅទួលស្លែងហ្នឹង។ ហើយអ្នកវ៉ៃខ្ញុំហ្នឹង គឺថា អាសេង, អាទិត, អាហ៊ា បីនាក់ហ្នឹង។

[១១:២៦:២៥]

**ស៖** ខ្ញុំចង់ដឹងហ្នឹង គឺអ្នកណាអ្នកសួរលោក អ្នកវ៉ៃលោកហ្នឹងហើយ ហើយអ្នកបកប្រែអម្បាញ់មិញហ្នឹង ស្តាប់ឈ្មោះដែលលោករៀបរាប់នុ៎ង មិនទាន់ទេ។ អ៊ីចឹងសូមលោករៀបរាប់ម្តងទៀតមើលអ្នកដែលសួរ ហើយវ៉ៃលោកហ្នឹង ឈ្មោះអ្វីខ្លះ?

**ឆ៖** អ្នកដែលវ៉ៃខ្ញុំ ដំបូងហ្នឹងគឺថាឈ្មោះវា អាសេង។ អាសេង វ៉ៃមួយថ្ងៃពីរទៅ បានឃើញ លេច អាទិត មក។ វ៉ៃសួរចម្លើយអ៊ីចឹងរហូតទៅ អាចុងបញ្ចប់នេះ អាទិត ហ្នឹងវាថា "បងអ្អែងមើល! (ប្រាប់ អាហ៊ី) វាថា បងអ្អែងមើល! វាអត់ព្រមអត់អីទេ" ពេលនោះ អាហ៊ី ទាញរំពាត់ក្រាកមក វ៉ៃខ្ញុំ ផូង១១ បាក់រំពាត់ វាក្រវាត់ចោល។ វាដើរចេញ វាថា អាចុយម៉ាយ អ្អែងមិនឆ្លើយអ្ហ!។ វាដើរចេញទៅ អាហ៊ី ហ្នឹង។

**ស៖** ក្រោយពីគេវ៉ៃលោករួចមកហើយនោះ លោកបាននិយាយថា លោកបាក់ម្រាមដៃទៀត។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលគេវ៉ៃលោកហ្នឹង លោកមានរបួសស្នាមអីទេ? ហើយពេលដែលមានរបួស ស្នាមអ៊ីចឹង តើមានពេទ្យនៅ ស-២១ ហ្នឹង គេព្យាបាលលោកទេ?

**ឆ៖** បាទ នៅ ស-២១ អត់មានពេទ្យព្យាបាលទេ ជម្រាបលោកព្រះរាជអាជ្ញា អត់មានពេទ្យ ព្យាបាលទេ។

**ស៖** តើ សេង ដែលជាអ្នកសួរចម្លើយហ្នឹង មានបានអង្គុយលើក្បាលលោកទេ ពេលសួរនោះ?

[១១:២៨:៣០]

**ឆ៖** ពេលនោះវាអង្គុយលើក្បាល ហើយវាយកអាវរំពាត់ហ្នឹង វ៉ៃក្បាលជង្គង់ខ្ញុំ។ អាចុយម៉ាយ អ្អែងមិនឆ្លើយ។ បាទ វាថាអ៊ីចឹង។

**ស៖** ក្នុងវប្បធម៌ខ្មែរនេះ តើអ្នកណាម្នាក់អង្គុយលើក្បាលអ្នកណាអ៊ីចឹង វាជារឿងមួយដែលគួរ ឲ្យអាម៉ាស់ទេ?

**ឆ៖** ចំពោះវប្បធម៌ខ្មែរហ្នឹង គឺថាជម្រាបលោកព្រះរាជអាជ្ញា គេប្រកាន់ណាស់រឿងក្បាលហ្នឹង គេប្រកាន់ណាស់ ខ្មែរយើងមិនឲ្យពីណាអង្គុយលើក្បាលអ៊ីចឹងទេ។

**ស៖** ពាក់ព័ន្ធនឹងការដែលគេដកក្រចកជើងលោក តើលោកអាចបញ្ជាក់បានទេ គឺថាគេដក ក្រចកជើងណាខ្លះ? ដកមេជើងទាំងពីរ ឬក៏ដក<>ម្រាមជើងណាខ្លះ ពីព្រោះថានៅក្នុងការបកប្រែហ្នឹង យើងស្ដាប់ដូចជាមិនសូវច្បាស់?

**ឆ៖** ការដកក្រចកជើង គឺថាវាដកទាំងពីរ ប៉ុន្តែអាមួយវាដុះមក វាអត់មាន វាអត់នេះទេ ដុះមក ស្អាតតែម្ដង។ បើអាមួយ ដុះមកអត់ស្អាតតែម្ដង។

**ស៖** លោកបានបង្ហាញ<ក្រចក>ជើងរបស់លោកក្នុងសវនាការនៃសំណុំរឿង០០១ផងដែរ។ អ៊ីចឹងក្រោយ ពីគេដកក្រចកជើងហ្នឹង គេមានបានយកថ្នាំ ឬក៏យកអាល់កុលអីមកលាប ដើម្បីកុំឲ្យឆ្លង ឬ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏ក្លាយទេ?

**ឆ៖** បាទ វាគ្រាន់តែយកអាល់កុលមកចាក់តែប៉ុណ្ណឹងទេ អត់មានលាបថ្នាំលាបអីទេបាទ។

[១១:៣១:៣០]

**ស៖** ពេលគេចាក់អាល់កុលលើសាច់ ដែលគេដកក្រចកជើងលោកហើយហ្នឹង តើលោកឈឺចាប់ស្អីខ្លាំង លោកស្រែកទេ? <តើលោកចាំថា វាឈឺចាប់ប៉ុនណាទេ?>

**ឆ៖** ជាពេលនោះ យើងអត់ហ៊ានស្រែកខ្លាំងទេ យើងខ្លាចវាវ៉ៃថែម យើងអត់ហ៊ានស្រែកទេ យើងសុខចិត្តធ្មេចភ្នែកខាំមាត់យើង។

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីការឆក់ខ្សែភ្លើង <និងផលប៉ះពាល់ក្រោយពីនោះ> ផងដែរ ហើយលោកមានស្នាមទៀត។ <ពាក់ព័ន្ធនឹងការឈឺចាប់ ដែលពិបាកខ្លាំងណាស់សម្រាប់លោកទ្រាំទ្រ> អ៊ីចឹងខ្ញុំចង់ដឹងថាតើគេដកក្រចកជើង ហើយនិងដោយមិនមានដាក់ថ្នាំសណ្តំ ឬក៏ថ្នាំអីអ៊ីចឹង ហើយនិងការឆក់ខ្សែភ្លើងនេះ តើមួយណាវាឈឺចាប់ជាង?

**ឆ៖** ជម្រាបប្រាប់លោកព្រះរាជអាជ្ញា ការឈឺចាប់ឆក់ខ្សែភ្លើងហ្នឹងវាឈឺចាប់ភ្លាម វាឈឺចាប់ខ្លាំង ទាល់យើងសន្លប់អត់ដឹងខ្លួនចំនួនពីរដង សន្លប់ពីរដងអត់ដឹងខ្លួន។

**ស៖** ក្រៅពីការវាយដំ ការដកក្រចកជើង ការឆក់ខ្សែភ្លើងហ្នឹង តើលោកឈឺចាប់ក្នុងផ្លូវចិត្តទេ ក្នុងអំឡុងពេលដែលគេឃុំខ្លួននោះ? <បើឈឺចាប់ តើ>លោកអាចរៀបរាប់<បានទេ?> តើ<នៅពេលនុ៎ង>លោកគិតយ៉ាងម៉េច ថាតើថ្ងៃអនាគតវានឹងយ៉ាងម៉េច?

**ឆ៖** ពេលនោះយើងមានការឈឺចាប់ខ្លាំងណាស់បាទ ឈឺចាប់ខ្លាំងមែនទែន។ យើងនឹកថាខ្ញុំទៅថ្ងៃក្រោយ ខ្ញុំនឹងជម្រាបប្រាប់ពិភពលោកឲ្យគេបានដឹងការពិត។

[១១:៣៥:១៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី និង -- ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះសាក្សី -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី អង្គជំនុំជម្រះមានបញ្ហាពីរដែលត្រូវជម្រាបជូនដំណឹងដល់ភាគី។ ទី១ ដោយសារតែអង្គជំនុំជម្រះកំពុងរង់ចាំរបាយការណ៍ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពាក់ព័ន្ធនឹងសាក្សី 2-TCW-865 ហេតុដូច្នេះអង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មសាក្សី 2-TCW-865 បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី នោះបានទេ។ ហើយអង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីនូវការបរិច្ឆេទជាក់លាក់នៃការស្តាប់សក្ខីកម្មសាក្សី 2-TCW-865 ហើយនៅពេលបន្ទាប់ពីនោះ ពីបានទទួលនូវរបាយការណ៍ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ហើយនៅថ្ងៃនេះ បើសិនជាបានសវនាការចប់មុនពេលកំណត់នោះ គឺមិនមានសាក្សីបម្រុងទេ។ ហើយថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងចាប់ផ្តើមសក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-919។ ទី២ កាលពីព្រឹកមិញនេះ អង្គជំនុំជម្រះបានទទួលនូវសំណៅនៃសំណើសុំដែលបានជូនដំណឹងមកអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែលរបស់សហមេធាវីការពារក្តី នួន ជា ស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួនប្រាំបី ពាក់ព័ន្ធនឹងសាក្សី 2-TCW-919 ដែលត្រូវបានត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែក ហើយព្រមទាំងសំណើសុំឲ្យសាក្សី 2-TCW-919 ផ្តល់នូវសំណៅនៃសៀវភៅនិពន្ធដែលខ្លួនមាន ហើយស្នើសុំឲ្យទទួល

យកសៀវភៅនេះជាភ័ស្តុតាង។ ហើយមុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-919 នៅថ្ងៃស្អែក អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់មាត់ភាគី លើសំណើសុំនេះនៅពេលព្រឹកនៅមុនពេលស្តាប់សក្ខីកម្មសាក្សី 2-TCW-919។ ហេតុនេះសូមភាគីជម្រាប។

ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី។

[១៣:៣៦:៣៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណ។ ជម្រាបសួរលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ លោកសាក្សី មុនពេលសម្រាក យើងបាននិយាយអំពីការធ្វើទារុណកម្ម ដែលលោកបានទទួល ហើយនិងការឈឺចាប់របស់លោក។ ហើយលោកបាននិយាយផងដែរអំពីការដែលលោកបានជួបលោក ខៀវ សំផន តាមរយៈគេនិយាយប្រាប់លោកនៅក្នុងជាងដែលលោកធ្វើការ។ ឥឡូវខ្ញុំៗសំណួរទៅលោកទាក់ទងនឹង នួន ជា ម្តង។ តើនៅពេលចន្លោះឆ្នាំ១៩៧៥ និងដល់ឆ្នាំ១៩៧៩ លោកធ្លាប់បានឃើញ ឬក៏ជួបលោក នួន ជា ដែរឬទេ នៅក្នុងឱកាសណាមួយនោះ?

**លោក ជុំ ម៉ី៖**

**ឆ៖** នៅពេលនេះ យើងសុំជម្រាបលោកព្រះរាជអាជ្ញា គឺថា ខ្ញុំបានទៅចូលរួមនៅក្នុងបុរីកីឡា គឺថា នួន ជា គាត់បានហៅកម្មករកាត់ដេរហ្នឹងទៅចូលប្រជុំនៅបុរីកីឡាហ្នឹងថា សមមិត្តណាមិនទាន់ជ្រះស្រឡះពីពួកចក្រពត្តិ សូមរាយការណ៍ជូនអង្គការ អង្គការនឹងលើកលែងទោសឲ្យ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើលោកបានចូលរួមក្នុងកិច្ចប្រជុំនោះនៅពេលណា ជាមួយនឹងកម្មករផ្សេងទៀតនោះ? តើ<>កម្មករ<ទាំងនោះមកពី>ទីក្រុងភ្នំពេញនេះ ឬក៏កម្មករមកពីកន្លែងផ្សេង? ហើយសូមជម្រាបពេលវេលាផង ចូលរួមប្រជុំនោះពេលណាដែរ?

**ឆ៖** ខ្ញុំបានចូលរួមប្រជុំហ្នឹង ជាមួយកម្មករកាត់ដេរនៅក្នុងផ្សារអូរឫស្សីហ្នឹង គេឲ្យមកស្តាប់ នួន ជា គាត់និយាយប្រកាសអ៊ីចឹង។ ហើយឲ្យខ្ញុំចាំថ្ងៃខែនុ៎ង ខ្ញុំមិនបានចាំទេ បាទ។

[១៣:៣៩:១៧]

**ស៖** តើនៅពេលនោះៗ លោកនៅក្នុងជិតផ្សារអូរឫស្សីនៅក្នុងកងកាត់ដេរ ឬក៏យ៉ាងម៉េច ដែល

គេហៅគ-៩? ពេលហ្នឹងហើយគឺជាពេលដែលលោកជួសជុលម៉ាស៊ីនកប៉ាល់អី ម៉ាស៊ីនកាណូតអីហ្នឹង ណា ពេលហ្នឹងមែនទេ?

**ឆ៖** ជួសជុលម៉ាស៊ីនកាណូត កប៉ាល់ ខ្ញុំជួសជុលនៅឫស្សីកែវ ឃ្លាតគ្នាប្រហែលជា៨គីឡូ ជួសជុលនៅឫស្សីកែវ។ តែរឿងជួលជុលម៉ាស៊ីនដេរ កាត់នៅនឹងផ្សារអូរឫស្សី។

**ស៖** នៅពេលដែលលោកចូលរួមក្នុងកិច្ចប្រជុំនោះ ពេលដែល នួន ជា បាននិយាយនោះ អង្កាល់នោះលោកបានមកធ្វើការនៅកន្លែងកាត់ដេរហើយ ដែលកាលនោះលោកជាអ្នកជួសជុលម៉ាស៊ីនដេរហើយ ឬក៏កាលដែលលោកចូលរួមប្រជុំនោះ គឺមុនពេលដែលលោកមកកន្លែងកាត់ដេរហ្នឹងទៅទៀត?

**ឆ៖** ពេលដែលយើងមកប្រជុំហ្នឹងគឺថា យើងនៅកន្លែងកាត់ដេរហ្នឹង។ កាត់ដេរហ្នឹងគឺថា អង្គភាពកាត់ដេរហៅថា “គ-៩”។

**ស៖** សូមអរគុណ។ សូមត្រឡប់មកនិយាយពី<អ្វីដែល> នួន ជា និយាយមកកាន់លោក<នៅថ្ងៃនោះ>វិញ។ អម្បាញ់មិញនេះគឺលោកទំនងជាបាននិយាយថា គាត់បានសូមឱ្យអ្នកដែលចូលរួមប្រជុំទាំងអស់គ្នានុ៎ងប្រាប់ឈ្មោះរបស់ខ្លួន។ តើលោកអាចជម្រាបជូនតុលាការម្តងទៀតបានទេថា គាត់បានសន្យាអ្វីខ្លះទៅអ្នកចូលរួមប្រជុំនុ៎ង? តើគាត់មានបានសូមឱ្យមនុស្សមួយចំនួនលើកដៃឡើង<លើទេ? តើគាត់សុំឱ្យគេធ្វើអ្វីឱ្យប្រាកដទៅ?> ខ្ញុំ<មិនសូវ>យល់<ចំណុចនេះទេ>? សូមលោកជួយនិយាយម្តងទៀតបានទេ?

[១៣:៤១:៥២]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់លោក ជុំ ម៉ី!

**លោក ជុំ ម៉ី៖**

**ឆ៖** ពេលនោះគឺយើងឃើញថាគេលើកដៃ គេថាគេមិនមានការពាក់ព័ន្ធនឹងពួកចក្រពត្តិទេ គេគ្រាន់តែនិយាយប៉ុណ្ណឹង កម្មករទាំងអស់ហ្នឹង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើ នួន ជា មានបាននិយាយអ្វីខ្លះដែរអំពីអ្នកដែលមានទំនាក់ទំនង ឬក៏ពាក់ព័ន្ធជាមួយពួកចក្រពត្តិហ្នឹង?

**ឆ៖** នួន ជា គាត់និយាយប្រាប់ថាសមមិត្តណា បើមិនទាន់ជ្រះស្រឡះពីពួកចក្រពត្តិ សូមឱ្យ

រាយការណ៍ជូនបក្ស ៗនឹងលើកលែងទោសឲ្យ។

**ស៖** តើលោកអង្គាល់ណោះ លោកយល់ថា<នោះជាការអំពាវនាវឲ្យប្រជាជនប្ដឹងកម្មាភិបាល បាលមួយចំនួន ដែលមិនបានផ្ដាច់ខ្លួនពួកគេចេញពី>ចក្រពត្តិ<ដែរ>ទេ?

**ឆ៖** ខ្ញុំមិនបានឮអ្នកអស់នោះ ដើម្បីរាយការណ៍ជូនអង្គការទេ ព្រោះពេលចេញពីប្រជុំមកវិញគឺ ថាគេទៅតាមផ្នែកគេផ្សេងៗ។

[១៣:៤៤:០៥]

**ស៖** ខ្ញុំសូមផ្អាកត្រឹមនេះទាក់ទងនឹងប្រធានបទនេះ ដោយសារពេលវេលាទៅមុខ។ ឥឡូវខ្ញុំសូម មកនិយាយអំពីមន្ទីរស-២១ គឺនៅពេលដែលលោកទ្រាំលែងបានហើយ ៗលោកសារភាព<នូវអ្វីដែល លោកនិយាយថាលោកមិនបានធ្វើ>។ <>យើងបាននិយាយអំពីទុក្ខវេទនារបស់លោក <ហើយយើង បាននិយាយអំ>ពី<ការ>ធ្វើទារុណកម្មលោក។ តើមានកត្តាអ្វីខ្លះដែលជំរុញឲ្យលោកសារភាពថា លោកនៅក្នុង សេ.អ៊ី.អា? <>លោក<ប្រាប់យើងថាការឆ្លើយសារភាពនោះ>វាខុសទាំងស្រុង <ប៉ុន្តែ> តើ<អ្វីដែល>បង្ខំឲ្យលោកសារភាពយ៉ាងដូច្នេះបាន<នៅពេលមួយនោះ>?

**ឆ៖** បញ្ហានេះ គឺថាវាមានរឿងរ៉ាវច្រើនណាស់ដែលបង្ខំឲ្យខ្ញុំឆ្លើយដាក់គេដាក់ឯងអ៊ីចឹង។ គឺទី១ គឺវាវ៉ៃសួរចម្លើយ ដល់ហើយខ្ញុំវ៉ៃឈឺខ្លាំងពេក ខ្ញុំយកដៃរង អ៊ីចឹងបាក់អាកូនដៃនេះបាទ បាក់កូនដៃ ហ្នឹង អាថ្ងៃទី១។ ដល់អាថ្ងៃទី២ វាដកអាក្រចកជើងយើង អាក្រចកមេជើងយើងហ្នឹងមួលក្រដាច់ វាកន្ត្រាក់ៗ ឲ្យដាច់។ ហើយអាលើកទី៣វាឆក់ខ្សែភ្លើង ដាក់ខ្សែភ្លើងចូលរន្ធត្រចៀកយើងហ្នឹង ញ៉ាត់ឆាច់ ប៊ឹង អ៊ីចឹង យើងបែកអំពិលអំពែកទៅ យើងសន្លប់អត់ដឹងខ្លួនទេ ពេលហ្នឹងយើងអត់ដឹងខ្លួនអីទាំងអស់។ អ៊ីចឹងខ្ញុំ ម្ខាងហ្នឹងខ្ញុំពិការរហូត គឺថាអាភ្នែកនេះ មើលអត់ឃើញទេ ឃើញព្រិលៗ។ ស្លឹកត្រចៀកនេះ គោះអ៊ីចឹង ដូចទឹកចូលអ៊ីចឹង ទីងៗ ដូចទឹកចូលអ៊ីចឹង។ ម្ខាងប្រើការអត់កើតទេ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ បើពុំមានការធ្វើទារុណកម្ម ហើយនិងលក្ខខណ្ឌ<ធ្ងន់ធ្ងរ>ទេ គឺ<> លោកមិនសារភាពទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

[១៣:៤៦:៣៣]

**ឆ៖** បាទ ខ្ញុំបាទយល់អ៊ីចឹងដែរ ដូចប្រសាសន៍លោកព្រះរាជអាជ្ញាមានប្រសាសន៍អ៊ីចឹង។

**ស៖** នៅក្នុងរឿងរ៉ាវដែលលោកឆ្លើយទៅអ្នកសួរចម្លើយលោកនោះ តើមានព័ត៌មានខ្លះមួយចំនួន ហ្នឹងពិត ហើយមួយចំនួនទៀតមិនពិតដែរឬទេ? ហើយបើអ៊ីចឹងមែន តើការពិតណាខ្លះ លោកបានប្រាប់

ទៅអ្នកសួរចម្លើយលោក ហើយការមិនពិតណាខ្លះ ដែលលោកប្រឌិតប្រាប់ទៅគេ?

**ឆ៖** ការដែលខ្ញុំឆ្លើយការពិតមួយចំនួន ហើយឆ្លើយការមិនពិតនោះមួយចំនួន។ មួយចំនួនដែលវាវ៉ៃខ្ញុំឲ្យខ្ញុំឆ្លើយថាខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹង អាហ្នឹងគឺថាមិនមែនពិតទេ ព្រោះខ្ញុំអត់ដែលស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងទេ។ ដល់វាវ៉ៃខ្លាំងពេក ដាក់ខ្សែភ្លើងខ្លាំងពេក ម្ល៉ោះហើយខ្ញុំទ្រាំអត់បាន ខ្ញុំចេះតែឆ្លើយទៅដែរ។

**ស៖** ដើម្បីបំភ្លឺ នៅក្នុងឯកសារ E3/5163 ជាចម្លើយដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនៅទំព័រទី២ ជាបីភាសាតែម្តង។ លោកនិយាយដូចតទៅនេះ គេបានបង្ហាញចម្លើយសារភាពរបស់លោក លោកឆ្លើយប្រាប់ថា៖ “ហ្នឹងហើយ ពិតជាចម្លើយសារភាពរបស់ខ្ញុំ ខ្ញុំនៅចាំច្បាស់ណាស់រឿងរៀបរាប់ទាំងអស់នេះ ពិតខ្លះ មិនពិតខ្លះ។ ហើយទាក់ទងទៅនឹងការងារដែលខ្ញុំបានធ្វើបន្តបន្ទាប់មកហ្នឹងជាការពិត ក៏ប៉ុន្តែអ្វីដែលខ្ញុំនិយាយទាក់ទងទៅនឹងការធ្វើវិទ្ធង្សនា ហើយនិងការដែលខ្ញុំជាភ្នាក់ងារ សេ.អ៊ី.អា ហើយនិងបណ្តាញក្បត់អ្វីទាំងអស់នោះ គឺមិនពិតទេ <ទាំងអស់នេះគឺជាការប្រឌិត>។ សំណួរដែល<>សួរខ្ញុំមិនចេះចប់មិនចេះហើយ<គឺ> ថាតើខ្ញុំ<ជាសមាជិក> សេ.អ៊ី.អា ឬកា.ហ្សេ.បេ ដែរឬទេ<> ខ្ញុំដើម្បីឲ្យគេឈប់វ៉ៃខ្ញុំ ខ្ញុំឆ្លើយថា បាទ។” តើលោកបញ្ជាក់បានដែរឬទេថា ទាក់ទងនឹងប្រវត្តិការងាររបស់លោក ហើយនិងព័ត៌មានទាក់ទងទៅនឹងគ្រួសាររបស់លោកគឺជាការពិត ហើយទាក់ទងទៅនឹងបណ្តាញក្បត់បណ្តាញអីជាដើមនោះ គឺមិនពិតទេ។ លោកអាចបញ្ជាក់ជូនតុលាការបានដែរឬទេ?

[១៣:៤៩:២៨]

**ឆ៖** បាទ អាកន្លែងត្រង់ណោះ ដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹងថា ខ្ញុំមិនបានឆ្លើយនេះទេ គឺថាឆ្លើយហ្នឹង គឺថាខ្ញុំប្រឌិតឡើង ដើម្បីដោយសារគេឆក់ខ្សែភ្លើងខ្លាំងពេក ខ្ញុំទ្រាំអត់បាន ម្ល៉ោះហើយខ្ញុំចេះតែឆ្លើយទៅបាទ។ ត្រង់ហ្នឹងហើយ ដែលពួកវាសួរទៅខ្ញុំថា អើបើអ្អែងឆ្លើយអ៊ីចឹងយូរណាស់ អញម៉េចនឹងវ៉ៃអ្អែង។ អាត្រង់ហ្នឹងហើយ អាសេង វានិយាយអ៊ីចឹង។ ហើយការពិតនោះ ខ្ញុំអត់ស្គាល់មែនអត់ស្គាល់សេ.អ៊ី.អាហ្នឹងស្អី កា.ហ្សេ.បេ ហ្នឹងស្អី ទើបស្គាល់ក្រោយទេ។

**ស៖** អម្បាញ់មិញនេះលោកបាននិយាយថា លោកបានប្រឌិតឈ្មោះអ្នកដែលនៅក្នុងបណ្តាញរបស់លោក។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកប្រឌិតឈ្មោះហ្នឹងទាំងអស់ ឬក៏លោក<បញ្ជាក់>ឈ្មោះអ្នកដែលធ្វើការជាមួយលោកមួយចំនួន<ដែលត្រូវបានគេចាប់ខ្លួនរួចហើយនោះ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំមិនបានរាប់រៀបអស់ទេ យើងចេះតែឆ្លើយពីទឹកពីដីទៅ ដូចជានេះអ៊ីចឹង ដូចជាថាធ្វើឲ្យបាក់ម្ជុលដេរ ចាក់ទឹកដាក់ ចាក់ទឹកអាស៊ីតដាក់ក្រណាត់អីៗ អាហ្នឹងខ្ញុំចេះតែឆ្លើយពីទឹកពីដី។ ពេលហ្នឹងវាវង្វេងវង្វាន់អស់ហើយ ជម្រាបលោកព្រះរាជអាជ្ញាបាទ រកគិតអ្វីរកគិតអត់ឃើញទេបាទ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីឈ្មោះនេះបន្តិចទៀត។ <ពាក់ព័ន្ធទៅនឹងចម្លើយ>សារភាព<ដែលលោកឆ្លើយ>នៅមន្ទីរស-២១ គឺលេខឯកសារ <E3/9253> <ចុះកាលបរិច្ឆេទ>ថ្ងៃទី០៦ ដល់ ០៨ វិច្ឆិកា ឆ្នាំ១៩៧៨។ តើឯកសារនេះលោកមាន<>បានអានឡើងវិញទេ ក្រោយឆ្នាំ៧៩? <តើលោកមានបាន>ឃើញ<បានអានឯកសារនោះទេ? ហើយតើអ្វីដែលលោកអាននោះ វាស៊ីគ្នាទៅនឹងអ្វីដែលលោកបាននិយាយទេ ឬក៏អ្នកសួរ>ចម្លើយ<បន្ថែមព័ត៌មានខ្លះទៅលើ>អ្វីដែលលោកបានឆ្លើយ<ប្រាប់គេ>? <>

[១៣:៥២:១១]

**ឆ៖** ឯកសារហ្នឹងខ្ញុំអត់បានអានទេ។ មើលហើយចេះតែ ពេលនោះគឺថាចេញពីហ្នឹងគឺអត់បានគិតចាប់អារម្មណ៍រឿងអានស្អីៗហ្នឹងទេបាទ អត់បានអានអីទាំងអស់បាទ។

**ស៖** នៅផ្នែកចុងក្រោយនៃចម្លើយសារភាពរបស់លោកនោះ គឺមានឈ្មោះទៅដល់៦៨នាក់។ អ៊ីចឹងជាដំបូងខ្ញុំចង់និយាយពីឯកសារ E3/9253 ជាភាសាបារាំងគឺទំព័រ២១ ដល់២៣ <ភាសាអង់គ្លេស<> ២១ ដល់២៤, ភាសាខ្មែរគឺ 00170580 ដល់85។ មានមនុស្ស៦៨នាក់ ដែលក្នុង<នោះ> ២០នាក់ជាមនុស្សដែលត្រូវបានគេចាប់ខ្លួនរួចបាត់ទៅហើយ។ ហើយក្នុងចំណោម២០នាក់ហ្នឹង គឺថាមានឈ្មោះមេរបស់លោក ដូចជាឈ្មោះ <គុណ>, ឈ្មោះ ឈុំ ហើយនិង យ៉ុង ដែលមកពីកង គ-៩។ <អ្នក>ដែលគេចាប់បានខ្លួនហើយនោះ <លោកបានប្រាប់ឈ្មោះពិតរបស់ពួកគេទាំងអស់នោះ> តើលោកបានផ្ដល់ឈ្មោះពិតប្រាកដរបស់គាត់ទៅអ្នកសួរចម្លើយលោក ឬក៏លោកប្រឌិតឈ្មោះហ្នឹងដោយខ្លួនឯងទេ?

**ឆ៖** ឈ្មោះ គុណ, ឈ្មោះ ឈុំ, ឈ្មោះ យ៉ុង, ឈ្មោះ វ៉ាន់ ហ្នឹង អាហ្នឹងគឺថាខ្ញុំនិយាយប្រាប់នេះហ្នឹង គឺថាខ្ញុំនិយាយប្រាប់មែន។ តែមុនគេចាប់ខ្ញុំមកទួលស្លែងហ្នឹង គេចាប់អ្នកអស់ហ្នឹងអស់ហើយ ចាប់ តាគុណ, ចាប់ឈុំ, ចាប់យ៉ុង។ ក្រោយមកបានមិត្តនារីមកនិរតីឈ្មោះ មិត្តវ៉ាន់ ហើយ មិត្តលីនហ្នឹង ដែលយកខ្ញុំទៅដាក់ទួលស្លែងហ្នឹង តែប៉ុន្មាននាក់ហ្នឹងទេ។

**ស៖** សំណួរចុងក្រោយនូវប្រធានបទនេះ គឺថាមានឈ្មោះម្នាក់ទៀតគឺឈ្មោះនៅលេខរៀងទី

៦៨ហ្នឹងមានឈ្មោះ ប៉ង់ ជាគណៈក្រសួងស-៧១ ចាប់បាត់ហើយ។ តើលោកមានស្គាល់ឈ្មោះ ប៉ង់ ហ្នឹងទេ ឬក៏គ្រាន់តែឈ្មោះដែលអ្នកសួរចម្លើយលោកហ្នឹងគាត់បន្ថែមខ្លួនឯងទេ?

[១៣:៥៥:១៨]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប! ដូចមានបញ្ហា។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ ពាក់ព័ន្ធ និងផ្អែកលើមូលដ្ឋាននៃឯកសារបានមកពីចម្លើយសារភាពនេះ ធ្វើជាមូលដ្ឋានសួរដេញដោលដូចជាបញ្ហា។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ លោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មិនជាការជំទាស់ទេ ខ្ញុំយល់អំពីហេតុផលអ្វីបានជាព្រះរាជអាជ្ញាសួរសំណួរបែបនេះ ប៉ុន្តែគាត់សួរសំណួរពីចម្លើយសារភាព ហើយសួរឈ្មោះហ្នឹង។ តាមពិតទៅឈ្មោះហ្នឹង គឺជាឈ្មោះនៅក្នុងចម្លើយសារភាពរបស់<ដើមបណ្ដឹងរដ្ឋប្បវេណី វាដូចជាអ្វីដែលបានមកពីចម្លើយសារភាព>។ ដូច្នេះខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះមានការណែនាំយ៉ាងម៉េចដែរ? ថាតើអនុញ្ញាតដែរឬទេ ដែលឲ្យមានការប្រើប្រាស់ចម្លើយសារភាពបែបនេះ? ព្រោះថា ក្នុងពេលកន្លងមកហ្នឹង គឺមានការហាមឃាត់នៅពេលដែលសួរសំណួរប្រហាក់ប្រហែលគ្នានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៥៧:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា វា<>មានប្រយោជន៍ នៅពេលដែលភាគីណាមួយចង់ប្រើខ្លឹមសារចម្លើយសារភាព គឺត្រូវប្រាប់អង្គជំនុំជម្រះពីមូលហេតុដែលខ្លួនចង់ប្រើចម្លើយសារភាព។ ឥឡូវខ្ញុំចង់ដឹងថា មូលហេតុដែលសហព្រះរាជអាជ្ញាប្រើព័ត៌មានទាំងអស់នេះៗ គឺក្នុងបំណងបង្ហាញពីការពិតនៃព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពហ្នឹង ឬក៏ដោយមានមូលហេតុមួយផ្សេងទៀត?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សំណួរខ្ញុំច្បាស់ហើយ ខ្ញុំចង់បែងចែកឲ្យច្បាស់លាស់ទាក់ទងទៅ

នឹងឈ្មោះមនុស្សចុងក្រោយនេះ។ ខ្ញុំចង់ដឹងថា តើជាឈ្មោះដែលគាត់ស្គាល់ ហើយគាត់ឆ្លើយរៀបរាប់ដាក់ ឬក៏ជាសេរីភាពរបស់អ្នកសួរចម្លើយយកឈ្មោះនេះមកដាក់ក្នុងបញ្ជីដោយខ្លួនឯង ដែលគេចោទថាជាអ្នកក្បត់។ ហើយខ្ញុំ<សូមរំឭកថា>"អនុសញ្ញា<ក្រុងហ្សឺណែវប្រឆាំង>នឹងការធ្វើទារុណកម្ម" ដែល<បាន>អនុវត្ត<ជាយូរហើយនោះ គឺមិនអនុញ្ញាតឲ្យបុគ្គលណា>ទាញយកប្រយោជន៍ពីព័ត៌មានដែល<មានក្នុងចម្លើយ>សារភាព<> ដែល<>បានមកពីការធ្វើទារុណកម្មទៅលើអ្នកដែលរងការធ្វើទារុណកម្ម<នោះទេ>។ ត្រង់កន្លែងនេះ <>មិន<មែនជាករណីនោះ>ទេ<>។ <នោះហើយគឺជាមូលហេតុដែល>ខ្ញុំសួរទៅ<ដើមបណ្ដឹងរដ្ឋប្បវេណី> ដែលគាត់ទទួលរងការធ្វើទារុណកម្មផ្ទាល់ <ដើម្បីឲ្យ>គាត់<និយាយអំពី>ចម្លើយ<សារភាពទាំង>នេះ <ហើយបញ្ជាក់ប្រាប់យើងនូវអ្វី>ដែល<ជាការពិតហើយអ្វីដែលមិនពិត>។ <ខ្ញុំគ្មានបំណងណាមួយក្នុងការប្រើប្រាស់>អនុសញ្ញា<ប្រឆាំងនឹងការធ្វើទារុណកម្មប្រឆាំងនឹងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ផ្ទុយគ្នាទាំងស្រុងតែម្ដង។ ដូច្នេះហើយ ខ្ញុំគិតថាសំណួរនេះត្រូវបានអនុញ្ញាតហើយលោកប្រធាន>។

[១៣:៥៩:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹងលោក គោលបំណងរបស់លោកមិនសួរថា ប៉ង់ នេះជាសេ.អ៊ី.អា ទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ នុំងហើយ ខ្ញុំមិនចង់សួរអ៊ីចឹងទេ។ ខ្ញុំគ្រាន់តែចង់សួរថាតើកាលនោះដើមបណ្ដឹងរដ្ឋប្បវេណីនេះស្គាល់ ប៉ង់ ដែរឬទេ? ហើយ<តើ>គាត់ពិតជាបានឆ្លើយរាយការណ៍ទៅអ្នក<>សួរចម្លើយគាត់មែន ឬក៏អ្នកសួរចម្លើយគាត់<នៅ ស-២១>ហ្នឹង បន្ថែមដោយខ្លួនឯងទេ ដោយសេរីដោយខ្លួនឯងទេ តាមទំនើងចិត្តគេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៣:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថា សំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាចំពោះដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ ពិតមែនតែផ្អែកលើមូលដ្ឋាននៃកំណត់នៃសក្ខីកម្មដែលបានមកពីការធ្វើទារុណកម្មមែន ប៉ុន្តែសំណួរនេះ គឺជាប្រភេទសំណួរមួយដែលអាចសួរបាន។ ដូច្នេះ គឺសហព្រះរាជអាជ្ញារង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អន្តរជាតិ អាចតាំងសំណួរចុងក្រោយបញ្ជាក់ឡើងវិញចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីគាត់ស្ដាប់យល់ ហើយនិងអាចឆ្លើយតបបាន ពីព្រោះទំនងជាគាត់ភ្លេចហើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្គាល់ឈ្មោះ ប៉ង់ នេះដែរឬទេ ដែលនៅគណៈក្រសួង ស-៧១ *(ស៊ីក)* នៅសម័យកម្ពុជាប្រជាធិបតេយ្យ? តើលោកខ្លួនឯងជាអ្នកផ្ដល់ឈ្មោះនេះទៅអ្នកសួរចម្លើយលោក ឬក៏អ្នកសួរចម្លើយលោកនោះ មានគំនិតផ្ដួចផ្ដើមដោយខ្លួនឯង ដាក់ឈ្មោះហ្នឹងចូលទៅក្នុងបញ្ជីហ្នឹង? លោកយល់ខ្ញុំទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា នេះគឺជាវិធីសាស្ត្រឆ្លាតវៃក្នុងការកែសម្រួល<ជាសំណួរដូចមុនដដែល>។ <ជាថ្មីម្ដងទៀត ខ្ញុំមិនជំទាស់នឹងការតាំងសំណួរនេះទេ> ប៉ុន្តែការពិតទៅ <> វាជាសំណួរដដែលទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំអម្បាញ់មិញ ខ្ញុំស្ដាប់តាមការបកប្រែជាភាសាបារាំង អង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំសួរ អ៊ីចឹងហើយខ្ញុំសួរម្ដងទៀត។

[១៤:០៤:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែប្រសិនបើតាមការបកប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះជាភាសាអង់គ្លេស គឺបកផ្សេងទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីបំភ្លឺខ្លឹមសារនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះហ្នឹង គឺអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់សួរសំណួរហ្នឹង ពីព្រោះថាអង្គជំនុំជម្រះ<មិនចាត់ទុក>ថាវាជាសំណួរដែល<>ចង់<បញ្ជាក់>ការពិត<នៃព័ត៌មានដែលមាន>នៅក្នុងចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្មនោះទេ។ <ព្រោះថាចំណុចនេះ>មិនចង់សួរ<ឲ្យបញ្ជាក់>ថាតើ<> ប៉ង់ នេះ<ជាផ្នែកនៃបណ្ដាញ សេ.អ៊ី.អា ឬអត់នោះទេ។ ហើយអ្វីដែល>អង្គជំនុំជម្រះបាន<និយាយទៅកាន់ព្រះរាជអាជ្ញានោះគឺថា គាត់អាចតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី>ឡើងវិញ។ <ដូច្នេះ គំនិតនោះគឺថា មិនឲ្យរៀបសំណួរឡើងវិញទេ ប៉ុន្តែឲ្យសួរទៅកាន់សាក្សីឡើងវិញ។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកយល់សំណួរខ្ញុំទេ? ហើយអាចឆ្លើយនឹងសំណួរខ្ញុំបានទេ ទាក់ទងនឹង ប៉ង់ នេះ?

**លោក ជុំ ម៉ី៖**

**ឆ៖** ខ្ញុំបាទជម្រាបលោកព្រះរាជអាជ្ញាអំពីរឿង ប៉ង់។ ប៉ង់ ហ្នឹងខ្ញុំមិនដែលឃើញ មិនដែលស្គាល់ទេ។ ទើបតែខ្ញុំធ្វើអាចង្រ្កាននៅនឹងផ្សារអូរឫស្សីហ្នឹង គឺថាគាត់ហ្នឹងទៅប្រាប់ខ្ញុំ ថាកុំយកអាឥដ្ឋហ្នឹងធ្វើចង្រ្កានហ្នឹង ព្រោះអាឥដ្ឋហ្នឹងវាថ្លៃណាស់ គេដឹកពីចិនមកថ្លៃណាស់ អាឥដ្ឋហ្នឹង។ ម្ល៉ោះហើយកុំឲ្យយកអាឥដ្ឋហ្នឹងធ្វើ។ អ៊ីចឹងខ្ញុំបានសួរតែអាអ្នកដាំបាយអីៗហ្នឹង ខ្ញុំសួរអ្នកណាគេមកប្រាប់ខ្ញុំថាកុំឲ្យយកឥដ្ឋហ្នឹងរៀបហ្នឹង ហើយគេថាឈ្មោះ ប៉ង់ ហ្នឹង ហើយខ្ញុំដឹងថា ប៉ង់ ហៅតាមគេអ៊ីចឹង ប៉ង់ៗ ទៅ តែគាត់ក៏មិនដែលមកទាក់ទងខ្ញុំទៀត ខ្ញុំមិនដែលទាក់ទងគាត់ទៀតដែរ។

[១៤:០៦:៥៤]

**ស៖** តើលោកដឹងដែរឬទេ ថាតើ លីន ដែលនាំលោកទៅមន្ទីរស-២១ហ្នឹង ជាអតីតអ្នកធ្វើការជាមួយ ប៉ង់ ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទអត់បានដឹងទេ រឿងរ៉ាវហ្នឹង ជម្រាបលោកប្រធាន -- ជម្រាបលោកព្រះរាជអាជ្ញា។

**ស៖** សូមអរគុណលោកប្រធាន ខ្ញុំនៅសល់សំណួរប្រាំ ប្រាំមួយទៀត ហើយខ្ញុំនឹងព្យាយាមសួរឲ្យខ្លីៗ។ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកនិយាយថា លោកបានរស់រានមានជីវិតដោយសារលោកមានសមត្ថភាព តើនៅពេលដែលលោកធ្វើការនៅរោងជាង លោកមានដឹងដែរឬទេ ថាជីវិតរបស់លោកហ្នឹងអាចរស់រានមានជីវិតបាននោះ តែរយៈពេលបណ្តោះអាសន្ន រយៈពេលខ្លីទេ ហើយលោកនឹងអាចត្រូវបានគេយកទៅសម្លាប់ក្នុងពេលណាមួយក៏បានដែរ?

**ឆ៖** យើងអត់សង្ឃឹមថាយើងនៅរស់រានមានជីវិតមកទល់ថ្ងៃហ្នឹងទេ ជម្រាបលោកព្រះរាជអាជ្ញា។ ក្នុងសារមន្ទីរទួលស្លែងហ្នឹង ២០.០០០នាក់ហ្នឹងគឺថាអត់មានអ្នកណារួចមួយទេ គេកម្ទេចទាំងអស់។ អ៊ីចឹងយើងដូចខ្ញុំជម្រាបដើមដំបូង ខ្ញុំថា ខ្ញុំជីវិតខ្ញុំកើតមួយសាទៀតហ្នឹង។

[១៤:០៨:៣៩]

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់មួយដែល ឌុច បាននិយាយទាក់ទងនឹងលោកនៅក្នុងឯកសារ

E3/5770 នៅក្នុងទាំងបីភាសាហ្នឹងគឺទំព័រទី២, ទី៣។ គាត់និយាយអំពីលោក៖ “ខ្ញុំមិនសង្ស័យថា ជុំ ម៉ី នេះពិតជាអ្នកទោសនៅមន្ទីរស-២១ ទេ ក៏ប៉ុន្តែ ហ៊ី នេះជាអ្នកចាត់តាំងឱ្យ ជុំ ម៉ី ទៅធ្វើការ។” ហើយបន្ទាប់មកទៀត ឌុច គាត់និយាយបន្ត គាត់និយាយថា៖ “អ្នកទោសទាំងអស់ហ្នឹងគង់តែត្រូវយកទៅសម្លាប់<មិនថាយូរឬឆាប់ទេ> ក៏ប៉ុន្តែ<ការសម្លាប់នោះអាចត្រូវបានពន្យារពេល ដើម្បីទុកឱ្យពួកគេធ្វើការនៅ ស-២១”។ ហើយចុះក្រោមបន្តិច> “ហ៊ី ហ្នឹងមានសិទ្ធិសម្រេច<ទុក>អ្នកទោសឱ្យធ្វើការនៅមន្ទីរស-២១ ហើយមិន<>យកសម្លាប់ភ្លាមៗ <ហើយ>គាត់ត្រូវតែធានាធ្វើយ៉ាងណាកុំឱ្យអ្នកទោសហ្នឹងលួចរត់រួច ហើយនិងបង្កបញ្ហា។” តើមុនពេលដែលគេឱ្យលោកទៅធ្វើការនៅកន្លែងរោងជាងហ្នឹង មានអ្នកណាដែលអ្នកយាមណានៅពេលនោះ ប្រាប់លោកថាធ្វើម៉េចកុំឱ្យលួចរត់ដែរឬទេ? <តើគេមានសួរលោកប្រហាក់ប្រហែលនេះដែរទេ?>

**ឆ៖** ពេលនុ៎ងគឺថា សួស ធី ហ្នឹងគាត់យកខោអាវមកឱ្យខ្ញុំស្លៀកពាក់ហ្នឹង ឱ្យទៅធ្វើការនៅរោងជាងខាងក្រោយ។ គាត់ប្រាប់ “អ្អែងកុំរត់ណា៎! តែរត់បាញ់អ្អែងចោលហើយ”។ ពេលនុ៎ងគឺថា ពួកវាហ្នឹងយកខ្ញុំទៅរោងជាងខាងក្រោយហ្នឹងគឺថាចងមុខ ហើយនិងដាក់ស្លាបសេក ដាក់ខ្នោះ។ ទៅដល់អាកន្លែងយើងជួសជុលម៉ាស៊ីនដេរហ្នឹង វាដាក់ខ្នោះជើង ហើយបើកមុខដោះដៃ ចេញពីខ្នោះឱ្យជួសជុលអាម៉ាស៊ីនដេរហ្នឹង។

**ស៖** <>នៅពេលដែលលោក<>ជាប់ឃុំឃាំង<នៅ ស-២១>ប្រហែលជាពីរខែ<នោះ> តើលោកដឹង<>ថា មានអ្នកទោសវៀតណាម ឬក៏ចាមដែរឬទេ? តើលោកមានបានឃើញ ឬក៏មានបានឮ<>ដែរឬទេ? <តើលោកអាចប្រាប់អ្វីបានខ្លះពាក់ព័ន្ធនឹងបញ្ហានេះ?>

[១៤:១១:៣៤]

**ឆ៖** ខ្ញុំបានឮសួរក្រោយមកទេ។ ខ្ញុំមិនបានឃើញជាក់នឹងភ្នែកខ្ញុំទេ គ្រាន់តែឮសួរគេនិយាយប្រាប់ខ្ញុំក្រោយៗហ្នឹង ព្រោះក្រោយមកហ្នឹងគឺថា វ៉ាន់ ណាត ហ្នឹងគាត់នៅជាមួយខ្ញុំ គាត់និយាយថា មានអ្នកទោសវៀតណាម មានអ្នកទោសចាម ស្អីៗអ៊ីចឹងណា៎។ ខ្ញុំគ្រាន់តែបានឮប៉ុណ្ណឹងទេ មិនបានឃើញផ្ទាល់នឹងភ្នែកទេ។

**ស៖** ឥឡូវសំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំមានសំណួរមួយទាក់ទងនឹងកូនស្រីរបស់លោកទាំងពីរនាក់។ លោកបាននិយាយអំពីកូនប្រុសរបស់លោកដែលស្លាប់ពេលជម្លៀស ហើយលោកមានកូនង៉ាមួយហើយនិងប្រពន្ធលោក<ដែលស្លាប់ក្នុងពេលរត់គេចខ្លួន>។ អ៊ីចឹងខ្ញុំសួរថា តើមានរឿងអីកើតឡើង

ចំពោះកូនស្រីលោកទាំងពីរនាក់ដែលធំៗជាងគេនោះ? តើលោកដឹងថា ពួកគាត់<ទៅ>ណាដែរឬទេ? ហើយលោកបែកបាក់ពីគាត់ហ្នឹង<យ៉ាង>ណាដែរ? ហើយលោកមានធ្លាប់បានទទួលដំណឹងពីពួកគាត់ដែរឬទេ?

**ឆ៖** ខ្ញុំបាទកូនប្រុសមួយស្លាប់នៅព្រៃកក្តាម កប់នៅព្រៃកក្តាម។ នៅសល់កូនស្រីពីរនាក់។ កូនស្រីពីរហ្នឹងគឺថាទៅនៅជាមួយម្តាយវានៅព្រៃកក្តាមហ្នឹង។ ក្រោយមកខ្ញុំនៅធ្វើការអូរឫស្សីហ្នឹង ខ្ញុំសុំពួកគេហ្នឹងឲ្យគ្រួសារខ្ញុំចូលមកជួយកាត់ដេរហ្នឹងផង។ ពេលហ្នឹងគេយកទាំងកូនខ្ញុំ ប្រពន្ធខ្ញុំអីយកមកកន្លែងកាត់ដេរហ្នឹង។ ហើយកូនស្រីខ្ញុំ បងហ្នឹងវាចេះកាត់ដែរ កាត់អី ចេះដេរអីដែរ ព្រោះអាយុវា១២ឆ្នាំហើយ នៅកូនស្រីមួយទៀតនៅមន្ទីរកុមារផ្សារដើមគ។ ពេលដែលគេចាប់ខ្ញុំមកទួលស្លែងហ្នឹងគឺថា កូនខ្ញុំ ប្រពន្ធខ្ញុំអត់ដឹងថាគេចាប់ខ្ញុំមកទួលស្លែងទេ។

[១៤:១៥:00]

**ស៖** ខ្ញុំទុកឲ្យលោកបំពេញចម្លើយបន្ទាប់ទៀត នៅពេលដែលលោកនិយាយពីទុក្ខវេទនារបស់លោក។ លោកនិយាយថា លោក<ទៅ>មន្ទីរស-២១ ជាញឹកញាប់។ សព្វថ្ងៃហ្នឹង លោកលក់សៀវភៅនៅទីនោះ។ <ដូច្នេះវាអាច>ជាសំណួរមួយដែល<ប៉ះពាល់ដល់ផ្លូវចិត្ត>បន្តិចដែរ។ លោក<រស់>នៅ<ទី>នោះ<រយៈពេល>ពីរខែ <លោកឈឺចាប់ច្រើនណាស់។> ហើយតើការនិទានរឿងរ៉ាវរបស់លោកក្នុងសៀវភៅលោកនេះ វាធ្វើឲ្យលោកអាចចេញផុត<ពីការចងចាំ>នៅមន្ទីរស-២១<ទេ?> ឬក៏<តើការចងចាំរបស់លោកនៅ ស-២១ នៅមានដល់បច្ចុប្បន្ន ដែលលោកមានអារម្មណ៍ថាជាកាតព្វកិច្ច ក្នុងការ>ផ្តល់សក្ខីកម្ម<ហើយត្រូវទៅស-២១ រហូតដល់ពេលនេះឬ>?

**ឆ៖** ចំពោះខ្ញុំមិនបានបំភ្លេចអ្វីដែលវាបាត់បង់ទៅទាំងប៉ុន្មានហ្នឹង ខ្ញុំមិនអាចបំភ្លេចបានទេ។ ប្រជាជនខ្មែរជិត៣លាននាក់ស្លាប់ដោយសាររបប ប៉ុល ពត ហ្នឹង។ អីចឹងយើងអត់បំភ្លេចបានទេ ប្រជាជនខ្ញុំ គឺខ្ញុំភ្លេចអត់បានទេ។ ម៉េចបានខ្ញុំបំភ្លេចមិនបាន? ព្រោះនៅពិភពលោកទាំងមូលមិនដែលប្រទេសណាកាប់សម្លាប់ជាតិឯងដូចប្រទេសកម្ពុជាទេ។ តែបើតាមខ្ញុំដឹងមួយជំនាន់នុ៎ង ប៉ុល ពត កាន់កាប់ហ្នឹង ប្រទេសហ្នឹងអត់មានច្បាប់ទេ កាប់សម្លាប់ជាតិឯងហ្នឹង។ សូម្បីតែសាសនាក៏វាអត់ឲ្យមានផង កម្ទេចចោលទាំងអស់។ អីចឹងខ្ញុំអត់បំភ្លេចបានទេ។ អីចឹងដែលខ្ញុំខំលក់សៀវភៅ ខ្ញុំខំនិយាយរឿងរ៉ាវប្រាប់ភ្ញៀវទេសចរណ៍ហ្នឹង គឺថាខ្ញុំដូចមនុស្សវិកលចរិតអីចឹង។ រាល់ថ្ងៃដូចមនុស្សវិកលចរិតអីចឹង ភ្ញៀវយំៗតាមភ្ញៀវទៅ ភ្ញៀវសើចៗតាមភ្ញៀវទៅ រាល់ថ្ងៃហ្នឹង។

[១៤:១៦:២៥]

**ស៖** សំណួរចុងក្រោយបំផុតរបស់ខ្ញុំ<។> លោកបានចូលរួមក្នុងសំណុំរឿង<០០១> លោក <>ជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ណាស់ <>នៅក្នុង<សំណុំ>រឿង<នោះ>។ <ហើយនៅក្នុងសំណុំរឿងនេះ។> ឌុច <បាន>សហការ<យ៉ាងច្រើន។> ហើយគាត់ទទួលស្គាល់ឧក្រិដ្ឋកម្មមួយចំនួនដែលបានប្រព្រឹត្តនៅមន្ទីរស-២១។ គាត់ទទួលស្គាល់ថា លោកពិតជាអ្នកទោសនៅមន្ទីរស-២១ មែន។ នៅក្នុងសំណុំរឿងយើង<បច្ចុប្បន្ន>នេះ <>ជនជាប់ចោទមិនសហការទេ <ព្រោះពួក>គាត់<បានជ្រើសរើសការរក្សាការ>ស្ងៀម<ស្ងាត់>។ តើចំពោះលោកផ្ទាល់នោះ តើនៅពេលដែលជនជាប់ចោទគាត់នៅស្ងៀមមិនឆ្លើយតបអីនេះ តើវាជាការធ្វើឲ្យលោកឈឺចាប់បន្ថែមទៀតដែរឬទេ?

**ឆ៖** ខ្ញុំទោះបីគាត់ឆ្លើយមិនឆ្លើយ ខ្ញុំអត់មានបញ្ហាទេ ខ្ញុំអត់មានបញ្ហាទេ ព្រោះខ្ញុំគឺថាទឹកភ្នែកខ្ញុំជារៀងរាល់ថ្ងៃអត់ដែលខានទេ។ ខ្ញុំនឹកថាអ្វីដែលជាតិខ្ញុំស្លាប់អស់ជិត៣លាននាក់ វាហួសទៅហើយឲ្យវាហួសទៅចុះ យើងធ្វើម៉េច យើងផ្តល់សក្ខីកម្មជូនតុលាការឲ្យដឹងការពិត បាទឲ្យដឹងការពិត ថាគេធ្វើទារុណកម្មយ៉ាងម៉េចខ្លះៗជំនាន់នុ៎ង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះផ្តល់ទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី។ សូមអញ្ជើញ!

[១៤:១៨:៣៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោកនៅពេលរសៀលនេះ។ ជាដំបូង ខ្ញុំចាប់ផ្តើមសួរលោកអំពីសំណួរមួយចំនួនពាក់ព័ន្ធថ្ងៃខែឆ្នាំកំណើតថា

តើលោកកើតនៅថ្ងៃ០៩ វិច្ឆិកា ឆ្នាំ<>១៩៣៣ តើមែនទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** ស្តាប់អត់បាន។

**ស៖** មិនអីទេ។ តើលោកកើតនៅថ្ងៃទី០៩ វិច្ឆិកា ១៩៣៣ តើមែនទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក ជុំ ម៉ី! ហើយមន្ត្រីរដ្ឋបាលតុលាការបង្វែរក្បាលមីក្រូហ្វូនមកខាងលិចបន្តិច ដើម្បីគាត់អាចមើលមុខជាមួយអ្នកសួរ និងអ្នកឆ្លើយបានល្អ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកស្តាប់ខ្ញុំឮទេលោកដើមបណ្តឹង?

**លោក ជុំ ម៉ី៖**

**ឆ៖** បាទ ស្តាប់ឮហើយលោកប្រធាន។ ខ្ញុំកើតឆ្នាំ១៩៣៣។

**ស៖** តើលោកកើតនៅថ្ងៃទី០៩ វិច្ឆិកា តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែនហើយលោកបាទ។

[១៤:២០:៤៨]

**ស៖** អ៊ីចឹងលោកកើតនៅក្នុងឃុំល្វា <> ស្រុកព្រះស្តេច <ខេត្តព្រៃវែង> តើមែនដែរឬទេ? គឺខ្ញុំអានពីឯកសារ E3/5885, អង់គ្លេសមាន <00156834>, ខ្មែរមាន 00152375, បារាំងមានលេខ 00351286។ ដូច្នេះលោកដើមបណ្តឹងរដ្ឋប្បវេណីខ្ញុំសូមសួរសំណួរឡើងវិញ ថាលោកកើតនៅឃុំល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង តើមែនដែរឬទេ?

**ឆ៖** ជម្រាបលោកប្រធាន ពីមុនមានស្រុកគេហៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ក្រោយមកគេដូរមកស្រុកព្រះស្តេចវិញ ហើយដែលខ្ញុំធ្វើក្រោយនេះធ្វើតាមយើងដាក់ស្រុកព្រះស្តេចទៅបាទ។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើលោកមានបងប្អូន<ប្រុសស្រី>ប៉ុន្មាននាក់ដែរ?

**ឆ៖** ជម្រាបថាលោក ខ្ញុំមានបងប្អូនប្រាំបីនាក់ ស្រីពីរ ប្រុសប្រាំមួយ។

**ស៖** មុនពេលដែលខ្ញុំសួរសំណួរអំពីអ្វីដែលកើតឡើងចំពោះលោកនៅឆ្នាំ៧៨នោះ ខ្ញុំចង់សួរលោកពីរបីសំណួរទៀតសិន ទាក់ទងទៅនឹងព្រះអង្គម្ចាស់ ចន្ទរង្សី ដែលលោកបាននិយាយពីរបីដងរួចមកហើយ ហើយសូម្បីតែក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ ក៏លោកបាននិយាយដែរ។ ដូច្នេះខ្ញុំចង់

ដឹងថា តើលោកមានទំនាក់ទំនងអ្វីដែរជាមួយព្រះអង្គម្ចាស់ ចន្ទរង្សី?

**ឆ៖** បាទជម្រាបលោក ព្រះអង្គ ចន្ទរង្សី កាលពីមុនគាត់នៅច្បារមនបាទ ហើយគាត់មានត្រាក់ទ័រច្រើនដើម្បីធ្វើកន្លែងត្រង់សេ ការពារពួកខ្មែរក្រហម ហើយគាត់អត់មានជាងទេ គាត់ហៅខ្ញុំជាងហ្នឹងទៅជួសជុលត្រាក់ទ័រឲ្យគាត់ព្រះអង្គម្ចាស់ ចន្ទរង្សី ហ្នឹង។ គាត់នឹងត្រូវជាមាសម្ដេច សីហនុ។

[១៤:២៤:១៤]

**ស៖** តើលោកដឹងទេថាគាត់ចូលរួមនៅក្នុងសង្គ្រាមស៊ីវិល ហើយគាត់គឺជាទាហាន លន់ នល់ <> ផងដែរនោះ?

**ឆ៖** យើងដឹងថាគាត់ចូលរួមជាទាហាន លន់ នល់ កាលហ្នឹងគឺថា យើងដឹងពីកូនទាហាន កូនអីទេថា គាត់ហ្នឹងពាក់ផ្កាយ១ ចន្ទរង្សី ហ្នឹង។

**ស៖** នៅពេលដែលលោកនៅជាមួយគាត់ គឺថាលោកបាននិយាយនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះថា លោកនៅផ្ទះរបស់គាត់។ តើនៅពេលនុ៎ង តើព្រះអង្គម្ចាស់ ចន្ទរង្សី ហ្នឹងគឺជាឧត្តមសេនីយ៍ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា។

**លោក ជុំ ម៉ី៖**

**ឆ៖** ពិតមែនហើយ គាត់នៅផ្ទះគាត់ហ្នឹង ជាឧត្តមសេនីយ៍មែន។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថា នៅពេលដែលលោកស្នាក់នៅជាមួយគាត់ហ្នឹង គឺគាត់ជាឧត្តមសេនីយ៍ហើយឬនៅ? ហើយថាតើគាត់បានចូលរួមនៅក្នុងសមរភូមិប្រយុទ្ធដែរទេ<>ពេលដែលលោកថា ស្នាក់នៅផ្ទះគាត់នោះ?

[១៤:២៦:០៦]

**ឆ៖** ខ្ញុំបាទមិនមែនស្នាក់នៅផ្ទះគាត់ទេ គ្រាន់តែទៅធ្វើឲ្យគាត់ ជាជាងជួសជុលត្រាក់ទ័រ ជួសជុលឡានឲ្យគាត់ អត់មានស្នាក់នៅផ្ទះគាត់ទេ ប៉ុន្តែមានពេលមួយ គាត់ហៅខ្ញុំមកឲ្យយកលុយដើម្បីទិញគ្រឿងបន្លាស់ត្រាក់ទ័រស្អីៗនៅបន្ទប់គាត់។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់<ខ្លីមួយ>ពីឯកសារ E3/5885 ខ្មែរមានលេខ 00152

377, អង់គ្លេសមានលេខ 00156836, បារាំងមានលេខ 00351290 គឺ<និយាយ>ដូចតទៅនេះ៖ "មុន<ថ្ងៃ១៧ មេសា> ឆ្នាំ៧៥ ខ្ញុំធ្វើការនៅមន្ទីរកិច្ចការសាធារណៈខេត្តកំពង់ស្ពឺ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះអង្គម្ចាស់ ចន្ទរង្សី។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ ខ្មែរក្រហមបានព័ទ្ធខេត្តកំពង់ស្ពឺ ព្រះអង្គម្ចាស់ ចន្ទរង្សី បានឲ្យយន្តហោះមកយកខ្ញុំ ទៅនៅដំណាក់សំណាងមិត្ត នៅខេត្តកណ្ដាល។ នៅពេលមកដល់ដំណាក់<ភ្នំ>សំណាង<>ព្រះអង្គម្ចាស់ ចន្ទរង្សី បានឲ្យខ្ញុំស្នាក់នៅផ្ទះ<របស់គាត់> ហើយចាំទទួលបញ្ជារបស់គាត់។" តើអ្វីដែលខ្ញុំអានហ្នឹងធ្វើឲ្យលោកនឹកឃើញឡើងវិញដែរឬទេ?

**ឆ៖** មិនមែនផ្ទះនេះទេ ផ្ទះសាម៉នម៉េត មិនមែនផ្ទះសំណាងមិត្តទេ។ ផ្ទះសាម៉នម៉េត នៅយើងជិតបែកចានហ្នឹង។ ពេលនុ៎ងគឺថាខ្មែរក្រហមព័ទ្ធជុំវិញនៅច្បារមនហ្នឹង ហើយគាត់ឲ្យអេលីកូទៅយកខ្ញុំពីច្បារមនហ្នឹងមក ពេលម៉ោងដប់ពីរថ្ងៃត្រង់យកតែខ្ញុំម្នាក់ទេមកនេះហ្នឹង ដំណាក់សាម៉នម៉េតហ្នឹង។ មកដល់គាត់ប្រាប់ថា "ប្អូនម៉ីឯង ទៅផ្ទះសិនទៅ ចាំកាលណាស្រុកម៉េចៗ ស្រុកសាន្តត្រាណអី ចាំខ្ញុំឲ្យគេទៅយកមកវិញ។" គ្រាន់តែប្រាប់ខ្ញុំប៉ុណ្ណឹង ចាប់តាំងពីនោះមក គឺថាបែកគ្នារហូត។

[១៤:២៨:៥៥]

**ស៖** តើវាមានន័យយ៉ាងម៉េច នៅពេលដែល<លោកនិយាយ> ឬក៏លោកសរសេរនៅក្នុងទម្រង់បែបបទព័ត៌មាននុ៎ងថា "ព្រះអង្គម្ចាស់ ចន្ទរង្សី ឲ្យខ្ញុំស្នាក់នៅផ្ទះ<របស់គាត់> ហើយចាំទទួលបញ្ជារបស់គាត់"? ស្ដាប់ទៅវាហាក់ដូចជា<ថាលោកជា>ជាទាហាន ឬក៏កងទ័ពអីចឹងដែរ។ តើលោកអាចបកស្រាយបានទេ?

**ឆ៖** ខ្ញុំបាទ មិនមែនជាកងទ័ពទេ។ ខ្ញុំបាទស៊ីវិល ធ្វើការនៅខាងគមនាគមន៍ ធ្វើផ្លូវ ធ្វើស្ពាន ធ្វើត្រាក់ទ័រ ធ្វើឡានហ្នឹង។ ខ្ញុំស៊ីវិលទេ ខ្ញុំមិនដែលធ្វើទាហានទេ។ ជំនាន់ ប៉ុល ពត ក៏មិនដែលធ្វើទាហាន ជំនាន់ លន់ នល់ ក៏មិនដែលធ្វើទាហាន សង្គមណាក៏ដោយ ខ្ញុំមិនដែលធ្វើទាហានទេ។

**ស៖** អីចឹងខ្ញុំសួរអីចេះវិញ ថាតើព្រះអង្គម្ចាស់ ចន្ទរង្សី ឬក៏យើងអាចនិយាយម្យ៉ាងទៀតថា ឧត្តមសេនីយ៍ ចន្ទរង្សី ហ្នឹងមាន<តួនាទី>បញ្ជា<លោកទេ> ឬក៏បានឲ្យបញ្ជាមកលោកអ្វីដែរឬទេ?

**ឆ៖** គាត់អត់មានបានបញ្ជាប្រាប់ខ្ញុំយ៉ាងម៉េចៗទេ អត់មានបានបញ្ជាអីទេ គ្រាន់តែថា មកជួបគាត់ហ្នឹង គាត់ប្រាប់ខ្ញុំថា "ប្អូនម៉ីឯងទៅនៅផ្ទះសិនទៅ ចាំស្រុកគេសាន្តត្រាណយ៉ាងម៉េចៗ ចាំខ្ញុំឲ្យគេទៅយកមកវិញ។" គ្រាន់តែប្រាប់ប៉ុណ្ណឹងទេ បាទ។

**ស៖** ឥឡូវនេះខ្ញុំនឹងសួរលោកពីមនុស្សដទៃ<>ទៀត ដែល<ខ្ញុំជឿថា លោក>ស្គាល់<គាត់>

មុនឆ្នាំ៧៥។ គឺ អ៊ឹង ប៊ិច លោកបាននិយាយច្រើនដងហើយ អំពី អ៊ឹង ប៊ិច ហ្នឹងសូម្បីនៅក្នុងកំណត់ហេតុ នៅក្នុងសវនាការហ្នឹងក៏លោកនិយាយដែរ។ តើលោកស្គាល់លោក អ៊ឹង ប៊ិច <លើកដំបូងនៅពេល>ណាដែរ?

[១៤:៣១:១៥]

**ឆ៖** បាទ ជម្រាបលោកថា លោក អ៊ឹង ប៊ិច ហ្នឹងគាត់ជា*មេកានិចស្បាង*ដូចខ្ញុំដែរ គេហៅថា *មេកានិច*នោះ *មេកានិចស្បាង*ដូចគ្នា។ ជំនាន់លន់នល់ហ្នឹង ធ្វើការនៅខាងគមនាគមន៍គេហៅអូរដឹមហ្នឹង ធ្វើការជាមួយគ្នា។ ដល់ពេលបែកទីក្រុងភ្នំពេញទៅហ្នឹង គឺថាមិនដឹងជាគាត់ទៅឯណាមកឯណា ខ្ញុំអត់បានដឹងទេ។ ស្រាប់តែដល់ពេលមួយ គេចាប់ខ្ញុំទៅទួលស្លែង ស្រាប់តែឃើញគាត់នៅទួលស្លែងហ្នឹង។ ហើយគាត់ឃើញខ្ញុំគាត់រាដៃ រាដៃអ៊ីចឹង ខ្ញុំដឹងថា គាត់ប្រហែលជាអត់ឲ្យខ្ញុំនិយាយរកគាត់ហើយមើលទៅ គាត់រាដៃបាទ។

**ស៖** អ៊ីចឹងមានន័យថា អ៊ឹង ប៊ិច ហ្នឹងស្គាល់លោកច្បាស់លាស់ <គាត់>ស្គាល់<លោក>តាំងមុន៧៥ <គាត់ឃើញលោកនៅ ស-២១>ហើយរហូតមក<>ទៀត <ខ្ញុំជឿថា លោកក៏បានរត់គេចខ្លួនជាមួយគាត់ចេញពី>ស-២១ <> តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយលោកបាទ។

**ស៖** ហើយលោកប្រាកដទេថា អ៊ឹង ប៊ិច នៅពេលដែលគាត់<នៅ>ស-២១ <>បានឃើញលោក ហើយ<គាត់>បានគ្រវីដៃដាក់លោកហ្នឹង តើលោកប្រាកដទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ជុំ ម៉ី៖**

**ឆ៖** បាទ ពិតប្រាកដណាស់ ដែលគេឲ្យខ្ញុំទៅធ្វើការនៅខាងក្រោយហ្នឹង អ៊ឹង ប៊ិច គាត់នៅជួសជុលឡាននៅខាងក្រោយហ្នឹង។ ហើយក្រឡេកឃើញខ្ញុំ គាត់រាដៃអត់ឲ្យខ្ញុំនិយាយរកគាត់ទេ ហើយខ្ញុំក៏អត់ហ៊ាននិយាយរកគាត់ដែរ។

[១៤:៣៣:២២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកមានបានប្រាប់អ្នកស៊ើបអង្កេតថា លោកខ្លាច លោកមិនហ៊ាននិយាយជាមួយ

លោក អ៊ឹង ប៊ុច <ទេ> ពេលនៅស-២១<នោះ>?

**ឆ៖** ខ្ញុំបាទខ្លាច កាលណាយើងនិយាយជាមួយគ្នា គេវ៉ៃយើងហើយ។

**ស៖** តើលោកអាចពន្យល់បានទេ ថាមានអ្វីកើតឡើងនៅពេលដែលលោក ហើយនិង អ៊ឹង ប៊ុច បានរត់គេចជាមួយគ្នា? តើ អ៊ឹង ប៊ុច ហ្នឹងគាត់ធ្វើយ៉ាងម៉េច? ថាតើគាត់នៅជាមួយលោករហូត ឬមួយក៏យ៉ាងម៉េចដែរ? តើលោកអាចប្រាប់បានទេថា អ៊ឹង ប៊ុច ហ្នឹងគាត់ធ្វើអីខ្លះនៅពេលនោះ?

**ឆ៖** អ៊ឹង ប៊ុច ហ្នឹងគាត់ធ្វើជាងជួសជុលឡាន។ ហើយពេលដែលរត់ចេញមកហ្នឹង គឺថាដល់រត់មកទាំងអស់គ្នា វាកៀរ កៀរឲ្យទៅអមលាំង។ ហើយពេលនោះយើងអត់ស្គាល់ថា អមលាំងហ្នឹងឯណាមួយ អមលាំងទេ យើងអត់ស្គាល់ទេ។ អ៊ីចឹងវាភ្ជង់យើងជាប់រហូតមកដល់អង្គស្នួលហ្នឹង ខ្ញុំបានជួបគ្រួសារខ្ញុំនៅហ្នឹង។ នារីៗប្រហែល១០នាក់ ម៉្លុំអង្គស្នួលហ្នឹង។ ពេលហ្នឹងហើយដែលខ្ញុំត្រូវជួបគ្រួសារខ្ញុំនៅហ្នឹង ទើបឆ្លងទន្លេបានពីរខែ។ ខ្ញុំសុំវាថា បងៗខ្ញុំសុំជួយបីកូនខ្ញុំផង ព្រោះខ្ញុំជួបគ្រួសារខ្ញុំ ហើយវាថា អើ ឲ្យបីទៅ។ ដល់ហើយខ្ញុំរៀបលើកកូនហ្នឹងបី គ្រួសារខ្ញុំប្រាប់ប៉ាអាភាព ឯងយកក្រម៉ាឲ្យមិត្តនារីម្នាក់ ដែលឆ្លងទន្លេនៅក្រោមដើមត្នោតហ្នឹង។ ខ្ញុំក៏បានយកក្រម៉ាហ្នឹងឲ្យមិត្តនារីឆ្លងទន្លេក្រោមដើមត្នោតហ្នឹង ហើយយើងធ្វើដំណើរឆ្លងកាត់ថ្នល់មកខាងជើងថ្នល់។ ពេលនុំងកងទ័ពរណសិរ្ស និងកងទ័ពវៀតណាមបាញ់ផ្តាច់មួយកំណាត់ហ្នឹង។ អ៊ឹង ប៊ុច, វ៉ាន់ ណាត ស្អីៗត្រឡប់មកក្រោយវិញ ខ្ញុំឡើងទៅជាមួយតាទួន ជាមួយ ប៊ូ ម៉េង ជាមួយ តាអេង អីៗឡើងទៅហួសហើយបាទ។

[១៤:៣៥:៥៣]

**ស៖** សំណួរបន្ថែមមួយទៀត ទាក់ទងទៅនឹង អ៊ឹង ប៊ុច លោកបាននិយាយអំពីគាត់យ៉ាងច្រើននៅសវនាការទី១ <នាថ្ងៃ>៣០ មិថុនា ឆ្នាំ២០០៩ គឺប្រតិចារឹក E3/7451 គឺនៅប្រហែលជាម៉ោង ០៩:៤៦:៤៧ គឺលោកបាននិយាយដូចតទៅនេះ៖ “បន្ទាប់មកយើងបានចាកចេញពីវត្តនោះ ប្រហែលជា១គីឡូម៉ែត្រពីវត្ត <ក្នុងពេល>យើង<>បន្តដំណើរ <>ពួកវាចាប់ផ្តើមបាញ់។ ពួកវាបាញ់មកលើគ្រួសារខ្ញុំ នៅពេល<យប់ ដែលមាន>ខែពេញវង់។ បន្ទាប់មកទៀត <ប្រពន្ធខ្ញុំបានប្រាប់ខ្ញុំឲ្យរត់ ពីព្រោះពួកវាបានបាញ់រះមកពួកយើង។ បន្ទាប់មកទៀត> តាអេង ក៏ត្រូវបានគេបាញ់ ហើយ តាអេង គាត់ដួល ហើយគាត់ប្រាប់ខ្ញុំថា គឺថានៅពេលដែលគាត់ដួលហ្នឹង គាត់ប្រាប់ឲ្យខ្ញុំរត់ទៅ ព្រោះទាហានវាបាញ់មកលើពួកយើងហើយ។” តាអេង ហ្នឹងគឺ អ៊ឹង ប៊ុច ហ្នឹងតើមែនទេ?

**ឆ៖** តាអេង ហ្នឹងផ្សេង, អ៊ឹង ប៊ុច ហ្នឹងផ្សេង មិនមែនដូចគ្នាទេ។ តាអេង ហ្នឹងគាត់ជាប់គុក

នៅទួលស្លែង គាត់គេចាប់ពីកំពង់ចាមមក ដល់គេឲ្យទៅអមលាំង ទៅជាមួយគាត់ហ្នឹង គាត់ទៅជាមួយខ្ញុំដែរ។ ហើយ អ៊ឹង ប៊ិច ហ្នឹងផ្សេង។ អ៊ឹង ប៊ិច ហ្នឹងគាត់ត្រឡប់មកវិញ គេបាញ់នៅត្រង់អង្គស្នួល គាត់ត្រឡប់មកវិញ។ ហើយខ្ញុំឡើងជាមួយ តាអេង ទៅ។ ពេលទៅដល់គេហៅថាវត្តស្រះធុលហ្នឹង គឺថាវាយប់ ៗរកសុំអង្ករគេដាំបាយហូប គេថាសួរមកពីណា ខ្ញុំថាមកបូក -- ខ្ញុំថាមកពីកន្លែងកាត់ដេរ។ អ៊ីចឹងស្រុកកំណើតនៅឯណា ខ្ញុំថានៅបូព៌ា។ អ៊ីចឹងពួកវាថា អ៊ីចឹងមិត្តឯងនៅហ្នឹងហើយ ចាំសុំសំបុត្រពីអង្គការបាន វាជូនទៅ។ ពេលនោះវាឲ្យយើងរៀបចំដេកនៅមុខសាលា ដេកនៅគ្រែមួយគ្នាបីនាក់។ ហើយយើងឃើញពួកវាហ្នឹងប្រហែលជា៣០-៤០នាក់ ទាហានហ្នឹង។ ដល់ប្រហែលជាម៉ោងដប់ម៉ោងអីហ្នឹងស្រាប់តែបាត់អស់រលីង។ មានឈ្លបម្នាក់គាត់នៅយាមជុំវិញខ្ញុំហ្នឹង នៅយាមកាំភ្លើងការ៉ាប៊ីនមួយដើមហ្នឹង ស្រាប់ប្រហែលជាម៉ោងដប់ពីរយប់ ស្រាប់តែឃើញពួកវាបីនាក់កាំភ្លើងបីដើម អាកាបីដើមហ្នឹងមកសួរអាឈ្លបយាមខ្ញុំហ្នឹង សួរអីណានេះដែលអ្នកបីនាក់ហ្នឹង ដែលត្រូវយកទៅសម្លាប់ចោលហ្នឹងនៅឯណា ហើយអាឈ្លបហ្នឹងថា នេះនៅដេកលើគ្រែហ្នឹង។ ពេលហ្នឹងខ្ញុំក្រោកអង្គុយឡើង កេះ តាអេង ឲ្យឡើង កេះគ្រួសារខ្ញុំឲ្យឡើង។ ហើយក៏វា--

[១៤:៣៩:០២]

**ស៖** សូមអរគុណលោកដើមបណ្ដឹង។ សូមទោសដែលខ្ញុំនិយាយកាត់លោក ប៉ុន្តែលោករៀបរាប់ពីហេតុការណ៍ហ្នឹងលម្អិត។ ដូច្នេះខ្ញុំគ្រាន់ចង់សួរលោកថា តាអេង ហ្នឹងគឺជាមនុស្សផ្សេងពី អ៊ឹង ប៊ិច។ អ៊ីចឹងតើ តាអេង ហ្នឹងឈ្មោះពេញគាត់ហ្នឹងឈ្មោះអីដែរ ប្រសិនបើ តាអេង ត្រូវបានគេឃុំនៅស-២១ ដែរ? ដូច្នេះតើលោកស្គាល់ឈ្មោះពេញរបស់ តាអេង ទេ?

**ឆ៖** ខ្ញុំបាទអត់បានស្គាល់ទេ។ តែគាត់ទៅកណ្ដាលផ្លូវ គាត់ប្រាប់ខ្ញុំថា គាត់ហ្នឹងឈ្មោះ អេង តែប៉ុណ្ណឹង។

**ស៖** ហើយគាត់នៅស-២១ ដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់នៅស-២១ ដែរ។

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយអំពី អ៊ឹង ប៊ិច គឺមនុស្សម្នាក់ដែលលោករត់ជាមួយ រត់គេចជាមួយដែរនោះ ហើយលោកក៏ដឹងច្បាស់ដែរ។ តើ អ៊ឹង ប៊ិច នេះគាត់ធ្លាប់បានផ្ដល់ភ័ស្តុតាង ឬក៏ផ្ដល់សក្ខីកម្មឲ្យតុលាការបដិវត្តន៍ដែលធ្វើការជំនុំជម្រះ ប៉ុល ពត, អៀង សារី នៅឆ្នាំ៧៩ដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំបាទអត់បានដឹងទេ លោកប្រធានអត់បានដឹងទេ។

**ស៖** លោកដើមបណ្ដឹង តើលោកដឹងទេ ថាតើ លៀប ចាម ហ្នឹងគឺជាអ្នកណាដែរ?

**ឆ៖** លៀប ចាម? លៀប ចាម ណាអត់បាន ខ្ញុំស្ដាប់អត់ច្បាស់ទេបាទ។

**ប្រធានអង្គជំនុំ៖**

មានៗឈ្មោះជាភាសាខ្មែរទេ ឲ្យមេធាវីជាតិអាចអានឈ្មោះហ្នឹងឲ្យច្បាស់លាស់បានដែរទេ?

[១៤:៤១:៤៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអភ័យទោសលោកប្រធាន ដោយសារតែយើងមានតែឯកសារជាភាសាអង់គ្លេស ប៉ុន្តែមិនអីទេ។ ខ្ញុំអាចជម្រាបបានថា ខ្ញុំនិយាយពីឯកសារ E3/2144 ជាពិសេសគឺ<មានតែ>ឯកសារ<ជាភាសាអង់គ្លេសទេ> ERN 00190231។ ខ្ញុំសូមសួរលោកអ៊ីចេះវិញ ខ្ញុំចង់សួរថាលោកស្គាល់ឈ្មោះ រុយ ណាក់កុង ដែរឬទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** ជម្រាបលោក អត់មានស្គាល់ឈ្មោះហ្នឹងទេ រុយ ណាក់កុង មិនដែលឮទេ។

**ស៖** ហេតុផលដែលខ្ញុំ<>សួរសំណួរទាំងអស់នេះទៅលោក គឺថា ដូចដែលខ្ញុំប្រាប់លោកអ៊ីចឹង អ៊ឹង ប៊ិច បានផ្ដល់នូវចម្លើយនៅចំពោះមុខចៅក្រមនៅក្នុងសវនាការជំនុំជម្រះ ប៉ុល ពត, អៀង សារី។ ហើយគាត់បានផ្ដល់សក្ខីកម្មនៅក្នុងថ្ងៃ២៥ មិថុនា ៧៩។ ហើយវាជារឿងគួរឲ្យភ្ញាក់ផ្អើលមួយនៅក្នុងចម្លើយរបស់គាត់នៅពេលនោះ ហើយខ្ញុំចង់ឲ្យ<លោក>ឆ្លើយប្រាប់យើងខ្ញុំ។ គាត់បាននិយាយដូចតទៅនេះ ហើយខ្ញុំសូមដកស្រង់នូវឯកសារជាភាសាអង់គ្លេសនៃសក្ខីកម្មរបស់គាត់។ គាត់បាននិយាយថា៖ “អ្នកនៅរស់រានមានជីវិតបួននាក់នៅគុកទួលស្លែងគឺមាន ទី១ អ៊ឹង ប៊ិច (គឺគាត់ខ្លួនឯងផ្ទាល់), ទី២គឺ លៀប ចាន់ <(ជាអ្នកឆ្លាក់)>, ទី៣ ណាត ជាអ្នកសិល្បៈ <និងអ្នកឆ្លាក់> និងទី៤ រុយ ណាក់កុង ជាជាង<ឈើ> គឺយើង<ទាំងបួននាក់បច្ចុប្បន្នធ្វើការជាមួយគ្នានៅក្នុងកងទី១>នៅ<>ភ្នំពេញ។ ហើយនៅក្នុងកថាខណ្ឌដដែល គាត់និយាយថា៖ កូន<ប្រុស>របស់ខ្ញុំនៅរស់រានមានជីវិតគឺឈ្មោះ អ៊ឹង វេងអៀង គាត់<ជានិស្សិត>ច្បាប់នៅ<មហាវិទ្យាល័យច្បាប់នៅ>ទីក្រុងភ្នំពេញ។” នេះគឺជាចម្លើយប្រាំពីរទំព័រ។ <លោកសាក្សី> យើង<បាននិយាយរួចមកហើយថា អ៊ឹង ប៊ិច> ស្គាល់លោកច្បាស់<ណាស់។ គាត់>ស្គាល់<លោក>តាំងពីមុន៧៥ <គាត់ឃើញលោក>នៅស-២១ ហើយ<គាត់បាន>រត់គេចជាមួយលោកផងដែរ។ ប៉ុន្តែនៅពេលដែលគេកោះហៅឲ្យគាត់<ជា>សាក្សី<ឲ្យផ្ដល់សក្ខីកម្ម>

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅក្នុងតុលាការថ្ងៃ២៥ មិថុនា ៧៩ គាត់បាននិយាយថា មានតែមនុស្សរស់នៅបួននាក់ប៉ុណ្ណោះ គឺគាត់មិនបាននិយាយពីឈ្មោះរបស់លោកទេ។ តើលោកអាចពន្យល់បានទេ ថាដោយសារហេតុផលអ្វីដែរ?

[១៤:៤៤:៥៨]

**ឆ៖** ឈ្មោះ វ៉ាន់ ណាត ហ្នឹងមាន មានឈ្មោះ វ៉ាន់ ណាត។ មិនមែន រុយកុង ទេ រុយ គង់ៗ។ តាគង់ ហ្នឹងគាត់ជាងឈើ បាទមាន។ ហើយ ចង ចាន់ ហ្នឹងក៏មាន ដែរ ហើយ ចង ចាន់, អៀម ចាន់ ប៉ុន្មាននាក់ហ្នឹងមានតើ នៅក្នុងហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណីលោក ជុំ ម៉ី ស្តាប់ឲ្យយល់បញ្ហា គឺឥឡូវលោកបានបញ្ជាក់រំឭកពីឈ្មោះពាក់ព័ន្ធនឹងសំណួរហើយ បានហើយ ប៉ុន្តែសូមលោកបញ្ជាក់ឲ្យច្បាស់លាស់ថា ចម្លើយរបស់គាត់ដែលគាត់ផ្តល់សក្ខីកម្មកាលពីខែ៦ ឆ្នាំ១៩៧៩នុ៎ង គឺមានមនុស្សរស់រានមានជីវិតពីស-២១ តែបួននាក់ទេអ្នកដែលនៅជាប់នៅឃុំឃាំងនៅទីនោះ។ ហើយការរៀបរាប់របស់លោកហ្នឹងគឺ -- របស់គាត់នុ៎ងមិនមានឈ្មោះលោកទេ។ តើលោកប្រតិកម្មទៅនឹងចម្លើយដែលគាត់បានផ្តល់សក្ខីកម្មកាលពីខែ៦ ឆ្នាំ១៩៧៩ចំពោះតុលាការបដិវត្តន៍កាលណោះដែលជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ប៉ុល ពត, អៀង សារី នោះ តើលោកប្រតិកម្មយ៉ាងម៉េច? ព្រោះថាមានតែបួននាក់ទេ ហើយការរៀបរាប់របស់គាត់ហ្នឹងគឺមិនមានឈ្មោះលោកទេ។

[១៤:៤៦:៣៦]

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំមានការជំទាស់ ប្រសិនបើយើងអានជាភាសាអង់គ្លេសទៅ គឺមានន័យថា បួននាក់ដែលរស់រានមានជីវិតពីគុកទួលស្លែង មានដូចជា។ ដូច្នេះបើតាម -- អ៊ីចឹងដាក់ បើយើងមើលតាមអង់គ្លេសទៅ គឺមានន័យថាអ៊ីចឹង ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីគាត់បាននិយាយហើយថាគាត់បែកពីអ្នកទាំងអស់ហ្នឹង។ អ៊ីចឹងចម្លើយហ្នឹងគឺជាចម្លើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៩។ អ្នកនៅរស់រានមានជីវិតហ្នឹងមិនអាចថាមានត្រឹមតែបួននាក់ទេ។ គាត់និយាយហ្នឹងតាមតែគាត់ដឹងទេ គាត់បែកពីអ្នកផ្សេងអស់ហើយ។ អ៊ីចឹងតាមដែលគាត់ដឹង គាត់គិតថាមានបួននាក់ ក៏ប៉ុន្តែគាត់ប្រហែលជាមិនដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅរស់រានមានជីវិតដែរ។ <តើគាត់ដឹងថាបុរសម្នាក់នេះនៅរស់ឬអត់? នេះជាសំណួរបើក។ ខ្ញុំមិនគិតថាសំណួរគួរស្នួរកំហិតដែលថាមានអ្នករស់រានមានជីវិតតែបួននាក់នោះទេ។>

គាត់ថាមានប្អូន ដែលមានឈ្មោះដូចតទៅ ហើយគាត់ក៏មិនបានបញ្ជាក់ថា <គ្មាន>អ្នកផ្សេងទៀត <ដែរ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបញ្ចេញប្រតិកម្មគឺថា ភាសាអង់គ្លេសបានបញ្ជាក់ច្បាស់ គឺថា "អ្នកនៅរស់រានមានជីវិតពីគុកទួលស្លែង<មានប្អូននាក់>គឺ"។ <>យើងបានកំណត់ជាច្រើនច្បាស់លាស់មកហើយថា ដើមបណ្ដឹងគាត់ស្គាល់ អ៊ឹង ប៉ិច ច្បាស់។ ហើយអង្គជំនុំជម្រះក៏ដឹងអំពី ណាត ដែរ ប៉ុន្តែ<>នៅពេលនេះ<អាចនិយាយបានថា គាត់នៅក្រោមសម្បថផងដែរ> នៅ<ក្នុង>តុលាការថ្ងៃ២៥ មិថុនា ៧៩ ហ្នឹង<>គាត់មិនបាននិយាយអំពីឈ្មោះនេះ<ទេ>។ <ឥឡូវនេះ ប្រហែលជាត្រូវការការពន្យល់ចំពោះករណីនេះហើយ។> វាអាចមានហេតុផលអាចថាគាត់ភ្លេចឈ្មោះ ឬមួយក៏ថាអាចថានៅពេលក្រោយមកទៀតគាត់ជួបដើមបណ្ដឹងមួយនេះ ហើយគាត់ថា សូមទោសខ្ញុំភ្លេចឈ្មោះលោកអីអ៊ីចឹងទៅ។ <>ខ្ញុំ<គិត>ថា <>ដើមបណ្ដឹង<រដ្ឋប្បវេណីគួរតែ>មានប្រតិកម្ម<ទៅនឹងមូលហេតុដែលអត់មានឈ្មោះគាត់>។

[១៤:៤៨:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើការតាំងសំណួរនេះ។ សំណួរនេះគឺសមស្របក្នុងការសួរហើយ។ ហើយលោក ជុំ ម៉ី សូមលោកឆ្លើយប្រតិកម្មតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយសហមេធាវីអន្តរជាតិ មេធាវីការពារក្ដីលោក នួន ជា អម្បាញ់មិញនេះ ប្រសិនបើលោកចាំសំណួរ គឺលោកឆ្លើយតប។ ដូចលើក យើងលើកយើងបញ្ជាក់អំមិញហើយថា អ៊ឹង ប៉ិច ហ្នឹងគាត់ឆ្លើយកាលពីខែ៦ ឆ្នាំ១៩៧៩ នៅចំពោះមុខតុលាការបដិវត្តន៍ជំនាន់នោះ គឺឆ្លើយថា គាត់ដឹងហ្នឹង គឺគាត់អ្នករស់រានមានជីវិត មានតែប្អូននាក់ទេ។ ហើយតើនៅក្នុងនុ៎ងគឺមាន អត់ឮឈ្មោះលោកទេ។ តើលោកប្រតិកម្មនឹងចម្លើយនោះយ៉ាងដូចម្ដេច?

**លោក ជុំ ម៉ី៖**

**ឆ៖** ចំពោះសំណួរនេះ ខ្ញុំមិនប្រតិកម្មអីទេ ព្រោះ អ៊ឹង ប៉ិច គាត់និយាយហ្នឹងនិយាយពេលដែលគេបាញ់ផ្ដាច់ត្រង់អង្គស្នួលហ្នឹង គាត់រត់មកប៉ុន្មាននាក់ហ្នឹង រត់មកក្រោយវិញ។ ហើយនៅសល់ប៉ុន្មាននាក់ឡើងទៅអមលាំងហ្នឹង គឺថាគេសម្លាប់អស់ទៅ។ និយាយរួមមកទាំង អ៊ឹង ប៉ិច មកទាំងអីជួបជុំគ្នានៅសល់បានប្រាំពីរនាក់ៗ។ ឥឡូវគាត់ស្លាប់អស់ប្រាំ នៅសល់តែពីរទេ។ អ៊ឹង ប៉ិច គាត់និយាយហ្នឹង

និយាយតែពេលដែលគាត់រត់ត្រឡប់មកវិញ អ៊ឹង ប៊ិច អត់មានឡើងទៅដល់អមលាំងទេ ទៅដល់តែអង្គស្នួលជាមួយ វ៉ាន់ ណាត ហ្នឹងរត់មកវិញ។ ហើយ រុយ គង់ អីៗហ្នឹងរត់មកវិញ។ ប្អូននាក់ហ្នឹងគាត់និយាយត្រឹមត្រូវហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីនិងដប់នាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:១៣នាទី)*

[១៥:១៣:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <សូមអរគុណលោកប្រធាន។ លោកដើមបណ្តឹងរដ្ឋប្បវេណី មុនពេលខ្ញុំចូលទៅដល់ព្រឹត្តិការណ៍>ឆ្នាំ១៩៨១ <>ខ្ញុំសូមសួរសំណួរលោកមួយចំនួនទៀតសិន ទាក់ទងទៅនឹងសវនាការកាត់ទោស ប៉ុល ពត, អៀង សារី ឆ្នាំ១៩៧៩។ តើខ្លួនលោកផ្ទាល់នេះ មានបានចូលរួមស្តាប់សវនាការដូចជាអ្នកមកតាមដានសវនាការនេះជាដើម មានបានចូលទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** កាត់ទោស អៀង សារី ហើយពីណាទៀតខ្ញុំស្តាប់អត់បាន ប៉ុន្តែខ្ញុំសូមជម្រាបអ៊ីចេះ លើកទី១ ដំបូងខ្ញុំអត់បានចូលរួមទេ ខ្ញុំទើបតែចូលរួមលើកទី២ហ្នឹងទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសុំសួរបញ្ជាក់ឡើងវិញ ខ្ញុំនិយាយអំពីការកាត់ក្តីនៅក្នុងឆ្នាំ១៩៧៩ ជំនុំជម្រះទៅលើ ប៉ុល ពត និង អៀង សារី គឺនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍កម្ពុជា ដែលជាការជំនុំជម្រះកំបាំងមុខ ដោយមិនមានវត្តមាន ប៉ុល ពត និង អៀង សារី ទេ។ អ៊ីចឹងសំណួររបស់ខ្ញុំនេះ តើលោក<>កាលហ្នឹងមានឱកាសបានចូលរួមទៅស្តាប់ចៅក្រម រដ្ឋអាជ្ញា និងមេធាវី តតាំងគ្នានៅក្នុងបន្ទប់សវនាការក្នុងនាមជាអ្នកមកចូលទស្សនាដូចបងប្អូនយើងអ៊ីចេះដែរទេ?

[១៥:១៥:៤១]

**ឆ៖** ខ្ញុំអត់បានមកចូលរួមទេ ជម្រាបលោកប្រធាន អត់បានមកចូលរួមទេ។

**ស៖** ចុះតើលោកធ្លាប់ឮសួរ ឬក៏ធ្លាប់រកឃើញថា ហេតុអ្វីបានជាគេកោះហៅ អ៊ឹង ប៊ិច ឲ្យមកធ្វើជាសាក្សីឆ្លើយពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខស-២១ ឯលោកវិញមិនត្រូវបានតុលាការកោះហៅ?

**ឆ៖** ខ្ញុំបានជម្រាបលោកអ៊ីចេះបាទ គឺថាពេលដែលគេហៅ អ៊ឹង ប៊ិច មកនេះហ្នឹង គឺថាខ្ញុំនៅខាងគមនាគមន៍ ខ្ញុំអត់បានមកចូលរួមគេទេ។

**ស៖** ដូចដែលខ្ញុំបានជម្រាបរួចមកហើយ ឥឡូវខ្ញុំចូលទៅដល់ព្រឹត្តិការណ៍ឆ្នាំ៨១។ លោកដើមបណ្តឹងរដ្ឋប្បវេណីលោកបានចូលរួមនៅក្នុងការ<>រៀបចំជួសជុលកសាងឡើងវិញ <ដែលគេហៅថា ស-២១ ជាមួយឌុច និងអ្នកផ្សេងៗទៀត> គឺឯកសារ E3/5765។ <ERN ជាភាសាអង់គ្លេសគឺ 00198003 និងចំណុច ៨.២។ ខ្ញុំអត់មានលេខ ERN ជាភាសាខ្មែរ និងជាភាសាបារាំងទេនៅពេលនេះ។ លោកដើមបណ្តឹងរដ្ឋប្បវេណី គេបានសួរលោកនូវសំណួរជាច្រើន ហើយបើតាមកថាខណ្ឌ ៨.២ ហើយខ្ញុំសូមអានជូនលោក-->

**អ្នកបកប្រែ៖**

លោកប្រធានអម្បាញ់មិញក្បាលមីក្រូអត់ដើរ ដូច្នេះបាត់ការបកប្រែទាំងលេខ ERNទាំងអស់ ដោយសារប៊ូតុងអត់ដើរ។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អំមិញហ្នឹង គឺអ្នកបកប្រែស្តាប់ភាសារបស់លោកនិយាយអត់បានទេ ដោយសារមានបញ្ហាក្បាលមីក្រូហ្នូន។ ដូច្នេះសូមលោករៀបចំនូវសំណួររបស់លោកសាជាថ្មីម្តងទៀត សំណួរចុងក្រោយរបស់លោកអម្បាញ់មិញនេះ តាំងពីដើមទៅ តាំងពីដើម។

[១៥:១៨:១៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទលោកប្រធាន។ លោកដើមបណ្ដឹងរដ្ឋប្បវេណីគឺថាលោកបានចូល<រួម>នៅក្នុងការរៀបចំ<ជួសជុល>ឡើងវិញនៅ<ស-២១ លោកអាចចាំរឿងនោះ ព្រោះវាកើតឡើង>ក្នុងឆ្នាំ២០០៨ គឺឯកសារ E3/5765 ត្រង់កថាខណ្ឌ<៨.២> ដែលជារបាយការណ៍មកពីសហចៅក្រមស៊ើបអង្កេត ដែលឯកសារនេះនិយាយថា៖ "នៅពេលដែលឲ្យចង្អុលបង្ហាញទៅរូបថត ជុំ ម៉ី គាត់ឆ្លើយថា គឺរូបថតនេះថតដោយអ្នក<ថតរូប>ជនជាតិអាល្លឺម៉ង់ នៅមុខអគារ "សេ" នៅក្នុងឆ្នាំ១៩៨១ គឺរូបថតលេខរៀងទី៣៥ ហើយលោកបានចង្អុលបង្ហាញលោក វ៉ាន់ ណាត, ប៊ុនឡេង, តាគង់ ហើយនិងខ្លួនលោកផ្ទាល់។ ហើយលោកបានបន្តឆ្លើយទៅទៀតថា អ្នកថតរូបជនជាតិអាល្លឺម៉ង់នេះបានមកប្រមូលរូបថត ដើម្បីបង្ហាញជូនអង្គការសហប្រជាជាតិ។ <ដោយសារពួកគេមិនជឿនូវអ្វីដែលគាត់និយាយនោះ>គាត់បានត្រឡប់មកវិញ <ហើយបាន>ថតរូប<ថ្មី រួមទាំងរូបថតនេះផង>។" បញ្ចប់ការដកស្រង់។ ឥឡូវខ្ញុំសូមបង្ហាញរូបថតនេះឲ្យលោកមើល ដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញឲ្យលោកមើលរួចមកហើយនៅក្នុងឆ្នាំ២០០៨។ ខ្ញុំយល់ឃើញថាលោកក៏កំពុងមើលរូបថតនេះហើយ។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញរូបថតដដែលនេះទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមើល ហើយក៏សូមបង្ហាញនៅលើអេក្រង់ផងដែរ។ គឺឯកសារE3/9431 ERN អង់គ្លេស 00198064។ លោកដើមបណ្ដឹងរដ្ឋប្បវេណី នេះជារូបថតសខ្មៅទេ គឺរូបថតនៅចំពោះមុខលោកនេះឯង។ តើលោកនៅចាំទេ តើរូបថតនេះ ត្រូវបានគេយកមកបង្ហាញឲ្យលោកមើល គឺថាត្រូវបានសហចៅក្រមស៊ើបអង្កេតមកបង្ហាញឲ្យលោកមើលនៅក្នុងឆ្នាំ២០០៨ លោកនៅចាំទេ?

[១៥:២០:៤៤]

**ប្រធានអង្គជំនុំ៖**

មាននៅលោក ជុំ ម៉ី?

កុំអាលទាន់! កុំអាលទាន់លោក ជុំ ម៉ី កុំអាលទាន់! ចាំមើលនៅគាត់បង្ហាញ ហើយពិនិត្យមើលដូចគ្នា ឯកសារដូចគ្នាដែលគាត់លើកបង្ហាញនៅក្នុងដៃ លោកចាំមើល ផ្ទៀងផ្ទាត់មើល ចាំមើលឯកសារនុ៎ងណា។ ហើយៗខាងប្រព័ន្ធសោតទស្សន៍ហ្នឹង អាចផ្សាយនូវរូបភាពនៅលើអេក្រង់ទូរទស្សន៍បានដែរឬទេ?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកអាចរៀបរាប់ឈ្មោះ មនុស្សទាំងប្រាំពីរនាក់នៅក្នុងរូបថតនេះ ជូនអង្គជំនុំជម្រះបានទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** បាទ ខ្ញុំបាទរៀបរាប់បាន។ ខ្ញុំចង់រៀបរាប់ រូបខ្ញុំផ្ទាល់ ខ្ញុំបាទ ជុំ ម៉ី ជា*មេការនិចស្យាង*។ បន្ទាប់មក ប៊ូ ម៉េង ជាជាងឈើ។ ហើយទី៣ គឺថា អ្នកឆ្លាក់រូប ៗរូបក្បាល ប៉ុល ពត ហ្នឹង។ ហើយទី៤ វ៉ាន់ ណាត អ្នកគូររូប។ ទី៥ ប៊ូ ម៉េង អ្នកគូររូបដែរ។ អានេះ ថង ចាន់ នេះគាត់អ្នកបកប្រែភាសាយៀកណាម។ បន្ទាប់មកបាន អ៊ឹង ប៊ិច ហ្នឹងក៏ជា*មេការនិចស្យាង*ដូចខ្ញុំដែរ។

[១៥:២២:៤៣]

**ស៖** ដើម្បីឲ្យច្បាស់១០០ភាគរយតែម្ដង។ ខ្ញុំក៏បានផ្ដល់ទៅលោក ក៏ដូចជា ភាគីទាំងអស់ផងដែរ ក៏ដូចអង្គជំនុំជម្រះរួចមកហើយដែរ លោកប្រធាន គឺនិយាយពីឯកសារប្អូនរបស់ខាងផ្នែកអាល្លឺម៉ង់ <ខាងកើត>ដែលជាអ្នករៀបចំឯកសារនេះ គឺគេហៅ <"ឌី អង្គការ"> ឌី.អាយ.អ៊ី <ហើយនិង "អង្គ-ការ"> ឯកសារ E3/3095R ជាឯកសារដែលយើងខ្ញុំ<បានដាក់បញ្ចូល ឬ>បានស្នើសុំដាក់បញ្ចូល<> ទៅក្នុងសំណុំរឿងហើយ។ ដូច្នេះគឺយើងខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញនូវឯកសារនេះ<លើអេក្រង់> ហើយខ្ញុំយល់ឃើញថ ខាងផ្នែកអង្គភាពសោតទស្សន៍នេះក៏បានត្រៀមរួចរាល់ហើយ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ប្រហែលយើងចាប់ផ្ដើមជាមួយនឹងលេខរៀងទី១មុន ឯកសារលេខរៀងទី១។

**ប្រធានអង្គជំនុំ៖**

លោក ជុំ ម៉ី យើងមើលឯកសារកូល័រ ឯកសារដែលមានកូល័រនេះ ចាប់ផ្ដើមពីទំព័រទី១ អំមិញៗ អាអំមិញរួចហើយ អាសខ្មៅអំមិញរួចហើយណ៎ា។ ឥឡូវយើងចាប់បន្តអាទី១ ដែលនៅឯកសារពណ៌ណ៎ា។ សូមលោកពិនិត្យមើល ហើយចាំឆ្លើយតបនឹងសំណួរ ហើយសូមឲ្យផ្នែកខាងសោតទស្សន៍ចាក់ផ្សាយ ផ្សព្វផ្សាយនូវឯកសារនេះ និង ជាបន្តបន្ទាប់តាមសំណើសុំរបស់មេធាវីការពារក្ដីលោក នួន ជា លោកមេធាវី វ៉ិចទ័រ កូប៉េ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវយើងចាប់ផ្ដើមជាមួយរូបថតនេះតែម្ដង លោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅខាងឆ្វេងដៃនេះ ជារូបលោកមែនទេ?

[១៥:២៥:០៦]

**លោក ជុំ ម៉ឺះ**

**ឆ៖** ឆ្វេងដៃរូបខ្ញុំបាទ។ បន្ទាប់មក តារុយ គង់ៗ គាត់អ្នកជាងឈើ។

**ស៖** ដូច្នេះសូមបង្ហាញរូបថតទី២ ចុះរូបថតទី២ ដែលមានមនុស្សពីរនាក់នេះ អ្នកទាំងពីរនេះជាអ្នកណា? លោកដើមបណ្តឹងរដ្ឋប្បវេណី លោកមើលលើអេក្រង់ក៏បានដែរ ពីព្រោះថារូបថតបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រហើយ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើរូបថតដែលនៅលើអេក្រង់នេះជាអ្នកណា?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន អេក្រង់នោះអត់មានបញ្ចេញរូបទេ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី លោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រហែលជាមានបញ្ហាជាមួយនឹងអេក្រង់ ប្រហែលជាខ្ញុំសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូមមើលរូបថតពណ៌នេះផ្ទាល់តែម្តង និងបញ្ជាក់មើលថាតើរូបថតនេះ គឺជាមនុស្សដែលគាត់ទើបតែបញ្ជាក់ឈ្មោះនៅលើរូបថតសខ្មៅមុននេះ ឬក៏ខុសគ្នាតែប៉ុណ្ណោះឯង។

[១៥:២៧:២៣]

**ប្រធានអង្គជំនុំ៖**

បាទ ត្រឹមត្រូវហើយ ប៉ុន្តែទំនងជាការរៀបចំលំដាប់នៃលេខឯកសារហ្នឹងវាខុសឆ្គាស់គ្នារវាងលោកបង្ហាញ ហើយនិងឯកសារដែលចែកជូនទាំងចៅក្រម ហើយភាគីដទៃទៀត វាមានការខុសគ្នា លោកបង្ហាញទី២ ឯកសារនៅទី៣ អីចឹង។ ប៉ុន្តែឥឡូវយើងបង្ហាញរូបហើយ គឺរូបមនុស្សពីរនាក់ លោក ជុំ ម៉ី លោកមើល ហើយលោកអាចប្រាប់ អាចស្គាល់ដែរទេ ហើយលោកពីរនាក់ហ្នឹងឈ្មោះអី?

ឥឡូវដកឯកសារ រៀបចំឯកសារហើយឲ្យគាត់អីចេះ យកទៅវិញ ហើយជួយរៀបគាត់ បង្ហាញមួយម្តងទៅ ដាក់ឲ្យចេញផុតមក ដោះហើយដាក់មួយម្តង ហុចមួយណា ដែលថាពាក់ព័ន្ធនឹងសំណួរហ្នឹង ឲ្យគាត់ពិនិត្យមើល ហើយឆ្លើយ ហើយរួចចាំហុចមួយទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកប្រធានដើម្បីឲ្យដំណើរការយើងលឿននោះ គ្រាន់តែសួរថាតើមនុស្សនៅលើរូបថត

ខ្ញុំសួរសរុបតែម្តងថា មនុស្សដែលមានរូបនៅលើរូបថតពណ៌នេះ គឺជាមនុស្សទាំងប្រាំពីរនាក់ដែលគាត់រៀបរាប់ឈ្មោះ នៅក្នុងរូបថតសខ្មៅនេះ ឬក៏មិនមែនទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** រូបថតសខ្មៅនេះ វាខុសពីមុន។ ពីមុនគាត់ថតក្មេងបាទ ក្មេងៗ ដូចនេះខ្ញុំមិនច្បាស់ទេ ដូចជា វ៉ាន់ ណាត នេះ អត់ច្បាស់ទេ តែគាត់នៅក្មេង។ តែបើខាងនេះ យើងអត់ច្បាស់ទេ ពីរនាក់ហ្នឹង បាទ អត់ច្បាស់ទេ។ យើងអត់ប៉ានឆ្លើយទេ ព្រោះអាពេលនោះ គាត់ថតខុសពីប្រាំពីរនាក់ហ្នឹង ខុសគ្នាៗ ស-ខ្មៅ។

[១៥:២៩:៤៥]

**ស៖** ខ្ញុំមិនទាន់យល់បានច្បាស់ទេ លោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវខ្ញុំសូមជម្រាបទៅលោកថា រូបថតពណ៌ទាំងអស់នេះ គេហៅថា ជារូបថតនៃខ្សែភាពយន្តឯកសារដែលបានថតនៅក្នុងឆ្នាំ៨១ ឬក៏មុនឆ្នាំ១៩៨១បន្តិច។ <ដូច្នេះរូបថតពណ៌នោះ ក៏ត្រូវបានថតនៅពេលជាមួយគ្នានោះដែរ។> តើលោកនៅចងចាំ ថានៅពេលមួយនោះ មានជនជាតិអាល្លឺម៉ង់<ខាងកើត>ជាអ្នកថតរូប មកថតរូបស-ខ្មៅ ហើយក្រោយមក គេហៅថា ក្រុមកាមេរ៉ានោះ គឺមកពីអាល្លឺម៉ង់ខាងកើត ក៏បានមកថតខ្សែភាពយន្តឯកសារ ដែលក្នុងនោះ គឺថា អ៊ឹង ប៊ុច បានឆ្លើយយ៉ាងវែងនៅពេលនោះ។ តើលោកមានចាំទេ ថាក្រុមកាមេរ៉ាវីដេអូ<មកពីអាល្លឺម៉ង់ខាងកើត>នេះ បានមកថតភាពយន្តឯកសារក្នុងឆ្នាំ១៩៨១?

**ឆ៖** ខ្ញុំបាទ ថតអាខ្សែវីដេអូ៨១ហ្នឹង ខ្ញុំមិនបានចាប់អារម្មណ៍ទេ មិនបានចាប់អារម្មណ៍ទេ។ មិនដឹងជាអាល្លឺងម៉ង់ គាត់ថតពីឆ្នាំណាៗ ខ្ញុំអត់បានដឹងទេ។ តែខ្ញុំដឹងតែរូបប្រាំពីរនាក់នេះគឺ តាអ៊ឹង ប៊ុច គាត់ទៅហៅខ្ញុំមកថតនៅទួលស្លែង។ ពេលហ្នឹងមានអាល្លឺម៉ង់ខាងកើត គឺថាទីក្រុងប៉ែកឡាំងហ្នឹង គាត់មកថតបានប្រាំពីរនាក់ហ្នឹង បាទ។

**ស៖** វាពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេស ប៉ុន្តែយ៉ាងណាក៏លោកមានរូបនៅក្នុងខ្សែភាពយន្តឯកសារហ្នឹងដែរ។ ក្រុមកាមេរ៉ាមែនទាំងអស់នេះ បានថតលោកដែរ ក៏ប៉ុន្តែខ្ញុំសួរសំណួរតែម្តង។ តាមរយៈសហចៅក្រមស៊ើបអង្កេត លោកបានឆ្លើយដូចខ្ញុំដកស្រង់អ៊ីចឹង “អ្នកថតរូបជនជាតិអាល្លឺម៉ង់បានមកប្រមូលរូបថតដើម្បីយករូបថតទាំងអស់នេះ ទៅបង្ហាញជូនអង្គការសហប្រជាជាតិ។ ដោយសារថាគេមិនជឿនូវអ្វីដែល<គាត់>និយាយ <គាត់ក៏>មកថតរូបសាជាថ្មីម្តងទៀត <រួមមានទាំងរូបនេះផងដែរ>។” <នេះបើតាមឯកសារនេះ> តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ តើហេតុម៉េចបានជា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកថតរូបជនជាតិអាល្លឺម៉ង់ខាងកើតនេះ មិនជឿនូវអ្វីដែលលោកបានប្រាប់គេនៅលើកទី១?

[១៥:៣២:៤៣]

**ឆ៖** ខ្ញុំ ដែលខ្ញុំអត់បានច្បាស់លាស់ប៉ុន្មានទេ គ្រាន់តែដឹងសើៗថា អាល្លឺម៉ង់ខាងកើតហ្នឹង មុនដំបូង មកថតបានតែឆ្អឹង បានតែស្អី អាលលាដ៍ក្បាលស្អីៗហ្នឹងទេ។ ថតយកទៅឲ្យអង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិគេអត់ជឿទេ។ ហ្នឹងអាល្លឺម៉ង់ខាងកើតហ្នឹង វាត្រឡប់មកវិញ។ ត្រឡប់មកវិញ មកប្រមូលបានគ្នាប្រាំពីរនាក់ហ្នឹង ទាំង អ៊ឹង ប៉ិច, គាគង់, ចេង ចាន់, វ៉ាន់ ណាត ស្អីៗ ប្រាំពីរនាក់ហ្នឹង ថតទៅមួយសាទៀត។ ថតទៅមួយសាទៀត បានអង្គការសហប្រជាជាតិ គេជឿ បាទ។ អង្គការសហប្រជាជាតិ គេជឿ ថាវាមានការកាប់សម្លាប់មែន។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកនៅចាំទេថា នៅពេលដែលអ្នកថតភាពយន្តឯកសារថតរូបលោក នៅឆ្នាំ៨១នោះ គឺមនុស្សបួននាក់ នៅក្នុងចំណោមប្រាំពីរនាក់នេះ ត្រូវបានគេសួរឲ្យប្រាប់អ្នកថតវីដេអូភាពយន្តឯកសារនូវអ្វីដែលបានកើតឡើងនៅ ស-២១ ចំពោះអ្នកទាំងអស់នេះ។ តើលោកនៅចាំថា អ៊ឹង ប៉ិច, ប៊ូ ម៉េង, ណាត ទាំងអស់នេះ បានប្រាប់ទៅអ្នកថតខ្សែភាពយន្តនេះ ថាមានអ្វីកើតឡើងចំពោះពួកគាត់នោះដែរឬទេ នៅពេលដែលពួកគាត់ត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១នោះ?

**ឆ៖** ខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាថា ខ្ញុំអត់បានមកចូលរួមជាមួយពួកអស់ហ្នឹងទេ គ្រាន់តែ អ៊ឹង ប៉ិច ហ្នឹងគាត់ហៅខ្ញុំមកថត នូវគ្នាប្រាំពីរហ្នឹង។ តែអារឿងបួននាក់នេះ ខ្ញុំអត់បានដឹង បានឃើញទេ។ ព្រោះក្រោយមក ស្រាប់តែឃើញចេញអារូបថតកូល័រហ្នឹងមកនេះ ខ្ញុំអត់បានដឹងទេ។ ខ្ញុំដឹងតែប្រាំពីរនាក់ហ្នឹងទេ។

[១៥:៣៥:១៦]

**ស៖** ដូច្នេះលោកមិនចាំទេថា អ្នកថតភាពយន្តមកពីអាល្លឺម៉ង់ខាងកើតហ្នឹងគឺបានសាកសួរទៅអ្នកដទៃទៀតអំពីការឃុំឃាំងខ្លួននៅស-២១នោះ គឺលោកមិនបានដឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងមែន បាទ។

**ស៖** តើលោកបានដឹង ឬក៏បានរកឃើញ ឬក៏ថាលោកដឹងទេថាហេតុអ្វីបានជា<អ្នក>ថតរូបអាល្លឺម៉ង់ខាងកើតហ្នឹងមិនបានសួរលោក ឲ្យលោករាប់អំពីដំណើររឿងរបស់លោក?

**ឆ៖** ខ្ញុំអត់បាន--

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតបដើមបណ្ដឹងរដ្ឋប្បវេណី!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សំណួរនេះជាសំណួរដែលនាំឱ្យសាក្សីឆ្លើយស្មានហើយពាក់ព័ន្ធទៅនឹងមូលហេតុអីបានជាក្រុមអ្នកថតរូបអាល្លឺម៉ង់គាត់ ហើយសួរតែអ្នកផ្សេងនោះ។ គាត់មិនអាចឆ្លើយស្មានពាក់ព័ន្ធនឹងចំណុចនេះបានទេ។ ដើមបណ្ដឹងរដ្ឋប្បវេណី គាត់អាចឆ្លើយអំពីអ្វីដែលពាក់ព័ន្ធនឹងគាត់។ គេសួរគាត់ ឬក៏មិនសួរគាត់ មិនអាចសួរគាត់ជំនួសឱ្យអ្នកថតកុននោះទេ។

[១៥:៣៦:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនបានអញ្ជើញឱ្យដើមបណ្ដឹងរដ្ឋប្បវេណី គាត់ធ្វើការឆ្លើយដោយស្មាននោះទេ គឺយើងចង់ឱ្យគាត់បញ្ជាក់<ថាតើ>គាត់ដឹង<ទេ ហេតុអ្វីមនុស្សបួននាក់ផ្សេងទៀត ដែលមានក្នុងរូបនេះត្រូវបានគេសុំឱ្យនិយាយអំពីការឃុំខ្លួនរបស់ពួកគេ> ហើយហេតុអីបានជាផលិតកររូបនោះមិនសុំឱ្យលោក ជុំ ម៉ី ហ្នឹងគាត់បង្ហាញពីហេតុការណ៍ រៀបរាប់ពីហេតុការណ៍ដែលបានកើតឡើងនោះ។ ខ្ញុំមិនមែនសួរឱ្យគាត់ឆ្លើយទៅស្មានៗទេ។ <ខ្ញុំសួរគាត់ថា តើគាត់ដឹងពីមូលហេតុទេ។ បើគាត់មិនដឹងទេ> មិនជាបញ្ហាទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសាក្សី -- លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចឆ្លើយតបនឹងសំណួរហ្នឹងបានណ៎ា។ សំណួរហ្នឹងសមស្របនឹងសួរហើយ។

**លោក ជុំ ម៉ី៖**

**ឆ៖** ខ្ញុំគ្រាន់តែជម្រាបប្រាប់គាត់អ៊ីចេះ ជម្រាបប្រាប់គាត់ថា រូបថតស-ខ្មៅប្រាំពីរនាក់នេះ ខ្ញុំជម្រាបគាត់បាន។ តែរូបថតកូល័រនេះ ខ្ញុំអត់ជម្រាបគាត់បានទេ។ ដូចរូបនេះអី ខ្ញុំដូចជាស្រពេចស្រពិលណាស់ រូបនេះបាទ មើលអត់ច្បាស់លាស់ទេ។ មិនមែនដូចរូប វ៉ាន់ ណាត ពិតប្រាកដស្អី។ យើងអត់បាននេះទេ។ បើរូបស-ខ្មៅនេះ ខ្ញុំអាចជម្រាបគាត់បាន។ ហើយណាមួយខ្ញុំក៏វាមានបញ្ហាអារឿងភ្នែកបន្តិចផង បាទ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៣៨:២៥]

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែអំមិញ យើងបានស្តាប់លោក ជុំ ម៉ី បានឆ្លើយបញ្ជាក់លើរូបថតពណ៌ទី១នេះ។ លោកបានឆ្លើយបញ្ជាក់យ៉ាងច្បាស់លាស់ហើយ គឺលោកស្គាល់។ ឈ្មោះលោកគឺ ជុំ ម៉ី ហើយនិងមនុស្សម្នាក់ទៀត គឺ រុយ គង់។ លោកបានឆ្លើយសំណួរនូវឯកសារទាំងបួន ក្នុងចំណោមឯកសារ -- ទាំងបួននេះគឺឯកសារទី១ លោកបានឆ្លើយច្បាស់ចំពោះរូបថតខ្លួនលោក។ ហើយនៅក្នុងឯកសារនេះគឺព្រីនចេញពីខ្សែភាពយន្តដែលថតឡើងដោយអ្នកភាពយន្តឯកសាររបស់អាល្លឺម៉ង់ខាងកើតក្នុងពេលជាមួយគ្នា។ អ៊ីចឹងហើយបានតែសំណួរថា បន្តទៅទៀតហ្នឹង សួរថា លោកបានចូលរួមនៅក្នុងសកម្មភាពនៃការងារហ្នឹងទេ? លោកថា អត់ទេ។ អ៊ីចឹងគ្រាន់សំណួរសួរបន្តទៀត ហេតុអីបានជាលោកមិនបានចូលរួម? ហើយវាអាចមានបញ្ហាពាក់ព័ន្ធនឹងរូបថតរបស់លោក ដែលលោកមានដូចគេដូចឯងដែរ។ គ្រាន់ពីរនាក់នេះនែ៎ ដែលលោកថតជាមួយនឹង រុយ គង់។ លោកបានឆ្លើយរួចហើយថា ពិតជារូបលោក។ លោកយល់ទេ ឮយល់បញ្ហាទេឥឡូវហ្នឹង? គ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់លាស់ពីបញ្ហាហ្នឹង។ រឿងថាលោកបានចូលរួមនៅក្នុងការដើរតួរ ឬក៏បង្ហាញខ្លួននៅក្នុងអំឡុងពេលនៃការដែលអ្នកខាងភាពយន្តអាល្លឺម៉ង់ខាងកើតមកថតពេលនោះដែរឬទេ? ហើយបើអត់ទេ ហេតុអីបានជាមិនបានចូលរួម?

**លោក ជុំ ម៉ី៖**

**ឆ៖** ពេលនោះគឺថា ក្នុងប្រាំពីរនាក់ហ្នឹង ខ្ញុំចូលរួមបាទ តែបួននាក់នេះដែលថតក្នុងខ្សែភាពយន្តខ្ញុំអត់បានចូលរួមទេ។ ខ្ញុំអត់បានចូលរួមទេ អាហ្នឹងហើយដែលខ្ញុំថា ខ្ញុំសំដៅយកតែប្រាំពីរនាក់ហ្នឹងទេ ដែលខ្ញុំចូលរួមហើយក៏ខ្ញុំចាំច្បាស់ដែរអាហ្នឹង រូបប្រាំពីរនាក់ហ្នឹង។ ហើយរូបថតនេះដែលមាន តាគង់ អី គាត់ឈរជិតខ្ញុំ រូបថតកូល័រហ្នឹងខ្ញុំមើលអត់ចង់ច្បាស់ទេ អត់ចង់ច្បាស់ទេ។ ហើយមួយទៀត រូបថតបីនាក់នេះទៀត គឺថាខ្ញុំមើលអត់ចង់ច្បាស់ មិនដឹងពីណាៗទេ ព្រោះគេ ជួនកាលគេថតអារូបក្មេងៗយកមកនេះហ្នឹង យើងមើលអត់ច្បាស់ទេ ណាមួយអាភ្នែកខ្ញុំវាកើតភ្នែកក្រហម កើតភ្នែកក្រហមប៉ុន្មានថ្ងៃហើយ ប៉ុន្តែដល់ថ្ងៃនេះគឺថ្ងៃទីបញ្ចប់ គឺថាខ្ញុំត្រូវតែមកនិយាយរឿងរ៉ាវប្រាប់លោកប្រធាន។

[១៥:៤០:៥២]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះសំណួរមិនពាក់ព័ន្ធនឹងរូបថតទៀតទេ សំណួរបន្ថែមហ្នឹងគឺសួរបញ្ជាក់អំពីបញ្ហាការចូល

រួមនៅក្នុងការថតរូបណ៌ា ដើរតួៗដើម្បីឲ្យខាងភាពយន្តអាល្លឺម៉ង់ហ្នឹង អាល្លឺម៉ង់ខាងកើតហ្នឹងថតរូប បង្កើតជាខ្សែភាពយន្តនេះឡើង ហើយមានអតីតអ្នកជនរងគ្រោះនៅដែលបានរស់រានមានជីវិតពីស-២១ ត្រូវបានការរៀបចំនៃខាងខ្សែភាពយន្តនោះ អ្នកថតភាពយន្តនុំងគេមកអញ្ជើញដើម្បីរៀបចំថតជាខ្សែភាពយន្តឯកសារពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១។ សំណួរសួរថា ទី១ លោកដឹងទេ ដឹងថាវាមានការថតរូប ថតខ្សែភាពយន្តដោយអ្នកភាពយន្តរបស់អាល្លឺម៉ង់ដែលថាយកទៅបង្ហាញអង្គការសហប្រជាជាតិហ្នឹងដែរទេ បញ្ហាមួយ? បញ្ហាទី២ ប្រសិនបើលោកដឹងសួរថា ហេតុអ្វីបានជាលោកមិនបានចូលរួមនៅក្នុងសកម្មភាពនៃការដើរតួបង្ហាញខ្លួននៅក្នុងអំឡុងពេលនៃការថតខ្សែភាពយន្ត? ឥឡូវរឿងរូបថតអត់មាននិយាយទៀតទេ និយាយពីរឿងចម្លើយឆ្លើយនឹងសំណួរតែម្តង សំណួរបែបហ្នឹងគឺយើងសរុបឡើងវិញ គឺសំណួរមេធាវីដែលចង់ដឹង គឺចង់ដឹងពីលោកឲ្យផ្តល់ព័ត៌មានអំពីសំណួរបែបហ្នឹង?

**លោក ជុំ ម៉ី៖**

**ឆ៖** នៅពេលនោះយើងបានចូលរួមមែន ក៏ប៉ុន្តែយើងអត់បានខ្សែភាពយន្តហ្នឹងគាត់សួរព័ត៌មានពីខ្ញុំយ៉ាងម៉េច អីយ៉ាងម៉េចយើងអត់បានដឹងទេ។ គ្រាន់តែថតរូបហើយ ខ្ញុំ, អ៊ឹង ប៊ុច ហ្នឹងគាត់ឲ្យខ្ញុំមកកន្លែងខ្ញុំធ្វើការវិញ តែប៉ុណ្ណឹងទេ ខ្ញុំធ្វើការនៅគមនាគមន៍។

[១៥:៤២:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធានដែលបានអន្តរាគមន៍។ សំណួររបស់ខ្ញុំ គឺខ្ញុំចង់សួរថា តើលោកមានធ្លាប់ឮការពិភាក្សាគ្នាទេ ហេតុអ្វីបានជាផលិតករអាល្លឺម៉ង់ខាងកើតហ្នឹងមិន<ចង់>បាន<>រឿងរ៉ាវ<របស់លោកថតមុខកាមេរ៉ា ពួកគេមិនចង់ឲ្យលោកប្រាប់រឿងរ៉ាវរបស់លោកនៅចំពោះមុខកាមេរ៉ា>?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកម្តងទៀត គឺថា យើងគាត់អត់បានមកពិភាក្សាសួរស្អីៗទេ គឺថាគាត់ថតហើយ ចប់ហើយ ទៅបាត់ទៅ។ បើនិយាយពីអ្នកថតរូប ថតខ្សែភាពយន្តនោះរាប់មិនអស់ទេ ខ្ញុំរាប់មិនអស់ទេ នៅសារមន្ទីរទួលស្លែងហ្នឹង។ អាល្លឺម៉ង់ហ្នឹងមិនដឹងមកប៉ុន្មានដង បារាំងហ្នឹងមិនដឹងមកប៉ុន្មានដង ថតខ្សែភាពយន្ត បាទ ម៉្លោះហើយយើងមិនបានចាំអស់ទេលោកប្រធានបាទ។

**ស៖** ខ្ញុំយល់លោកដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹងថ្ងៃស្អែកខ្ញុំនឹងអាចបង្ហាញអំពីខ្សែភាពយន្តផ្នែកណាមួយនៅក្នុងខ្សែភាពយន្តនេះ ហើយមនុស្សដែលនៅក្នុងរូបភាពហ្នឹង គឺបានរៀបរាប់ពីរឿងរ៉ាវដែលបានកើតឡើងកន្លងមក ហើយពួកគាត់ហ្នឹងសុទ្ធតែមានរូបថតដើមរបស់គាត់នៅក្នុងមន្ទីរសន្តិសុខ

ស-២១។ <ហើយជាការពិតនោះ ពេលលោកមើល>ខ្សែភាពយន្តឯកសារនោះ គឺយើងឃើញមនុស្សទាំងអស់នោះ<កំពុង>និយាយហើយ<ឃើញអ្នកទោស ហើយ>លោកអាចឃើញអំពីរូប<ថតពួកគេ>នៅក្នុងមន្ទីរសន្តិសុខស-២១ ក៏ដូចជារៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងចំពោះ<ពួកគេ>។ ហើយតើលោកដឹងទេ ហេតុអីបានជាគេមិនបានដាក់រូបភាពលោកនៅក្នុងនោះដែរ នៅក្នុងស-២១នោះ?

[១៥:៤៤:៥៥]

**ឆ៖** អត់យល់។

**ស៖** ខ្ញុំសូមសួរតាមវិធីផ្សេង គឺលោកនៅ<>ទួលស្លែង<ជារៀងរាល់ថ្ងៃ។> ហើយខ្ញុំទៅទីនោះដែរ ហើយលោកឃើញរូប<ថតអ្នកទោស>ជាច្រើននៅតាមជញ្ជាំង ហើយលោកបានបញ្ជាក់ថា លោកត្រូវបានគេឃុំឃាំងនៅក្នុងខែតុលា <៧៨ ដូច្នេះគឺរយៈពេល២ខែមុនពេល>វៀតណាមចូល<ឈ្លានពាន>។ <សំណួររបស់ខ្ញុំគឺ> តើលោកដឹងទេ ហេតុអីបានជាមិនឃើញមានរូបថតលោកនៅមន្ទីរសន្តិ-សុខស-២១នេះ ក៏ដូចជារូបភាពដែលបង្ហាញ ក៏ដូចជាហ្វីលអីនៅទីនោះ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន នេះជាសំណួរដែលសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយស្មានហើយ បើមិនមាន<រូបថតគាត់ទេ> -- យើងដឹងថា មិនមានរូបថតគ្រប់អ្នកទោសទាំងអស់នៅស-២១ទេ។ ហើយបើសួរថា ហេតុអីបានជាមិនមានរូបគាត់ហ្នឹង គឺមិនមែនជាសំណួរត្រឹមត្រូវទេ។ បើសួរថាតើលោកបានឃើញរូបថតរបស់លោក ឬក៏អត់ ទើបត្រឹមត្រូវជាង។ ហើយបើសួរថា ហេតុអីបានជាមិនមានរូបថតលោកគឺសួរឲ្យស្មានហើយ។ អ៊ីចឹងអង្គជំនុំជម្រះសូមមេត្តារារាំងកុំឲ្យមេធាវីការពារក្តី សួរសំណួរមិនសមរម្យបែបនេះ។

[១៥:៤៦:៣៩]

**លោក ជុំ ម៉ី៖**

**ឆ៖** ក្នុងគាត់ឆ្លល់មូលហេតុអីដែលមិនឃើញរូបថតខ្ញុំនៅសារមន្ទីរទួលស្លែង។ រូបថតខ្ញុំ គឺថាគេថតរូបហ្នឹង គេពាក់ស្លាកហ្នឹង ខ្ញុំអត់បានពិនិត្យស្លាកហ្នឹងទេ គេថតរូបហ្នឹង។ ហើយអ្នកថតរូបហ្នឹងពីឆ្នាំទៅ ឆ្នាំទៅមួយនោះ ញ៉ែម អេន គាត់មកជួបខ្ញុំ។ ខ្ញុំសួរ អេន ឯងអារូបថតខ្ញុំ អេន ឯងទុកអីណាបានអត់ឃើញ? ហើយ ញ៉ែម អេន ហ្នឹងគាត់ប្រាប់ថា បងអើយ បងឯងសួរអ៊ីចឹង ខ្ញុំភ្លេចភ្លាំងអស់ហើយ អារូបថតអស់ហ្នឹង គេប្រមូលបីបួនកញ្ចប់យកដាក់អាផ្ទះខាងកើត ផ្ទះឈើខាងកើតនេះ ហើយគេ

ដុតចោលអស់ហើយ។ ហើយអារូបថតដែលនៅសល់បន្តិចបន្តួចហ្នឹង អាហ្នឹងវាសេសសល់ទេ។ អារូបថតនេះ គេដុតចោលអស់ហើយ ទាំងរូបថត ប៊ូ ម៉េង ស្អីៗហ្នឹង គឺថាគេដុតចោលអស់ហើយ។ នៅតែរូបថត អ៊ឹង ប៉ិច ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ឥឡូវសូម ខ្ញុំសូមបន្តទៅទៀតលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកចាំទេ នៅពេល<ណា>ដែលគេសួរចម្លើយលោកនៅលើកដំបូងនោះ? តើគេមានសួរឲ្យលោកបង្ហាញអំពីជីវប្រវត្តិរបស់លោកដែរឬទេ? ហើយតើលោកមាន<ប្រាប់អ្នកសួរ>ជីវប្រវត្តិ<របស់លោកនោះ>ពីអាយុពិតប្រាកដរបស់លោកដែរឬទេ នៅពេលនោះ?

**ឆ៖** គេសួរអារឿងជីវប្រវត្តិរបស់ខ្ញុំហ្នឹង គឺថាមុនដំបូង អាសេង ៗវាសួរ អ្ហែងស្រុកកំណើតនៅឯណា? ខ្ញុំថា ខ្ញុំនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ហើយដល់នេះអ៊ីចឹង មកអាក្រោយមកស្រុកក្រសាំងទងនេះ គេប្តូរផ្លាស់ក្រោយទេ។ មុនដំបូងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ អ៊ីចឹងគឺថា គេសួរហ្នឹងគឺថា អាសេង វាសួរ បងប្អូនប៉ុន្មាននាក់? អីប៉ុន្មាននាក់អ៊ីចឹង ឪពុកឈ្មោះអីៗ អាអ្នកវ៉ៃសួរចម្លើយហ្នឹង វាសួរខ្ញុំ ហើយខ្ញុំក៏បានរៀបរាប់ប្រាប់វាតាមហ្នឹងទៅ។

[១៥:៤៩:២៩]

**ស៖** ឥឡូវខ្ញុំសួរផ្សេងវិញ។ តើលោកមានបានប្រាប់ដែរឬទេ នៅខែតុលា ឆ្នាំ១៩៧៨នោះ ដែលលោកបានឆ្លើយថា លោកគឺអាយុ៤៧ឆ្នាំនោះ តើលោកមានបានឆ្លើយអ៊ីចឹងដែរឬទេ?

**ឆ៖** ៤៧! ៤៨។ គេចាប់ខ្ញុំអាយុ៤៨ មិនមែន ៤៧ទេ។

**ស៖** ខ្ញុំសួរកាលពីមុននេះ ពាក់ព័ន្ធជាមួយនឹងថ្ងៃខែឆ្នាំកំណើតរបស់លោក ហើយលោកបានបញ្ជាក់ថា គឺកើតនៅខែវិច្ឆិកា ឆ្នាំ១៩៣៣។ អ៊ីចឹងមានន័យថា នៅក្នុងខែតុលា ឆ្នាំ៧៨នេះ គឺលោកអាយុ<៤៥ឆ្នាំ មិនមែន>៤៧ មិនមែន៤៨ទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់បាននិយាយរៀបរាប់រឿង៤៧ទេ គឺថាគេចាប់មក៤៨។

**ស៖** ខ្ញុំជឿជាក់ថា តាមរយៈកំណត់ហេតុពាក់ព័ន្ធទៅនឹងស-២១នោះ គឺនៅពេលនោះ គឺលោកបញ្ជាក់ថា លោកអាយុ៤៧<>ឆ្នាំ<>ក្នុងខែតុលា ឆ្នាំ១៩៧៨។ <អ៊ីចឹងតើត្រឹមត្រូវទេ នៅខែតុលា ឆ្នាំ១៩៧៨> លោកអាយុ៤៣ ឆ្នាំ <មិនមែន៤៧ ឬ៤៨ទេ>?

**ឆ៖** គាត់សួរនេះ សួរពិបាកឆ្លើយ ហើយពិបាកស្តាប់ទៀត។ ម្តង៤៣ ម្តង៤៧ ម្តង៤៨ ពិបាក

ណាស់ដល់អ៊ីចឹង។

[១៥:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណី នេះជានីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ នីតិវិធីនៃការឈ្លេចសួរដេញដោលតាមផ្លូវតុលាការដើម្បីស្វែងរកការពិត។ លោកធ្លាប់ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការរួចហើយ។ អ៊ីចឹងសំណួរធម្មតា អ៊ីចឹងសំណួរនៅចំពោះមុខតុលាការមិនសំណួរធម្មតាទេ ហើយសំណួរនេះ ដើម្បីបញ្ជាក់ពីជំនឿទុកចិត្ត ថាតើលោកមានអ្នក ជាអ្នកអតីតអ្នកទោសនៅ ស-២១ ដែរឬទេ? នេះសំណួរដែលថាចង់សួរនេះ។ អ៊ីចឹងលោកត្រូវតែប្រឹងប្រែងឆ្លើយតបឱ្យបានត្រឹមត្រូវ។ ពាក្យឆ្លើយតបមិនមែន សំណួរគឺលទ្ធភាពដែលលោកអាចធ្វើទៅបាន។ ហើយខាងមេធាវីគេគណនាគណនាតាមគណិតវិទ្យាក្នុងការដកចេញរវាងឆ្នាំកំណើត ជាមួយនឹងកាលបរិច្ឆេទនៃការពាក់ព័ន្ធ ដើម្បីធ្វើការដកទូទាត់ដើម្បីសួរបញ្ជាក់។ អ៊ីចឹងលោកត្រូវឆ្លើយតបឱ្យបានច្បាស់លាស់។ គួរគិតគូរដោយខ្លួនឯងផងអំពីកិច្ចការទាំងនេះ ថាតើវាសមស្របដែរទេ? វាត្រឹមត្រូវដែរទេ? កើតឆ្នាំ១៩៣៣ ហើយដល់ពេល១៩៧៨ លោកអាយុប៉ុន្មាន? នេះជាបញ្ហាដើម្បីសួរបញ្ជាក់។

លោកយល់ទេនេះ? បាទ ត្រូវតែព្យាយាមក្នុងការឆ្លើយតបនឹងសំណួរ។ មិនមែនឱ្យតែ ពាក្យថាឆ្លើយតប វាមានន័យថា ឆ្លើយតបនូវអ្វីដែលដឹង អ្វីដែលមិនដឹងគឺឆ្លើយថាមិនដឹង។ ពាក្យថា មិនដឹង ក៏ជាចម្លើយតបដែរ។ ដូចលោកបានឆ្លើយអំមិញ អំពីបញ្ហាពាក់ព័ន្ធជាមួយនឹងរូបថតអ៊ីចឹង។ ដូច្នេះលោកគណនាឡើងវិញ ព្រោះនេះជារឿងអាយុ វាពាក់ព័ន្ធជាមួយនឹងអត្តសញ្ញាណផ្ទាល់ខ្លួនរបស់លោក។ យើងយល់អំពីបញ្ហាជា ក្នុងនាមជាខ្មែររវាង ៤៧ និង ៤៨ អាចមានបញ្ហារវាងការរាប់ របៀបរាប់ពីព្រោះខ្មែរយើង វកកើតហ្នឹង គាត់កើតឆ្នាំវក ឆ្នាំវករាប់មួយហើយ វក, វកា។ អ៊ីចឹងតែពីរថ្ងៃ ជួនកាលពីរបីថ្ងៃទេ បើកើតនៅក្នុងថ្ងៃចូលឆ្នាំហ្នឹង គ្រាន់តែដើមឆ្នាំ ដើមចូលឆ្នាំ ខែចេត្រ ១៣, ១២ហ្នឹង ទៅថ្ងៃ ១៤, ១៥ ហ្នឹងវាបានន័យថាពីរឆ្នាំបាត់ហើយ វាចូលវក, វកា ឃើញទេ! វាពីរឆ្នាំបាត់ហើយ ប៉ុន្តែបើគិតទៅតែពីរថ្ងៃទេ។ វាអាចករណីនេះកើតឡើង។ អ៊ីចឹងហើយបានជាគេគណនាទៅតាមខែឆ្នាំ។ អ៊ីចឹងហើយបានយើងព្យាយាមសួរឆ្នាំ ថ្ងៃខែឆ្នាំកំណើត នៅក្នុងនីតិវិធីចំពោះមុខតុលាការនេះ ដើម្បីឱ្យមានការបញ្ជ្រាបចូលទៅក្នុងប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាល ក៏ដូចជាកិច្ចការច្បាប់របស់ជាតិនេះផងដែរ។ លោកយល់ទេ? សូមលោកឆ្លើយតបទៅនឹងសំណួរ។ ព្រោះសំណួរគេសួរថា បើសិនជាលោកគិតពីថ្ងៃខែ

ឆ្នាំកំណើត រហូតដល់ថ្ងៃមួយពាន់ប្រាំបួនរយ – ខែ១០ ឆ្នាំ១៩៧៨ លោកអាយុប៉ុន្មាននិយាយឲ្យចំទៅ?

[១៥:៥៤:៤២]

**លោក ជុំ ម៉ីះ**

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកថាខ្ញុំ មិនបានគិតអីចឹងៗទេ រាល់ថ្ងៃហ្នឹងគឺថា វាភ្លេចភ្លាំងមួយចំនួនហើយ យើងវាមិនមែនអាយុតិចឯណា ៨៦ទៅហើយ ម្ល៉ោះហើយភ្លេចមុខភ្លេចក្រោយ យើងអត់មានចាំទាំងអស់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** មិនជាបញ្ហាទេ។ ឥឡូវលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមបន្តទៀត។ ខ្ញុំសូមសួរពាក់ព័ន្ធជាមួយនឹងឈ្មោះមួយចំនួនដែលខ្ញុំចង់សួរ ថាតើលោកសាក្សីដឹងឈ្មោះនេះដែរឬទេ បុគ្គលទាំងនេះដែរឬទេ?

លោកប្រធាន ខ្ញុំសូមការណែនាំរបស់លោក ថាតើខ្ញុំគួរធ្វើយ៉ាងណា គួរគ្រប់គ្រងយ៉ាងណា ពាក់ព័ន្ធទៅនឹងបញ្ជីអ្នកទោសថ្មី<របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានបញ្ជូនមកឲ្យយើងខ្ញុំកាលពីពីរសប្ដាហ៍កន្លងទៅ> ដែលមានលេខ E/393.2 <*(ស៊ីក)*។ ដូចលោកដឹងហើយ យោងតាម> អ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់<> ក៏បានបញ្ជាក់<អូ.ស៊ី.អាយ.ជេ បានធ្វើការអស់រយៈពេល២ឆ្នាំ ដើម្បីធ្វើសេចក្ដីព្រាងថ្មីនៃ>បញ្ជីឈ្មោះអ្នកទោស ស-២១។ ដូច្នេះ ខ្ញុំចង់ប្រើប្រាស់នូវបញ្ជីឈ្មោះថ្មីនេះ ហើយ<មិនប្រើប្រាស់បញ្ជីឈ្មោះដែលពិនិត្យឡើងវិញដោយ អូ.ស៊ី.ភី ដែល>យើង <>បានប្រើប្រាស់<ជាយូរមកហើយនោះទេ>។ ហើយ<កាន់តែពិសេសទៅទៀតនោះ> ខ្ញុំ<គិតថា វាកាន់តែងាយស្រួលបំផុត ដូចជាការប្រើប្រាស់តួលេខ> ដែល<ត្រូវបាន>ប្រើប្រាស់ដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រម <>ពាក់ព័ន្ធទៅនឹងសំណុំរឿង០០៣, ០០៤នេះ។ <ដូច្នេះហើយ ពេលដែលខ្ញុំបញ្ជាក់ពីតួលេខទាំងអស់នេះ នោះភាគីទាំងអស់ រួមទាំងអង្គជំនុំជម្រះផង នឹងមិនមានការលំបាកក្នុងការយល់ថាតើនរណាដែលខ្ញុំកំពុងនិយាយនោះ។> ដើម្បីឲ្យកាន់តែច្បាស់នោះ ឧទាហរណ៍ថា ខ្ញុំចង់សួរដើមបណ្ដឹងរដ្ឋប្បវេណី ថាតើគាត់ដឹង ឬក៏ស្គាល់អ្នកទោសលេខរៀង៦៦៥ <នៅក្នុងបញ្ជីថ្មីទេ? មិនត្រឹមតែលេខរៀង ៦៦៥ ទេ> ក៏<>មានលេខរៀង៩.៣៣៧, <៩.៤៣១> ហើយនិងអ្នកទោសលេខរៀង ១០.៥៦១។ <ទាំងនេះគឺជាតួលេខចំនួន៤> ដែលខ្ញុំចង់សំដៅទៅលើឈ្មោះដែលពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះអ្នកទោសទាំងអស់នេះ។ លោកប្រធាន សូមការអនុញ្ញាតប្រើប្រាស់នូវបញ្ជីឈ្មោះទាំងអស់នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដើម្បីសួរផ្ទាល់ទៅនឹងលោកដើមបណ្ដឹងរដ្ឋប្បវេណី ថាតើគាត់ដឹង ឬក៏ស្គាល់ដែរឬទេ នូវមនុស្សទាំងអស់នេះ?

[១៥:៥៧:៥៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឲ្យមេធាវីការពារក្ដីបញ្ជាក់លេខឯកសារឡើងវិញ ព្រោះថាបើតាមការស្ដាប់ឮលេខអម្បាញ់មិញនេះ ខ្ញុំរកមិនឃើញនៅក្នុង*ហ្វាយឡេក*ទ សូមបញ្ជាក់ឡើងវិញ លេខកូដឯកសារ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺជាឯកសារមួយដ៏ធំ គឺមានប្រហែល<៧០០ ឬ៨០០>ទំព័រ។ <តួ>លេខ<៦៦៥> គឺ <មនុស្សម្នាក់ឈ្មោះ> ជា ហ៊ុច, គឺលេខរៀង<៩.៣៣៧> គឺ ស៊ុន ឌិន ហើយ<៩.៤៣១>គឺ ណេត កន ហៅ នួន ហើយនិងលេខរៀង<១០.៦៥១> គឺលោកមានឈ្មោះថា ប៊ុន ណោង ហើយនិងលេខរៀង ៩.៤៣២ គឺមានឈ្មោះ ជិន សុខ។ ដូច្នេះលោកដើមបណ្ដឹង តើលោកធ្លាប់ឮមនុស្សឈ្មោះ ជា ហ៊ុច ហ្នឹងដែរឬទេ ស៊ុន ឌិន, ណេត កន, ជិន សុខ និង ប៊ុន ណោង?

**លោក ជុំ ម៉ី៖**

**ឆ៖** ជម្រាបប្រសាសន៍លោក ឈ្មោះទាំងអស់នេះ ខ្ញុំអត់បានដឹង អត់បានឮទេ អត់បានស្គាល់ទេ។

[១៦:០០:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រហែលជាសហការីជនជាតិខ្មែរខ្ញុំអាចអានច្បាស់ជាង ព្រោះយើងមានឈ្មោះជាភាសាខ្មែរ ដោយយើងអាចអានច្បាស់។ ដូច្នេះយើង<>អាច<ឲ្យ>ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ពិនិត្យឈ្មោះនៅលើបញ្ជីនោះបាន ព្រោះយើងមានជាភាសាខ្មែរ។ អ៊ីចឹងសូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត។ សូមអញ្ជើញ!

**លោក លីវ សុវណ្ណា៖**

បាទ លេខរៀងទី៤៧៨ ជុំ ម៉ី, លេខរៀងទី៦៦៥ ជា ហួត, លេខរៀង៩៣៣៧ ស៊ុន ឌឹម, លេខ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01247045



រៀង៩៤៣១ នេត ខន, លេខរៀង១០៦៥១ ប៊ុន ណោង។ បាទ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសង្ឃឹមថា ការអានជាភាសាខ្មែរច្បាស់។ តើលោកដើមបណ្ដឹងរដ្ឋប្បវេណីមានស្គាល់ឈ្មោះបុគ្គលទាំងអស់នេះដែរឬទេ?

**លោក ជុំ ម៉ី៖**

**ឆ៖** ខ្ញុំអត់បានស្គាល់ឈ្មោះទាំងអស់នេះទេ។

**ស៖** អ៊ីចឹងមានន័យថា លោកអស់ស្គាល់អ្នកណាម្នាក់ទេ មិនអ៊ីចឹងអ្ហេ?

**ឆ៖** បាទ អត់ស្គាល់ទេ។

[១៦:០១:៥៨]

**ស៖** ប្រហែលជានេះជាហេតុផលល្អមួយដែរ ក៏ប៉ុន្តែបុគ្គលដែលខ្ញុំបានបញ្ជាក់ហ្នឹងគឺសុទ្ធតែសុទ្ធសឹងតែធ្វើការងារនៅ<ផ្នែកផលិតសម្លៀកបំពាក់>ក្នុងគ-៩ <ជាមួយគ្នា ហើយពួកគេទាំងអស់ត្រូវបានចាប់ខ្លួនប្រហែលជានៅថ្ងៃជាមួយគ្នា ឬពេលជាមួយគ្នា>នឹងលោក ជុំ ម៉ី ដែលជារូបលោកដើមបណ្ដឹងរដ្ឋប្បវេណីផ្ទាល់តែម្ដង។

**ឆ៖** ក្នុង គ-៩ ហ្នឹងវា គេមានចែកជាក្រុមៗ ខ្ញុំមិនស្គាល់គេអស់ទេ អត់បានស្គាល់គេអស់ទេ ព្រោះមនុស្សរាប់ពាន់ រាប់រយ ខ្ញុំអត់បានស្គាល់ទេ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់វិញ លោកដើមបណ្ដឹងរដ្ឋប្បវេណី គឺមានលោក គឹម ចាន់ ដែលជាអនុប្រធាន<ក្រុមមួយ>នៅក្នុងគ-៩ <ផ្នែកផលិតសម្លៀកបំពាក់>។ តើលោក<មិនធ្លាប់ឮឈ្មោះគាត់>ទេ<ឬ>?

**ឆ៖** បាទ អត់ឈ្មោះ គឹម ចាន់ ហ្នឹងទេ អត់មានទេ។

**ស៖** សូមអធ្យាស្រ័យ គឺខ្ញុំហៅខុសទេ គឺលោក ជា ហួត <>ជា<អ្នកដែលខ្ញុំចង់និយាយនោះ>ជាប្រធាន<ក្រុមផ្នែកអ៊ុតចំហាយទឹក នៅ គ-៩ ក្នុងមន្ទីរ ៩> ហើយនិងលោក ស៊ុន ឌឹម ដែលជាមេកងកាត់ដេរ ហើយនិង នេត ខន។ <ទាំងអស់នេះត្រូវបានចាប់ខ្លួនមួយថ្ងៃក្រោយលោក។ ពួកគេទាំងអស់>ធ្វើការ<នៅមន្ទីរតែមួយទេ តាមមើលទៅ>។ តើលោកចាំឬទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន អម្បាញ់មិញនេះខ្ញុំស្នើសុំឲ្យមេធាវីការពារក្ដី ឲ្យផ្ដល់លេខE3ឡើងវិញ លេខបញ្ជី

ឯកសារហ្នឹង ហើយខ្ញុំអត់ទាន់ទទួលទេ។ អ៊ីចឹងសុំឲ្យបញ្ជាក់លេខបញ្ជីហ្នឹងឡើងវិញ ហើយតើមេធាវីការពារក្ដីអានហ្នឹង អានឈ្មោះបដិវត្តន៍ ឬក៏ឈ្មោះពេញអ្នកទាំងអស់ហ្នឹង? ប្រហែលជាដើមបណ្ដឹងរដ្ឋប្បវេណីអាចដឹងឈ្មោះ។ ដូច្នេះបើក្នុងចន្លោះឆ្នាំ៧៥-៧៩ បើមិនអានឈ្មោះបដិវត្តន៍ទេ ដើមបណ្ដឹងប្រហែលជាគាត់មិនដឹងទេ។ អ៊ីចឹងសូមទី១ ឲ្យលេខបញ្ជីអ្នកទោសហ្នឹង លេខE3ហ្នឹង សូមបញ្ជាក់ឡើងវិញ។

[១៦:០៤:៥៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោក វ៉ិចទ័រ កូប៉េ!

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់នៅក្នុងប្រតិចារឹក អត់មានឯកសារ E3 ហ្នឹងទេ គឺ E393.2 តែម្ដង មិនមែនដូចលោកថា E3/393.2 ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកចៅក្រម។ ហើយ<ខ្ញុំក៏ព្រួយបារម្ភបន្តិចបន្តួចដែរ ដោយសារព្រះរាជអាជ្ញាមិនបានដឹងពីផលិតផលនៃការធ្វើការខំប្រឹងធ្វើការងាររយៈពេល២ឆ្នាំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អត់មាន>ឈ្មោះបដិវត្តន៍<ទេ។ ពួកគេបានប្រើឯកសារ>ស-២១ <ដើម្បី>រៀបចំបញ្ជីឈ្មោះអ្នកទោសទាំងអស់នោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <ជាថ្មីម្ដងទៀត>លោកដើមបណ្ដឹងរដ្ឋប្បវេណី <ខ្ញុំមានការសង្ស័យបន្តិចចំពោះការពិតដែលលោកមិនស្គាល់មនុស្សណាម្នាក់ ដែល>ត្រូវបានគេចាប់ខ្លួននៅ<ថ្ងៃជាមួយលោក ឬមួយថ្ងៃក្រោយមក ហើយពួកគេធ្វើការនៅរោងចក្រជាមួយ>លោកដែរ។ តើលោក<>អាចពន្យល់បានទេចំពោះហេតុការណ៍ទាំងអស់នេះ?

[១៦:០៦:១១]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប!

អញ្ជើញមេធាវី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់មួយ ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីយល់ច្បាស់នោះ គួរតែសួរថា តើគាត់ធ្វើការនៅក្នុងកងអី នៅគ-៩ហ្នឹង? ពីព្រោះថាមេធាវីការពារក្ដីនិយាយអំពីឈ្មោះដែលអ្នកធ្វើការនៅក្នុងកងផ្សេងៗនៅ<ក្នុងរោងចក្រនោះ> ហើយ<ដើមបណ្ដឹងរដ្ឋប្បវេណី> បានបញ្ជាក់ហើយថាមានមនុស្ស<រាប់ពាន់នាក់>ធ្វើការនៅកន្លែងនោះ ហើយមានច្រើនកង។ អ៊ីចឹងដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីគាត់ដឹងច្បាស់ គួរបញ្ជាក់ថាតើអ្នកទាំងអស់ហ្នឹងធ្វើការនៅក្នុងកងអីខ្លះនៅគ-៩ហ្នឹង ដើម្បីឲ្យដឹងថាតើឈ្មោះហ្នឹងចេញមកពីកងតែមួយជាមួយនឹងលោក ជុំ ម៉ី ឬក៏កងផ្សេងប៉ុន្តែនៅគ-៩ ជាមួយគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចឆ្លើយតបទៅនឹងអ្វីដែលលើកឡើងនេះ <>លោកប្រធាន ខ្ញុំអាចបញ្ជាក់ថា នេះគឺជាសក្ខីកម្ម<របស់ដើមបណ្ដឹងរដ្ឋប្បវេណីផ្ទាល់ខ្លួនគាត់ ដែលគាត់មិនត្រូវបានចាប់ខ្លួនតែម្នាក់ឯងនោះទេ គាត់ត្រូវបាន>ចាប់ខ្លួន<ជាមួយ>មនុស្សពីរនាក់<ទៀត។ វាអាចត្រឹមត្រូវដែរ> ដែល<>ថា នៅក្នុង<រោងចក្រ>នោះ <>មានមនុស្សរាប់ពាន់<នោះ ប៉ុន្តែខ្ញុំ>មិនដឹងច្បាស់នោះទេ។ <នៅពេលនេះ ខ្ញុំគ្រាន់តែធ្វើការសន្និដ្ឋានបឋម>ថា លោកដើមបណ្ដឹងរដ្ឋប្បវេណីមិនបានស្គាល់អ្នកទាំងអស់នោះ ដែលត្រូវបានគេចាប់ខ្លួន<ជាមួយ>គាត់<នៅពេលជាមួយគ្នានោះ>ទេ។ <ហើយខ្ញុំ>គ្រាន់តែចង់ដឹងថា តើមានលោកដើមបណ្ដឹងរដ្ឋប្បវេណីគាត់អាចបញ្ជាក់ ឬក៏ពន្យល់ពីហេតុការណ៍ហ្នឹងបានឬក៏អត់ ហេតុអីបានគាត់អត់ដឹង? <ខ្ញុំគិតថា ខ្ញុំអាចសួរសំណួរទាំងអស់នេះបាន។>

[១៦:០៨:០៤]

**លោក ជុំ ម៉ី៖**

**ឆ៖** បានជាខ្ញុំអត់ដឹង គេអត់ប្រាប់ខ្ញុំថាគេចាប់ឈ្មោះនេះ ចាប់ឈ្មោះនោះអីយកទៅនេះ យកទៅនោះ យើងអត់ដឹងទេ។ យើងដឹងគ្រាន់ថា អ្នកនោះបាត់ អ្នកនេះបាត់ តែមិនដឹងទៅណាទេ ខ្លះគេថាយកទៅច្រូតស្រូវ ខ្លះយកទៅអីឯណា ដឹកជញ្ជូនស្អីៗ ពាសទឹកពាសដីអីចឹងទៅណា។ អ៊ីចឹងខ្ញុំអត់បានស្គាល់ឈ្មោះអស់ហ្នឹងច្បាស់លាស់ទេ អត់បានស្គាល់ទេឈ្មោះហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ អរគុណលោកមេធាវី។ បាទឥឡូវនេះដល់ពេលសម្រាកហើយសវនាការនៅថ្ងៃនេះ ហើយសវនាការផ្តល់សក្ខីកម្មលោក ជុំ ម៉ី ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ ណ៎ា លោក ជុំ ម៉ី ការផ្តល់សក្ខីកម្មរបស់លោកគឺគ្រោងធ្វើតែមួយថ្ងៃទេ ប៉ុន្តែឥឡូវមិនទាន់ចប់ទេ ដោយមូលហេតុមានបញ្ហាបច្ចេកទេសនីតិវិធីដែលត្រូវបានអង្គជំនុំជម្រះបំពេញកិច្ចកាលពីព្រឹកមិញគឺអស់រយៈពេលមួយចំនួន។ ដូច្នេះគឺអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលទំនងជាប្រើរយៈពេលមិនលើសពីមួយម៉ោងទេ ក្នុងការបន្តស្តាប់សក្ខីកម្មរបស់លោកនៅព្រឹកថ្ងៃស្អែកនេះ។

ហើយឥឡូវនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់នាថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-911 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឱ្យអនុរក្ស -- ឱ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក ជុំ ម៉ី វិញត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណា -- ឬក៏ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់ មកចូលរួមផ្តល់សក្ខីកម្មនៅថ្ងៃស្អែក នៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូប ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១០នាទី)*